ឧសភ២០២២

# តំបន់ការពារធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា

## អត្ថបទវិភាគអំពីក្របខណ្ឌច្បាប់ និង បទពិសោធន៍របស់សហគមន៍



ClientEarth

## ClientEarth

A future in which people and planet thrive together isn't just possible: it's essential. We use the power and rigour of the law to create it; informing, implementing and enforcing legislation, training legal and judicial professionals, and proposing policy. Our programmes of work span two broad categories: climate and pollution, and protection of nature. Our climate and pollution efforts defend our rights to a healthy existence. We force governments around the world to uphold their commitment to the Paris Agreement, decarbonise energy and tackle pollution hazardous to human and environmental health. Our nature protection work fights on behalf of vital ecosystems upon which we depend: forests, oceans and wildlife. We push for ambitious new legal protections and radical reforms to industry, and hold lawbreakers to account.


## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះបានរៀបចំឡើងដោយក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលមួយ និង ClientEarth[១]

យើងសូមធ្វើការថ្លែងអំណរគុណដល់អ្នកជំនាញដែលបានចែករំលែកបទពិសោធន៍របស់ពួកគាត់ក្នុងការធ្វើការងារក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងលើប្រធានបទពាក់ព័ន្ធជាមួយពួកយើង ដែលក្នុងនោះមានតំណាងពីអង្គការជនជាតិដើមភាគតិចកម្ពុជា ( CIPO ) សមាគមសកលសម្រាប់ប្រជាជន និងបរិស្ថាន ( GAPE ) ព្រៃឡង់បៃតង ( GPL ) អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើ ( NTFP-EP ) មូលនិធិសត្វព្រៃពិភពលោក ( WWF ) អង្គការព្រៃឈើ និងជីវភាព ( FLO ) សមាគមតំបន់ខ្ពង់រាប ( HA ) សមាគមអភិរក្សសត្វព្រៃ ( WCS ) និងធនាគារពិភពលោក ( WB )។



អ្នកស្រាវជ្រាវបង្គោលនៃរបាយការនេះរួមមាន:

**Kanyara Sath**, Independent Consultant; **Brian Rohan**, Head of Programme, Forests, ClientEarth; **Yena Kwon**, International Environmental Policy and Law Consultant; **Isaac Horenblas**, Legal Researcher, Lewis and Clark Law School; and **Yao Wang**, Public Policy Researcher, Columbia University School of International and Public Affairs.


រាល់កំហុសឆ្គង ឬភាពមិនត្រឹមត្រូវនៅក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។

## Disclaimer

This Report is not offered as advice on any particular matter and must not be treated as a substitute for specific advice. In particular, information in this publication does not constitute legal, professional, financial or investment advice. Advice from a suitably qualified professional should always be sought in relation to any particular matter or circumstances. Any references and findings in this Report with regard to individual companies are for illustrative purposes only, express the opinion of ClientEarth and are based upon sources believed to be accurate and reliable.


© 2022, ClientEarth. All rights reserved.

# មាតិកា


សេចក្តីថ្លែងអំណរគុណ
ពាក្យកាត 2
ខ្លឹមសារសង្ខេប 3
សេចក្តីផ្តើម 6
សារ់តា 7

## ក្របខ័ណ្ឌ CPA

១. ការកាន់កាប់ដីធ្លី 9
២. ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ 14
៣. អភិបាលកិច្ចផ្ទៃក្នុងសហគមន៍ 21
៤. ការចូលរួម និងតំណាងពីខាងសហគមន៍ 25
៥. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាត 28
៦. ការទទួលបាន (ស្វែងរកបាន) ទីផ្សារ 32
៧. ការបែងចែកផលប្រយោជន៍ 36
៨. ដំណោះស្រាយវិវាទ 38
៩. ការអនុវត្តច្បាប់ 41
១០. ការគាំទ្រពីខាងក្រៅ 45

កំណត់ចំណាំចុងក្រោយ 48
គន្ថនិទ្ទេស 55
ច្បាប់ និងគោលនយោបាយ 56

# ពាក្យកាត់

| | |
|---|---|
| **CEDT** | ក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ |
| **CF** | សហគមន៍ព្រៃឈើ |
| **CIPO** | អង្គការជនជាតិដើមភាគតិចកម្ពុជា |
| **CLT** | ប័ណ្ណកម្មសិទ្ធិដីសមូហភាព |
| **CPA** | សហគមន៍តំបន់ការពារធម្មជាតិ |
| **ELC** | សម្បទានដីសេដ្ឋកិច្ច |
| **FA** | រដ្ឋបាលព្រៃឈើ |
| **FLO** | អង្គការព្រៃឈើ និងជីវភាព |
| **FPIC** | គោលការណ៍ដោយសេរី ជាមុន និងការយល់ព្រមដែលទទួលបានព័ត៌មាន (គោលការណ៍អេហ្វពិក) |
| **GDANCP** | អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ |
| **GPL** | ព្រៃឡង់បៃតង |
| **HA** | សមាគមតំបន់ខ្ពង់រាប |
| **LCIPs** | សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើម |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MLMUPC** | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **MoE** | ក្រសួងបរិស្ថាននៅកម្ពុជា |
| **MOI** | ក្រសួងមហាផ្ទៃនៅកម្ពុជា |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **NTFP** | អនុផលព្រៃឈើមិនមែនឈើ |
| **NTFP-EP** | អង្គការកម្មវិធីផ្លាស់ប្តូរបទពិសោធន៍អនុផលព្រៃឈើ |
| **PA** | តំបន់ការពារធម្មជាតិ |
| **PDo** | មន្ទីរបរិស្ថានខេត្ត |
| **WB** | ធនាគារពិភពលោក |
| **WWF** | មូលនិធិសត្វព្រៃពិភពលោក |

# ខ្លឹមសារសង្ខេប

## គេសង្កេតឃើញថាមានកំណើននៃការទទួលស្គាល់ជាសកលអំពីតួនាទីដ៏សំខាន់នៃការចូលរួមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងការអភិរក្សជីវៈចម្រុះ។

នៅពេលដែលក្របខ័ណ្ឌច្បាប់ជាពិសេសក្របខ័ណ្ឌច្បាប់ថ្នាក់ជាតិ ផ្តល់លទ្ធភាពឲ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចចូលរួមនៅក្នុងកិច្ចការអភិរក្សនេះ គេសង្កេតឃើញថានឹងអាចមានការសម្រេចបាននូវផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម សេដ្ឋកិច្ច និងវប្បធម៌រយៈពេលយូរអង្វែង។

អត្ថបទវិភាគនេះត្រូវបានរៀបចំឡើងក្រោយការពិភាក្សាជាបឋមជាមួយដៃគូពាក់ព័ន្ធជាច្រើន ដែលក្នុងនោះរួមមានក្រសួងបរិស្ថាន ដែលបានបង្ហាញចំណាប់អារម្មណ៍ក្នុងការពិនិត្យមើលសក្តានុពលនៃមធ្យោបាយនានាក្នុងការពង្រឹងប្រព័ន្ធសហគមន៍តំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន។ របាយការណ៍នេះបានធ្វើការឆ្លុះបញ្ចាំងពីចន្លោះប្រហោងរបស់ក្របខ័ណ្ឌច្បាប់ បញ្ហាប្រឈមនៃការអនុវត្ត និងផ្តល់នូវអនុសាសន៍សម្រាប់ជាដំណោះស្រាយទៅលើចន្លោះប្រហោង និងបញ្ហាប្រឈមដែលបានលើកឡើង។

របាយការណ៍នេះបែងចែកជា ១០ (ដប់) ផ្នែកសំខាន់ៗដែលបង្កើតចេញពីគំរូរបស់ ClientEarth[2] អំពីមូលដ្ឋានគ្រឹះសំខាន់ចំនួន១០ នៃក្របខ័ណ្ឌច្បាប់ ដែលគាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍ដូចជាសហ-គមន៍តំបន់ការពារធម្មជាតិ។ ខណៈពេលដែលរបាយការណ៍នេះផ្តោតសំខាន់ទៅលើបញ្ហានានានៅក្នុងបរិបទនៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន លទ្ធផលពិភាក្សានៃរបាយការណ៍នេះក៏អាចប្រើប្រាស់ជាការណែនាំចំពោះកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ណាមួយនៅក្នុងប្រព័ន្ធសហគមន៍ព្រៃឈើ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទផងដែរ។

លទ្ធផលនៃការវិភាគរបស់យើងទៅលើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ ដែលប្រើប្រាស់មូលដ្ឋានគ្រឹះចំនួន ១០នៃគំរូរបស់ ClientEarth នាំមកនូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

### ១. ការកាន់កាប់ដី

បញ្ហាប្រឈមចម្បងចំពោះមុខរបស់សហគមន៍តំបន់ការពារធម្មជាតិគឺភាពអសុវត្ថិភាពនៃការកាន់កាប់ដីធ្លី។ នៅក្រោមក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ សិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់សហគមន៍មានតែមួយផ្នែកប៉ុណ្ណោះ ពោលគឺពួកគេអាចអនុវត្តបានសិទ្ធិចេញ-ចូល សិទ្ធិប្រើប្រាស់ សិទ្ធិទាញយកផល និងសិទ្ធិគ្រប់-គ្រង។ ទោះជាយ៉ាងណាក្តី សហគមន៍តំបន់ការពារធម្មជាតិមានការខ្វះខាតនូវការប្រើប្រាស់សិទ្ធិហាមឃាត់ (សមត្ថភាពក្នុងការហាមឃាត់អ្នកខាងក្រៅកុំឲ្យចូលក្នុងតំបន់ព្រៃសហគមន៍ ឬប្រើប្រាស់ដី) ដែលធ្វើឲ្យការកាន់កាប់ដីធ្លីរបស់សហគមន៍មានភាពចុះខ្សោយដែលធ្វើឲ្យប៉ះពាល់ដល់ការរៀបចំផែនការរយៈពេលវែង ការសម្រេចចិត្តទាក់ទងនឹងជីវភាព និងការអភិរក្សរបស់សហគមន៍។ ការកែសម្រួលក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិដោយអនុញ្ញាតឲ្យសហគមន៍ទទួលបានសិទ្ធិកាន់កាប់ដីធ្លីសមរម្យបន្ថែមទៀតរួមមានសិទ្ធិមិនអនុ-ញ្ញាតឲ្យអ្នកខាងក្រៅចេញ-ចូល នឹងបង្កើនប្រសិទ្ធភាពនៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្ម-ជាតិបានយ៉ាងប្រសើរ។ លើសពីនេះទៅទៀត ការបន្ថែមរយៈពេលនៃការកាន់កាប់ដីរបស់សហគមន៍តំបន់ការពារធម្មជាតិ នឹងអនុញ្ញាតឲ្យសហគមន៍មានការចូលរួមយ៉ាងពេញលេញ និងជាប់លាប់នៅក្នុងសកម្មភាពគ្រប់គ្រងសម្រាប់រយៈពេលវែង។

### ២. ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

ភាពស្មុគស្មាញផ្នែករដ្ឋបាលពាក់ព័ន្ធនឹងការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ បង្ខំឲ្យសហគមន៍ពឹងផ្អែកទៅលើមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីជួយនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការបង្កើតសហគមន៍។ ការធ្វើឲ្យមានភាពងាយស្រួលពាក់ព័ន្ធនឹងការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ស្របជាមួយការធានាឲ្យបាននូវការចូលរួមដ៏មានអត្ថន័យរបស់សហគមន៍នៅក្នុងការកំណត់ផែនទី និងការកំណត់តំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ នឹងសហគមន៍តំបន់ការពារធម្មជាតិទាំងមូល នឹងនាំឲ្យមានភាពប្រសើរជាងមុននៃការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការនៃការបង្កើតសហគមន៍ និងក្នុងការទទួលផលប្រយោជន៍ពីប្រព័ន្ធសហគមន៍តំបន់ការពារធម្មជាតិទាំងមូល។

## ៣. អភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍

តម្លាភាព និងគណនេយ្យភាពគឺមានសារៈសំខាន់នៅក្នុងការធ្វើឲ្យមានប្រសិទ្ធភាពនៃអភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍។ ទោះជាយ៉ាងណាក្តី ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិមិនមានចែងជាក់លាក់អំពីយន្តការគណនេយ្យភាពនោះទេ។ លើសពីនេះទៅទៀត សេចក្តីណែនាំ ឬលក្ខខណ្ឌតម្រូវជាក់លាក់ស្តីពីតម្លាភាពគឺកម្រនឹងឃើញមាន និងហាក់ដូចជាមានភាពរប៉ាត់របាយនៅក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ។ ការដាក់បន្ថែមទៀតនូវយន្តការគណនេយ្យភាព និងតម្លាភាពនឹងជួយសហគមន៍មូលដ្ឋានឲ្យសម្រេចបាននូវការគ្រប់គ្រង និងចាត់ចែងសហគមន៍តំបន់ការពារធម្មជាតិដែលបានបង្កើតរួចដោយខ្លួនឯង។

## ៤. ការចូលរួម និងភាពជាតំណាងក្នុងសហគមន៍

វត្តមាននៃក្រុមជនងាយរងគ្រោះ ក្នុងចំណោមថ្នាក់ដឹកនាំជួយធានាដោះស្រាយនូវតម្រូវការរបស់សមាជិកទាំងអស់ក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្នភាគច្រើនគ្របដណ្តប់ដោយបុរស ហើយការរួមបញ្ចូលស្ត្រី យុវជន និងសមាជិកសហគមន៍ដែលខ្វះខាតត្រូវការមានការលើកទឹកចិត្តបន្ថែមទៀត។ ការជ្រើសរើសបុគ្គលងាយរងគ្រោះ និងពង្រឹងការការពាររបស់ពួកគាត់ក្នុងបំណងលើកទឹកចិត្តក្នុងការចូលរួម អាចនាំឲ្យមានប្រសិទ្ធភាពក្នុងការបង្កើនពិពិធភាពក្នុងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

## ៥. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ជាញឹកញយ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមានសភាពស្មុគស្មាញក្នុងការអនុវត្តដោយសហ-គមន៍ខ្លួនឯងផ្ទាល់។ ជារឿយៗផែនការទាំងនោះ ក៏ត្រូវបានរឹតត្បិតក្នុងការរួមបញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលមានតម្លៃ និងសមស្របជាមួយវិធានការអភិរក្សប្រកដោយចីរភាព ដូចជាសិទ្ធិក្នុងការបង្កើតកិច្ចព្រមព្រៀងជាមួយភាគីទីបីដោយផ្ទាល់ និងការគ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម។ ការសម្រួលលក្ខខណ្ឌផែនការគ្រប់គ្រង អនុញ្ញាតឱ្យតម្រឹមកម្រិតនៃភាពស្មុគស្មាញមកត្រឹមសកម្មភាពដែលបានស្នើឡើង និងពង្រីកសិទ្ធិគ្រប់គ្រង ដែលអនុញ្ញាតឱ្យសហគមន៍តំបន់ការពារធម្មជាតិអាចបង្កើតកិច្ចព្រមព្រៀងជាមួយភាគីទីបីដើម្បីធ្វើសកម្មភាពពាណិជ្ជកម្មបែបចីរភាព ដែលនឹងបង្កើនការស្វ័យអាស្រ័យរបស់សហគមន៍អំឡុងការកាន់កាប់ និងធ្វើឱ្យប្រសើរឡើងនូវជម្រើសនៃជីវភាពរស់នៅ ដូចជាការផ្តល់ផលប្រយោជន៍ដល់សហគមន៍ ខណៈសហគមន៍តំបន់ការពារធម្មជាតិគ្រប់គ្រងដី និងធនធានធម្មជាតិដោយចីរភាព។

## ៦. ការទទួលបាន (ស្វែងរកបាន) ទីផ្សារ

កង្វះខាតនូវភាពច្បាស់លាស់ស្តីពីលក្ខខណ្ឌបញ្ញត្តិសម្រាប់សកម្មភាពសេដ្ឋកិច្ច (ដូចជាអាជ្ញាបណ្ណ) អាជ្ញាធរទទួលបន្ទុក និងបទបញ្ញត្តិជាក់លាក់ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិក្នុងការគ្រប់គ្រង និងប្រើប្រាស់ដី និងធនធនធម្មជាតិដោយចីរភាព។ ការបញ្ជាក់ច្បាស់លាស់ និងសម្រួលនូវនីតិវិធីផ្តល់អាជ្ញាបណ្ណ បញ្ជាក់ពីអាជ្ញាធរទទួលបន្ទុក និងភ្ជាប់ទំនាក់ទំនងរវាងសហគមន៍តំបន់ការពារធម្មជាតិ និងវិស័យឯកជន នឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពសហគមន៍ និងការទទួលបានទីផ្សារ។ ដើម្បីពង្រឹងភាពជាដៃគូរវាងសហគមន៍តំបន់ការពារធម្មជាតិ និងវិស័យឯកជន សហគមន៍ នៃសហគមន៍តំបន់ការពារធម្មជាតិគួរតែទទួលបានការគាំទ្រក្នុងការពង្រឹងសមត្ថភាព ដើម្បីកាត់បន្ថយហានិភ័យនៃអតុល្យភាពនៃអំណាច ឬការកាន់កាប់ដោយអភិជនមួយក្រុមតូច។

## ៧. ការបែងចែកផលប្រយោជន៍

ជាទូទៅ ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ ណែនាំពីរបៀបបែងចែកផលប្រយោជន៍ដោយតម្លាភាព គណនេយ្យភាព និងសមភាព ប៉ុន្តែពុំបានបញ្ជាក់ពីរបៀបក្នុងបែងចែកផលប្រយោជន៍ដែលត្រូវអនុវត្តក្នុងសហគមន៍តំបន់ការពារធម្មជាតិឡើយ។ ដូច្នេះ ការណែនាំបន្ថែមទៀត គឺជាការចាំបាច់សម្រាប់បែងចែកផលប្រយោជន៍ក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ ការផ្តល់កត្តាក្នុងការពិចារណា ជម្រើស គំរូ បទដ្ឋានអប្បរមា និង/ឬ ទម្រង់កិច្ចព្រមព្រៀងស្តីពីការបែងចែកផលប្រយោជន៍ នឹងជួយធានាការប្រតិបត្តិក្នុងសហគមន៍ប្រកបដោយតម្លាភាព និងសមភាពក៏ដូចជាសម្រេចបានយ៉ាងពេញលេញនូវសក្តានុពលសេដ្ឋកិច្ច និងការអភិរក្ស។

## ៨. ការដោះស្រាយវិវាទ

អស់រយៈពេលជាយូរ វិវាទដីធ្លីបន្តជាបញ្ហាចម្បងនៅកម្ពុជា ដែលក្នុងនោះសហគមន៍តំបន់ការពារធម្មជាតិក៏មិនអាចចៀសរួចផងដែរ។ នៅពេលមានវិវាទ សហគមន៍តំបន់ការពារធម្មជាតិជាទូទៅស្ថិតក្នុងស្ថានភាពពុំមានប្រៀបឡើយ ដោយប្រឈមទៅនឹងភាគីក្រៅសហគមន៍ដែលមានការគាំទ្រផ្លូវការក្នុងការកាន់កាប់ដីវិវាទ ដូចជាកម្មសិទ្ធិដី កិច្ចព្រមព្រៀងសម្បទាន ឬការទាមទារប្រើប្រាស់ដោយមានការអនុញ្ញាត។ បើទោះបីជាបញ្ហាបន្តកើតមានក្តី យន្តការដោះស្រាយវិវាទ និងការណែនាំបន្តមានភាពមិនច្បាស់លាស់។ ការបង្កើតការណែនាំជាក់ច្បាស់ និងបទដ្ឋានប្រតិបត្តិក្នុងការដោះស្រាយវិវាទដោយបន្តនូវគោរពប្រពៃណី/ទំនៀមទម្លាប់ អាចជួយដោះស្រាយវិវាទ យ៉ាងមានប្រសិទ្ធភាពនៅពេលដែលមានវិវាទកើតមានឡើង។

## ៩. ការពង្រឹងការអនុវត្ត

ការអនុវត្តសកម្មភាពដែលទាក់ទងនឹង សហគមន៍តំបន់ការពារធម្មជាតិ អាចធ្វើឲ្យប្រសើរឡើងបាន។ ការអនុវត្តដោយតឹងរឹង និងការដាក់ទណ្ឌកម្មដើម្បីកុំឲ្យមានការប្រព្រឹត្តបទល្មើសកំពុងតែខ្វះខាត។ ការផ្តល់អំណាចដល់សហគមន៍តំបន់ការពារធម្មជាតិក្នុងការអនុវត្តដោយផ្ទាល់នូវវិន័យ និងច្បាប់ទាក់ទងនឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ក៏ដូចជាការធានាផ្គត់ផ្គង់ធនធាន និងសមត្ថភាពក្នុងការល្បាត និងអនុវត្ត អាចជួយពង្រឹងការអនុវត្តសំខាន់ៗ។

## ១០. ការគាំទ្រពីខាងក្រៅ

ការគាំទ្រពីខាងក្រៅ អាចមានសារៈសំខាន់ក្នុងការបង្កើត និងការប្រតិបត្តិសហគមន៍តំបន់ការពារធម្មជាតិដោយជោគជ័យ។ បើទោះបីជាអង្គការមិនមែនរដ្ឋាភិបាល នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុទៅសហគមន៍តំបន់ការពារធម្មជាតិក្តី ការសហការរវាងសហគមន៍តំបន់ការពារធម្មជាតិ និងវិស័យឯកជន រួមជាមួយនឹងការផ្តល់មូលនិធិគ្រប់គ្រាន់ពីរដ្ឋាភិបាល និងការកសាងសមត្ថភាពដល់សហគមន៍តំបន់ការពារធម្មជាតិ ជាការចាំបាច់ក្នុងការកាត់បន្ថយការពឹងអាស្រ័យលើធនធានសាធារណៈដែលមានកម្រិត និងធនធានរបស់វិស័យអង្គការមិនមែនរដ្ឋាភិបាល៕



# សេចក្ដីផ្ដើម

របាយការណ៍នេះគឺជាកិច្ចខិតខំប្រឹងប្រែងរួមរវាងក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយ និង ClientEarth ដែលជាអង្គការមិនមែនរដ្ឋាភិបាលប្រចាំនៅប្រទេសអង់គ្លេសធ្វើការទាក់ទងនឹងច្បាប់បរិស្ថានអន្តរជាតិ និងទទួលបានការគាំទ្រពីសាកលវិទ្យាល័យកូលុមប៊ី និងសាលាច្បាប់លូវីស និងក្លើករបស់សហរដ្ឋអាមេរិក។

ដោយផ្អែកលើបទពិសោធន៍នៃការអនុវត្តយ៉ាងទូលំទូលាយពីក្រសួងបរិស្ថាន សហគមន៍មូលដ្ឋាន និងការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល ការស្រាវជ្រាវនេះមានគោលបំណងធ្វើការវិភាគយ៉ាងទូលំទូលាយលើស្ថានភាពបច្ចុប្បន្នដែលមានការប៉ះពាល់ដល់សហគមន៍ការពារធម្មជាតិនៅកម្ពុជាដោយមើលទៅលើទាំងក្របខ័ណ្ឌច្បាប់ និងបទពិសោធន៍ជាក់ស្តែងរហូតមកដល់បច្ចុប្បន្ន។ របាយការណ៍នេះគឺជាលទ្ធផលរួមដែលបានមកពីការធ្វើការវិភាគឯកសារច្បាប់ ការធ្វើការរំលឹកទ្រឹស្តី ការសិក្សាករណីផ្សេងៗ និងការធ្វើបទសម្ភាសន៍ដោយផ្ទាល់ជាមួយសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា និងបទសម្ភាសន៍ជាមួយដៃគូពាក់ព័ន្ធជាច្រើនទៀត។ លទ្ធផលនៃការស្រាវជ្រាវនេះគឺជាសំណុំនៃអនុសាសន៍ណែនាំលម្អិតសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងនៃសហគមន៍តំបន់ការពារធម្មជាតិ ទាំងក្នុងរចនាសម្ព័ន្ធ និងមុខងារជាក់ស្តែង។

របាយការណ៍នេះត្រូវបានបែងចែកជា ១០ផ្នែកដែលបង្កើតចេញពីគំរូរបស់ ClientEarth[3] អំពីមូលដ្ឋានគ្រឹះសំខាន់ៗចំនួន ១០ នៃក្របខ័ណ្ឌច្បាប់ដែលគាំទ្រដល់ការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍ និងគឺជាតំណាងនៃបញ្ហាចំបងទាំង ១០ទាក់ទងនឹងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ការគ្រប់គ្រង និងការអនុវត្តបន្ត។ ផ្នែកនីមួយៗចាប់ផ្តើមពីនិយមន័យនៃបញ្ហាទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា។ បន្ទាប់មក ផ្នែកនីមួយៗមានផ្នែកដែលពន្យល់ពីស្ថានភាពបច្ចុប្បន្ននៃក្របខ័ណ្ឌច្បាប់ និងសក្តានុពលនៃចន្លោះប្រហោងដែលអាចកើតមានឡើងនៅក្នុងការអនុវត្តនាពេលបច្ចុប្បន្ន។ ជាចុងបញ្ចប់ ផ្នែកនីមួយៗមានផ្តល់ជាអនុសាសន៍ណែនាំពាក់ព័ន្ធនឹងការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃបញ្ហានីមួយៗ។

> របាយការណ៍នេះធ្វើឡើងក្នុងគោលបំណងប្រើប្រាស់ជាធនធានសម្រាប់ជម្រាបជាព័ត៌មាន ឬដំណឹងដល់អាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ អ្នកបង្កើតគោលនយោបាយ និងភាគីពាក់ព័ន្ធសំខាន់ៗនៅកម្ពុជា។ ក្នុងរបាយការណ៍នេះយើងក៏មានគោលបំណងផ្តល់ការណែនាំយ៉ាងទូលំទូលាយដល់ដៃគូដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់របស់សហគមន៍តំបន់ការពាធម្មជាតិគ្រប់សមត្ថភាពដូចជា ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល។ ទម្រង់នៃរបាយការណ៍នេះ ដែលបានធ្វើការវិភាគទៅលើបញ្ហានានារបស់សហគមន៍តំបន់ការពារធម្មជាតិស្របទៅតាមមូលដ្ឋានគ្រឹះចំនួន ១០ អនុញ្ញាតឲ្យអ្នកអានអាចយកទៅប្រើប្រាស់ជាឧបករណ៍យោងតាមតម្រូវការនៃប្រធានបទ។

របាយការណ៍នេះត្រូវបានរៀបចំឡើងនៅក្នុងអំឡុងពេលដែលមិនច្បាស់លាស់នៃជំងឺរាតត្បាតកូវីដ-១៩ កិច្ចការសិក្សានេះត្រូវបានជួបប្រទេះនឹងបញ្ហាប្រឈម និងចំណុចខ្វះខាតមួយចំនួន។ បញ្ហាប្រឈមសំខាន់បំផុតគឺទាក់ទងនឹងការលំបាកក្នុងការចុះធ្វើការងារមូលដ្ឋាន ជាពិសេសទាក់ទងនឹងជំនួបជាមួយសហគមន៍ និងការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន។ បន្ថែមពីនេះទៅទៀត ដើម្បីទប់ស្កាត់ជំងឺរាតត្បាតកូវីដ-១៩ ជំនួបដោយផ្ទាល់ជាមួយមន្ត្រីរាជការពាក់ព័ន្ធទាំងថ្នាក់តំបន់ និងថ្នាក់ជាតិត្រូវបានកម្រិត។ ជាលទ្ធផល ឥឡូវនេះយើងនឹងធ្វើបទបង្ហាញពីរបាយការណ៍នេះទៅភាគីពាក់ព័ន្ធ និងជាពិសេសទៅមន្ត្រីរាជការ ដើម្បីជាឧបករណ៍ក្នុងការចាប់ផ្តើមការពិភាក្សាពីចំណេះដឹង និងចែករំលែកបទពិសោធន៍ដែលនឹងអាចនាំឲ្យមានកំណែលម្អក្នុងការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិនាពេលអនាគត។

# សារតា

## តំបន់ការពារធម្មជាតិ និងគោលនយោបាយបរិស្ថាន

តំបន់ការពារធម្មជាតិមានសារៈសំខាន់ណាស់ក្នុងការអភិរក្សជីវៈចម្រុះ និងធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។[4] មុខងារទាំងនោះរួមមាន ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការបម្លែងមុខងារដី ហើយទាំងនេះត្រូវបានបង្ហាញឲ្យឃើញនៅក្នុងការសិក្សាស្រាវជ្រាវជាច្រើន។[5] ផ្ទុយពីនេះទៅវិញ ការសិក្សាស្រាវជ្រាវផ្សេងទៀតបានអះអាងថាការកើនឡើងនៃការបង្កើតតំបន់ការពារធម្មជាតិនាំឲ្យមានផលប៉ះពាល់ដោយផ្ទាល់ទៅលើសហគមន៍មូលដ្ឋានដែលជារឿយៗសហគមន៍ត្រូវបានបណ្តេញចេញពីដីប្រពៃណីរបស់ពួកគេ ដែលជាហេតុនាំឲ្យមានការកើនឡើងនៅវិវាទ និងការផ្តន្ទាទោសលើការប្រើប្រាស់ដីជាលក្ខណៈប្រពៃណី។[6] តំបន់ការពារធម្មជាតិក៏អាចងាយរងគ្រោះទៅនឹងការសឹករេចរិលជាទូទៅ ការទន្ទ្រានកាន់កាប់ដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគឯកជន និងការបរបាញ់សត្វខុសច្បាប់។[7] ខណៈពេលដែលនិន្នាការក្នុងការបង្កើតតំបន់ការពាធម្មជាតិមានការកើនឡើង ស្របពេលជាមួយគ្នានេះ វាក៏បង្ហាញឲ្យច្បាស់ថាវិធិសាស្តក្រ្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិដែលរិតបន្តឹង ដឹកនាំដោយរាជរដ្ឋាភិបាលពីលើចុះក្រោម មិនអាចបំពេញបាននូវគោលដៅអភិរក្ស។[8]

>40%

ផ្ទៃដីនៃប្រទេសកម្ពុជាត្រូវបានគ្របដណ្តប់ដោយ PAs

ចាប់ពីឆ្នាំ ១៩៩០មក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការខិតខំប្រឹងប្រែងក្នុងការរឹតបន្តឹងការការពារធនធានធម្មជាតិ និងទីជម្រកធម្មជាតិ។ ក្នុងឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យទាក់ទងនឹងការការពារតំបន់ធម្មជាតិបានទទួលស្គាល់តំបន់ការពារធម្មជាតិចំនួន ២៣។[9] តំបន់ការពារធម្មជាតិជាសរុបគ្របដណ្តប់ជាង ៤០ភាគរយនៃផ្ទៃដីរបស់ប្រទេសកម្ពុជានៅចុងឆ្នាំ ២០១៧។[10]

បច្ចុប្បន្ន តំបន់ការពារធម្មជាតិចំនួន ៥៣ត្រូវបានបង្កើតឡើង។ លើសពីនេះទៅទៀត តំបន់ការពារធម្មជាតិនីមួយៗត្រូវបានបែងចេកជា បួនតំបន់ផ្អែកទៅតាមលក្ខណៈសម្បត្តិធម្មជាតិ និងតម្រូវការនៃការអភិរក្សរួមមាន៖ តំបន់ស្នូល តំបន់អភិរក្ស តំបន់ចីរភាព និងតំបន់សហគមន៍។

តំបន់ស្នូល រួមមានប្រភេទសត្វទទួលរងការគម្រាមកំហែង និងជិតផុតពូច និងប្រព័ន្ធអេកូឡូជីដែលមានភាពផុយស្រួយ គឺជាតំបន់ដែលមានការការពារយ៉ាងខ្លាំង និងមានសិទ្ធិចូលប្រើប្រាស់មានកម្រិតបំផុត។ ការចូលប្រើប្រាស់ជាទូទៅត្រូវបានហាមឃាត់ លើកលែងតែការប្រើប្រាស់ដោយមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ( GDANCP ) និងអ្នកសិក្សាស្រាវជ្រាវដែលធ្វើការសិក្សាទៅលើបរិស្ថាន និងធនធានធម្មជាតិ ( ក្រោយពីពួកគេបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថាន )។[11]

តំបន់អភិរក្សគឺជាតំបន់ដែលមានតម្លៃអេកូឡូស៊ីខ្ពស់ និងស្ថិតនៅជាប់នឹងតំបន់ស្នូល និងមានតួនាទីជា"របាំង"។[12] ទោះបីជាវាមិនមានការការពារតឹងរឹងខ្លាំងដូចជាតំបន់ស្នូល ការប្រើប្រាស់តំបន់អភិរក្សត្រូវតែមានការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ មានការលើកលែងចំពោះការប្រើប្រាស់តាមបែបសហគមន៍កម្រិតតូចក្នុងការប្រើប្រាស់អនុផលព្រៃឈើ មិនមែនឈើដើម្បីទ្រទ្រង់ជីវភាពរបស់ជនជាតិភាគតិចក្នុងតំបន់ ប្រសិនបើការចូល និងប្រើប្រាស់មិននាំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើជីវៈចម្រុះ។[13] សកម្មភាពអេកូទេសចរណ៍ត្រូវបានអនុញ្ញាតប្រសិនបើវាត្រូវបានរកឃើញថាសកម្មភាពទាំងនោះបង្កផលប៉ះពាល់តិចតួចដល់ប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះ។[14]

តំបន់ប្រើប្រាស់ដោយចីរភាពមានការការពារអេកូឡូស៊ីតិចជាងតំបន់ស្នូល និងតំបន់អភិរក្ស។ តំបន់ប្រើប្រាស់ដោយចីរភាពផ្តល់អាទិភាពលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនិងលើការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។ ការចូលប្រើប្រាស់គឺត្រូវបានអនុញ្ញាតយ៉ាងទូលំទូលាយ ក៏ប៉ុន្តែមានការហាមឃាត់លើសកម្មភាពមួយចំនួន។[15] សហគមន៍តំបន់ការពារធម្មជាតិអាចនឹងបង្កើតឡើងនៅក្នុងតំបន់នេះ។[16]

តំបន់សហគមន៍គឺជាកន្លែងដែលមានសារៈសំខាន់តិចបំផុតលើការការពារប្រព័ន្ធអេកូឡូស៊ីក្នុងចំណោមតំបន់ទាំងបួន និងមានការផ្តល់អាទិភាពទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅក្នុងតំបន់។[17] តំបន់សហគមន៍គឺសម្រាប់តែការប្រើប្រាស់របស់ប្រជាជនក្នុងតំបន់មូលដ្ឋានតែមួយគត់។ ការប្រើប្រាស់ដែលក្រៅពីតំបន់មូលដ្ឋានត្រូវបានហាមឃាត់។[18] សហគមន៍តំបន់ការពារធម្មជាតិអាចនឹងបង្កើតនៅក្នុងតំបន់នេះ[19] ក៏ប៉ុន្តែវាមានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងលក្ខខណ្ឌទូទៅដែលបានចែងនៅក្នុងគោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិឆ្នាំ ២០១៧ ( ដែលហៅថាគោលការណ៍ណែនាំកំណត់តំបន់ ) ដែលបានចែងថាតំបន់សហគមន៍គួរដាក់កម្រិតលើតំបន់ដែលមានប្រជាជនតាំងទីលំនៅស្រាប់ ( ភូមិ ) និងផ្ទៃដីដាំដំណាំរបស់ពួកគេ ( ដូចជា៖ វាលស្រែ ចំការ និងវាលចំការ ) ដែលបានទទួលប័ណ្ណកម្មសិទ្ធិរួចហើយ។[20]

នៅក្នុងឆ្នាំ ១៩៩៩ ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃអនុសញ្ញាតំបន់ដីសើម ឬអនុសញ្ញារ៉ាមសារ ដែលជាលិទ្ធផលធ្វើឲ្យមានការបង្កើតនូវតំបន់ដីសើមចំនួនប្រាំបន្ថែមទៀត ក្នុងនាមជាតំបន់ការពាររ៉ាមសារ។[21] ក្នុងឆ្នាំ ២០០៨ ការចូលជាសមាជិកនេះត្រូវបានបន្តដោយការអនុម័តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលកំណត់ប្រភេទតំបន់ការពារជាប្រាំបី (៨) ប្រភេទ៖ តំបន់ឧទ្យានជាតិ   តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់យ៉ាងច្រើន តំបន់រ៉ាមសារ តំបន់ស្នូលនៃបបនីយជីវមណ្ឌល (ជាពិសេសបឹងទន្លេសាប) តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់ឧទ្យានជាតិសមុទ្រ ។[22] ក្នុងឆ្នាំ ២០១៧ ក្រសួងបរិស្ថានបានប្រកាសបង្កើតនូវ "របៀងអភិរក្សជីវចម្រុះ" ថ្មីៗ ដើម្បីភ្ជាប់តំបន់ការពារធម្មជាតិដែលកំពុងតែមាន ដែលលាតសន្ធឹងលើផ្ទៃដីប្រហែល ១.៥លានហិកតា។ ការបង្កើតក្រមបរិស្ថានថ្មីដែលគាំទ្រដោយក្រសួងបរិស្ថានស្ថិតនៅក្រោមដំណាក់កាលពិភាក្សាជាយូរឆ្នាំ ក៏ប៉ុន្តែពុំទាន់ឃើញមានការបញ្ជូនបន្តទៅរដ្ឋសភាដើម្បីអនុម័តឡើយ។

ទោះបីជាមានការខិតខំប្រឹងប្រែងពីរដ្ឋាភិបាលទាក់ទងនឹងការរៀបចំការអភិរក្សតាមបែបសហគមន៍ និងការអនុវត្តដោយការផាកពិន័យយ៉ាងតឹងរ៉ឹងលើការបំពានច្បាប់ស្តីពីតំបន់ការពារយ៉ាងណាក្តីក៏ធនធានធម្មជាតិនៅកម្ពុជានៅតែស្ថិតនៅក្រោមការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ។[23] នៅចន្លោះពីឆ្នាំ ២០១០ និង២០១៦ គម្របព្រៃឈើប្រចាំឆ្នាំនៅកម្ពុជាមានការថយចុះយ៉ាងខ្លាំងពី ៥៧.០៧% ទៅ៤៦.៨៦%នៃគម្របព្រៃឈើសរុប។[24] ការថយចុះនៃគម្របព្រៃឈើត្រូវបានគេកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំដោយសារតែការកើនឡើងនៃការកាប់ឈើខុសច្បាប់ ការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកផ្ទៃដីកសិកម្ម។ កត្តាជម្រុញសំខាន់ៗនៃការកាប់បំផ្លាញព្រៃឈើគឺបណ្តាលមកពីតម្រូវការខ្ពស់នៃការនាំចេញឈើទៅប្រទេសដទៃ ក៏ដូចជាផលិតកម្មកសិកម្មតាមរយៈសម្បទានដីសេដ្ឋកិច្ចទ្រង់ទ្រាយធំ (ELCs)។[25] នៅក្នុងបរិបទនេះហើយដែលដៃគូពាក់ព័ន្ធទាំងអស់រួមមានរដ្ឋាភិបាលជាតិ អាជ្ញាធរមូលដ្ឋាន សហគមន៍ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល គួរតែធ្វើការអភិរក្ស និងដាំដុះធនធានធម្មជាតិប្រកបដោយចីរភាព។

## សហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា៖ ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្នយន្តការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍នៅកម្ពុជាមានជាបីទម្រង់៖ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ។ ក្នុងឆ្នាំ ២០១៦ ការគ្រប់គ្រងព្រៃឈើក្នុងតំបន់ការពារធម្មជាតិត្រូវបានផ្ទេរពីក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ទៅក្រសួងបរិស្ថាន។ ផ្ទៃដីសរុបដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់ការពារធម្មជាតិបច្ចុប្បន្នស្មើនឹង ៧.៥លានហ.ត (ឬ៤១% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា)។[26]

**182**

CPAs ដែលបានបង្កើតឡើង គ្របដណ្តប់ ៣០៩,៤៦៣ ហិកតា

សហគមន៍តំបន់ការពារធម្មជាតិជាធម្មតាគ្របដណ្តប់គ្របដណ្តប់ចន្លោះរវាងពីមួយភូមិដល់៣ភូមិនិងមានផ្ទៃដីពី៥០០ ទៅ៨០០០ហិកតា។ បច្ចុប្បន្ន គ្រួសារចំនួន ៥៥,៤៤៦គ្រួសារជាផ្នែកមួយនៃសហគមន៍តំបន់ការពារធម្មជាតិទាំងនេះ។ សហគមន៍ជាធម្មតាជាអ្នកមានគំនិតផ្តួចផ្តើមបង្កើតសហគមន៍តំបន់ការពារធម្មជាតិដោយឆ្លងកាត់យន្តការកម្មវិធីផ្លូវច្បាប់ដែលបានចែងក្នុងប្រកាសស្តីពីគោលការណ៍ណែនាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧) (ដែលហៅកាត់ថា គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិ) ដោយនៅពេលខ្លះមានជំនួយពីរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល។  សហគមន៍តំបន់ការពារធម្មជាតិទទួលបានសិទ្ធិរយៈពេល ១៥ឆ្នាំក្នុងការគ្រប់គ្រងដីធ្លីរបស់សហគមន៍។ សិទ្ធិរបស់ពួកគេមិនអាចពង្រីកហួសព្រំដែនរបស់សហគមន៍តំបន់ការពារធម្មជាតិឡើយ។ យន្តការសហគមន៍តំបន់ការពារធម្មជាតិនេះមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវកិច្ចខិតខំប្រឹងប្រែងអភិរក្ស ព្រមទាំងលើកកម្ពស់ឱកាសកំណើនជីវភាពរបស់សហគមន៍។[27] វាក៏មានសក្តានុពលធ្វើជាក្របខ័ណ្ឌក្នុងការរៀបចំ និងទាក់ទាញសកម្មភាពវិនិយោគដូចជា៖ កសិកម្មប្រកបដោយចីរភាព និងអេកូទេសចរណ៍ ក៏ត្រូវទទួលបានការទទួលស្គាល់ពីក្រសួងបរិស្ថាន និងអង្គការមិនមែនរដ្ឋាភិបាល។ដោយពិចារណាពីការធ្វើឲ្យប្រសើរឡើងក្នុងការសម្របសម្រួលគោលដៅដែលបានចែងខាងលើស្តីពីការផ្តល់ឲ្យ សហគមន៍មានតួនាទីសកម្មជាងមុន កិច្ចពិភាក្សាទៅលើការពិនិត្យឡើងវិញនូវគោលការណ៍ណែនាំនៃសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានធ្វើឡើងរវាងក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធដទៃទៀត។

ការរិះគន់លើយន្តការបច្ចុប្បន្នរួមមាន៖ ការមានកម្រិតក្នុងការចូលប្រើប្រាស់ធនធានធម្មជាតិដោយប្រជាជនក្នុងតំបន់ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ ការអនុវត្តច្បាប់ដោយគ្មានប្រសិទ្ធភាព ភាពខ្សោយនៃការកាន់កាប់ដីធ្លី និងកង្វះខាតសិទ្ធិពិតប្រាកដក្នុងការគ្រប់គ្រង ការពារ និងចូលរួមក្នុងតំបន់ការពារធម្មជាតិ។[28]

# ១. ការកាន់កាប់ដីធ្លី

### និយមន័យ៖

សិទ្ធិកាន់កាប់ដីធ្លីអាចត្រូវបានយល់ថាជាបណ្តុំនៃសិទ្ធិជាក់លាក់មួយ ដែលអាចរួមបញ្ចូលដូចជា៖ សិទ្ធិចេញ-ចូល(ការចេញចូលដីធ្លី) សិទ្ធិប្រើប្រាស់ (ការប្រើប្រាស់ដី និងធនធានរបស់វា) សិទ្ធិក្នុងការអាស្រ័យផល(ការទាញយកធនធាន ឧទាហរណ៍៖ ការទាញផលធនធានពីដីធ្លី ដូចជាការប្រមូលទិន្នផលព្រៃឈើ ឬទិន្នផលមិនមែនព្រៃឈើ) សិទ្ធិគ្រប់គ្រង (អំណាចក្នុងការសម្រេចចិត្តទាក់ទងទៅនឹងការប្រើប្រាស់ដី) សិទ្ធិផ្តាច់មុខ(សិទ្ធិមិនឲ្យអ្នកខាងក្រៅចូល ឬប្រើប្រាស់ដី) សិទ្ធិក្នុងការចាត់ចែង(លទ្ធភាពក្នុងការជួល លក់ ឬផ្តល់សិទ្ធិដល់អ្នកដទៃទាក់ទងទៅនឹងដីធ្លី)។[29]

### ច្បាប់ទាក់ទងនឹងការកាន់កាប់ដីធ្លី៖

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) ច្បាប់ភូមិបាល (២០០១) ច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧)

### ភាគីពាក់ព័ន្ធ៖

ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរបរិស្ថានខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាឃុំ និងសហគមន៍មូលដ្ឋាន

### បរិបទទូទៅ៖

ក្របខ័ណ្ឌច្បាប់របស់កម្ពុជាបានទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច បើទោះជាបណ្តាច្បាប់ទាំងនោះមានការទទួលស្គាល់ចំណុចនេះខុសៗគ្នាក៏ដោយ។ ឧទាហរណ៍៖ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) បានចែងថា "រដ្ឋទទួលស្គាល់ និងធានាដល់ការប្រើប្រាស់ដីធ្លី អនុវត្តប្រពៃណី ទំនៀមទម្លាប់ ជំនឿ និងសាសនា ជូនសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិភាគតិចដែលកំពុងស្នាក់នៅលើ និងក្បែរ ឬក្នុងតំបន់ការពារធម្មជាតិ។" ទោះជាយ៉ាងណា ចំណុចនេះត្រូវបានកម្រិតនៅត្រឹមតំបន់មួយចំនួនប៉ុណ្ណោះនៃតំបន់ការពារធម្មជាតិ រួមមាន តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្ស (**សូមមើលផ្នែក "ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ " ដើម្បីព័ត៌មានបន្ថែមអំពីការបែងចែកតំបន់របស់តំបន់ការពារធម្មជាតិ។**)[30]

> "រដ្ឋទទួលស្គាល់ និងធានាដល់ការប្រើប្រាស់ដីធ្លី អនុវត្តប្រពៃណី ទំនៀមទម្លាប់ ជំនឿ និងសាសនា ជូនសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិភាគតិចដែលកំពុងស្នាក់នៅលើ និងក្បែរ ឬក្នុងតំបន់ការពារធម្មជាតិ។"

អភិក្រមនៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ មានភាពខ្វះខាតមួយចំនួន ដោយច្បាប់នេះបានទទួលស្គាល់តែសិទ្ធិកាន់កាប់ដីធ្លីដោយផ្នែករបស់សហគមន៍ជនជាតិភាគតិច។ អភិក្រមនេះមានលក្ខណៈផ្ទុយពីច្បាប់ស្តីពីដីធ្លី (២០០១) ដែលបានចែងពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពជូនដល់សហគមន៍ជនជាតិភាគតិចដែលស្របទៅនឹងលក្ខខណ្ឌជាធរមានមួយចំនួន។[31] អភិក្រមខុសៗគ្នាទាំងនេះ មិនត្រូវបានសម្របសម្រួលឲ្យមានលក្ខណៈតែមួយឡើយ។ ទិដ្ឋភាពបែបនេះ បានបង្កជាបច្ច័យបង្កភាពមិនច្បាស់លាស់ និងអាចបណ្តាលឲ្យសហគមន៍ជនជាតិភាគតិចមួយចំនួនទទួលបានលទ្ធភាពខុសគ្នាក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី អាស្រ័យលើតើដីធ្លីរបស់ពួកគេ ស្ថិតឬ មិនស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ។

យោងតាមក្របខ័ណ្ឌច្បាប់ជាធរមាន សហគមន៍តំបន់ការពារធម្មជាតិមានសិទ្ធិកាន់កាប់ដីធ្លីដោយផ្នែក ក្នុងនោះជាទូទៅពួកគេអាចមានសិទ្ធិចេញ-ចូល សិទ្ធិប្រើប្រាស់ដីធ្លី សិទ្ធិអាស្រ័យផលដីធ្លី និងសិទ្ធិគ្រប់គ្រងដីធ្លី។ ទោះជាយ៉ាងណា សហគមន៍តំបន់ការពារធម្មជាតិ មានការលំបាកក្នុងការអនុវត្តសិទ្ធិហាមប្រាមការធ្វើដំណើរចូលដីធ្លី និងសិទ្ធិលក់ ជួល ឬសម្បទានដីធ្លី ដែលទាំងនេះប៉ះពាល់សិទ្ធិកាន់កាប់ដីធ្លីទាំងមូលរបស់សហគមន៍តំបន់ការពារធម្មជាតិ។ បញ្ហាប្រឈមរួមមាន សហគមន៍តំបន់ការពារធម្មជាតិមិនមានលទ្ធភាពក្នុងការផ្តល់សិទ្ធិដល់ភាគីដទៃទៀតទាក់ទងនឹងការកាន់កាប់ដីធ្លីរបស់ពួកគេ។ ឧទាហរណ៍៖ សហគមន៍តំបន់ការពារធម្មជាតិ មិនអាចមានលទ្ធភាពផ្ទេរសិទ្ធិកាន់កាប់ដីធ្លីទៅសហគ្រាសឯកជនដែលមានបំណងវិនិយោគលើធុរកិច្ចចីរភាពលើដីរបស់សហគមន៍។បញ្ហានេះបង្កជាការប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍជីវភាពសហគមន៍តំបន់ការពារធម្មជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែអតុល្យភាពនៃអំណាចរវាងសហគមន៍ និងក្រុមហ៊ុនកើតមានឡើងជាញឹកញយ យន្តការជាក់លាក់មួយចំនួន គួរតែត្រូវបានដាក់បញ្ចូលដើម្បីធានា

ថាសហគមន៍ទទួលបានការការពារគ្រប់គ្រាន់ក្នុងនាមជាភាគីកិច្ចសន្យាដែលមានអំណាចខ្សោយជាង។ ឧទាហរណ៍នៃយន្តការទាំងនោះមានដូចជា៖ ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលទៅសហគមន៍ដើម្បីចរចារកិច្ចព្រមព្រៀង ឬការហាមឃាត់ការទំលាក់ការទទួលខុសត្រូវមកលើសហគមន៍ចំពោះការប្រព្រឹត្តខុសរបស់ភាគីទីបីនៅក្នុងការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ច។

បន្ថែមពីលើនេះ សិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច នៅតំបន់ការពារធម្មជាតិបច្ចុប្បន្នត្រូវឆ្លងកាត់នីតិវិធីមួយចំនួនផងដែរ។ នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០២០ សម្តេចនាយករដ្ឋមន្ត្រីបានដាក់ចេញបទបញ្ជាដល់ក្រសួងចំនួនបី រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក្នុងការផ្តល់ដីធ្លីស្ថិតក្នុងតំបន់ការពារធម្មជាតិជូនដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់នោះ។[32]

ព័ត៌មានលម្អិតស្តីពីការអនុវត្តបទបញ្ជានេះ មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយ។ បើតាមប្រភពក្រៅផ្លូវការ នីតិវិធីដែលរដ្ឋាភិបាលនឹងធ្វើបន្ទាប់ គឺបញ្ជាឲ្យរដ្ឋបាលខេត្ត បង្កើតក្រុមការងារមួយចំនួនទទួលបន្ទុកស្វែងរកទិន្នន័យរួមអំពីទីតាំង និងចំនួនគ្រួសារដែលកំពុងរស់នៅក្នុង និងនៅជិតតំបន់ការពារធម្មជាតិ។ ផ្អែកលើទិន្នន័យដែលទទួលបាន ក្រុមការងារទាំងនេះនឹងធ្វើការវាយតម្លៃស្នើយោបល់ជូនរដ្ឋាភិបាលថា ក្នុងចំណោមក្រសួងទាំងបីខាងលើ តើក្រសួងមួយណាដែលត្រូវទទួលបន្ទុកអនុវត្តបទបញ្ជាសម្តេចនាយករដ្ឋមន្ត្រី។ បន្ទាប់មក ក្រសួងពាក់ព័ន្ធនីមួយៗនឹងផ្តល់ការគាំទ្រ សម្របសម្រួលមួយចំនួនក្នុងការផ្តល់ដីធ្លីជូនគ្រួសារដែលត្រូវទទួលបាន។[33]

នីតិវិធីនេះមិនមែនជាក្របខ័ណ្ឌច្បាប់ថ្មីនោះទេ។ តាមពិតទៅ រាល់ការបែងចែកដីធ្លីទាំងអស់ត្រូវបានធ្វើឡើងស្របតាមច្បាប់ជាធរមាននាពេលបច្ចុប្បន្ន។ ដូច្នេះ យើងមិនទាន់ដឹងទេថា ការបែងចែកដីធ្លីខាងលើនឹងត្រូវបានធ្វើឡើងក្នុងទម្រង់ណាមួយឡើយ។ ក្រសួងបរិស្ថានអាចនឹងជ្រើសរើសប្រើប្រាស់យន្តការសហគមន៍តំបន់ការពារធម្មជាតិ ធ្វើជាមធ្យោបាយយ៉ាងសំខាន់ក្នុងការអនុវត្តបទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី។ ការណ៍នេះ តម្រូវឲ្យក្រសួងបរិស្ថានធ្វើការកែសម្រួលនីតិវិធីស្តីពីការកាន់កាប់ដីធ្លីក្នុងក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីឆ្លើយតបទៅនឹងស្តង់ដាកំណត់ដោយបទបញ្ជាដែលដាក់ចេញដោយសម្តេចនាយករដ្ឋមន្ត្រី។

ការព្រួយបារម្ភមួយដែលកំពុងកើនឡើងពាក់ព័ន្ធនឹងការអនុវត្តបទបញ្ជាដែលដាក់ចេញដោយសម្តេចនាយករដ្ឋមន្ត្រីនេះ គឺពាក់ព័ន្ធនឹងកង្វះខាតនៃតម្លាភាពក្នុងការអនុវត្ត និងនៅក្នុងករណីមួយចំនួន បទបញ្ជានេះបានរាប់បញ្ចូលទាំងដីទន្ទ្រានដោយអ្នកមានអំណាយមួយចំនួនតូច។ ករណីនេះបានបង្កជាបញ្ហានៅក្នុងតំបន់ និងការប្រញាប់ប្រញាល់ក្នុងការទិញដីក្នុងតំបន់ ដែលជាលទ្ធផលធ្វើឲ្យជនឯកជនដែលមានអំណាចទទួលបានដីដែលគួរតែជាដីដែលត្រូវផ្តល់ឲ្យសហគមន៍ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ។[34]

## ចន្លោះប្រហោងផ្លូវច្បាប់៖

### បញ្ហារវាង កម្មសិទ្ធិដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លី

ក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិបានផ្តល់ជូនសហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិចនូវភាពស្របច្បាប់មួយចំនួន ដូចជាការផ្តល់ការការពារ និងធានានូវសិទ្ធិប្រពៃណីក្នុងការកាន់កាប់ដីធ្លីរបស់ពួកគេ ដូចដែលបានរៀបរាប់ជូនខាងលើ (ប៉ុន្តែអភិក្រមនេះ ត្រូវបានកម្រិតស្ថិតនៅក្នុងព្រំដីដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ)។ កត្តានេះបណ្តាលឲ្យមានភាពមិនប្រាកដប្រជាទាក់ទងនឹងបញ្ហាកម្មសិទ្ធិដីធ្លី ពីព្រោះរាល់ដីធ្លីទាំងអស់ដែលត្រូវបានបែងចែកជូននៅក្រោមក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ គឺស្ថិតក្រោមការគ្រប់គ្រងបណ្តោះអាសន្នដោយសហគមន៍ ប៉ុន្តែដីទាំងនោះនៅតែស្ថិតនៅជាដីរដ្ឋដដែល។[35] ដូចបានរៀបរាប់ជូនខាងលើ នៅក្រៅក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ជនជាតិភាគតិចអាចមានលទ្ធភាពក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លីរួម តាមរយៈប័ណ្ណកម្មសិទ្ធិដីធ្លីដូចមានចែងក្នុងច្បាប់ស្តីពីដីធ្លី[36] បើទោះជានីតិវិធីនៃការទទួលបានប័ណ្ណកម្មសិទ្ធិមានលក្ខណៈយូរ និងស្មុគស្មាញក៏ដោយ។

### ការបញ្ជាក់អំពីសិទ្ធិកាន់កាប់ដីធ្លី

សុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីក្រោមក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ មានភាពទន់ខ្សោយ ដោយសាររដ្ឋមានសិទ្ធិអំណាចក្នុងការដកហូតដីសហគមន៍នាពេលណាក៏បាន ក្រោមហេតុផលថាដីសហគមន៍តំបន់ការពារធម្មជាតិ"ផ្តល់ប្រយោជន៍សង្គម និងសាធារណៈជាជាងការធ្វើឲ្យដីនោះស្ថិតនៅជាសហគមន៍តំបន់ការពារធម្មជាតិ។"[37] ដូច្នេះហើយ អគ្គនាយកដ្ឋាននៃសហគមន៍មូលដ្ឋាន មានតួនាទីផ្តល់ជូនសហគមន៍តំបន់ការពារធម្មជាតិនូវលិខិតជាលាយលក្ខណ៍អក្សរ យ៉ាងតិចចំនួន ៦ខែ មុនពេលដកហូតដីសហគមន៍។ លើសពីនេះ សហគមន៍តំបន់ការពារធម្មជាតិក៏នឹងទទួលបាននូវអត្ថប្រយោជន៍មួយចំនួនដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ណាមួយនៅលើដីសហគមន៍។ ពាក្យដែលតែងលើកឡើងថា "ប្រយោជន៍សង្គម និងសាធារណៈ" មិនត្រូវបានបកស្រាយឲ្យបានលម្អិត និងច្បាស់លាស់ឡើយ ហើយក៏មិនដែលមានការប្រៀបធៀបច្បាស់លាស់ណាមួយរវាង "ប្រយោជន៍សង្គម និងសាធារណៈ" ជាមួយនឹងប្រយោជន៍សហគមន៍តំបន់ការពារធម្មជាតិនោះទេ។ បន្ថែមពីលើនេះ រដ្ឋក៏មិនទាន់មានការបញ្ជាក់ច្បាស់អំពី"អត្ថប្រយោជន៍ និងសំណង"ដែលរដ្ឋត្រូវផ្តល់ជាសំណងជូនសហគមន៍តំបន់ការពារធម្មជាតិ នាពេលមានការដកហូតដីសហគមន៍ដើម្បីអភិវឌ្ឍន៍។ ដូច្នេះ របៀបអនុវត្តបទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី គឺនៅមានភាពមិនច្បាស់លាស់នៅឡើយ។[38]

ចំណុចសំខាន់មួយទៀតគឺ ច្បាប់កម្ពុជាស្តីពីសហគមន៍តំបន់ការពារធម្មជាតិ មិនបានផ្តល់ដោយគោលការណ៍សេរី ជាមុន និងការយល់ព្រមដែលទទួលបានព័ត៌មាន (គោលការណ៍អេហ្វពិក) ជូនដល់ជនជាតិភាគតិច និងសហគមន៍មូលដ្ឋានឡើយ ទាក់ទងនឹងបញ្ហាមួយចំនួននៃយន្តការសហគមន៍តំបន់ការពារធម្មជាតិរួមមាន ការបែងចែកដីធ្លី ការដកហូតដីធ្លី ការផ្តល់ជាថ្មីនូវសិទ្ធិកាន់កាប់ដីធ្លី ការកែសម្រួលការកាន់កាប់ដីធ្លីជាដើម ក៏ដូចជាមិនបានបញ្ជាក់ពីសំណាងដែលសហគមន៍មូលដ្ឋានត្រូវបានទទួលបាន ប្រសិនជាជួបប្រទះនឹងបញ្ហាអវិជ្ជមានផ្សេងៗ ដែលបង្កឡើងដោយការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ ការបញ្ចូលវិធានការមួយចំនួនដូចជា ការដាក់លក្ខខណ្ឌនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ នឹងផ្តល់នូវការគាំពារប្រកបដោយបរិយាប័ន្នជូនសហគមន៍ជនជាតិភាគតិច ក៏ដូចជាផ្តល់សហគមន៍មូលដ្ឋាននូវសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ។

## រយៈពេល និងការផ្តល់ជាថ្មីនៃសិទ្ធិកាន់កាប់ដីធ្លី

សិទ្ធិកាន់កាប់ដីធ្លីដែលផ្តល់ក្រោមក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ មានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ។ សហគមន៍មូលដ្ឋានត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរយៈពេលតែ ១៥ ឆ្នាំប៉ុណ្ណោះ។ រយៈពេលពេលនេះ អាចត្រូវបានបន្ថែមជូនទៀត តែមិនអាចធានាជូនសហគមន៍មូលដ្ឋានថានឹងបន្ថែមពេលវេលាកាន់កាប់ឲ្យពួកគេនោះឡើយ។[39]

រយៈពេលនៃការផ្តល់សិទ្ធិគ្រប់គ្រងជូនសហគមន៍មូលដ្ឋានត្រូវបានមជ្ឈដ្ឋាននៅកម្ពុជាក៏ដូចជាបណ្តាប្រទេសដទៃទៀតរិះគន់ថាមិនមានភាពគ្រប់គ្រាន់ក្នុងការធានាឲ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ឲ្យមានភាពរីកចម្រើនប្រកបដោយចីរភាពឡើយ។ បញ្ហាមួយទៀតគឺនៅត្រង់នីតិវិធីក្នុងការបង្កើត សហគមន៍តំបន់ការពារធម្មជាតិ។ បើទោះជារយៈពេល១៥ឆ្នាំនៃការគ្រប់គ្រងរបស់សហគមន៍ត្រូវបានចាប់ផ្តើម ចាប់តាំងពីកិច្ចព្រមព្រៀងនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិចូលជាធរមានក្តីតាមការពិតជាក់ស្តែង សមាជិកសហគមន៍ត្រូវការពេលជាច្រើនឆ្នាំបន្ថែមទៀតដើម្បីយល់ដឹងនិងអនុវត្តទៅតាមផែនការគ្រប់គ្រងលក្ខន្តិកៈ ក៏ដូចជាបទបញ្ជាផ្សេងៗទាក់ទង នឹងសហគមន៍តំបន់ការពារធម្មជាតិ។[40]

ផ្ទុយទៅវិញ ការផ្តល់ជូនសហគមន៍មូលដ្ឋាននូវសិទ្ធិកាន់កាប់ដីធ្លីយូរអង្វែងនឹងចូលរួមចំណែកដល់ការគ្រប់គ្រង អភិរក្សសហគមន៍។[41] ជាទូទៅដើម្បីមានប្រសិទ្ធភាពកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍ត្រូវមានសុពលភាពយ៉ាង តិច ៣០ ឆ្នាំ ។[42]

បើទោះជា ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិបានចែងអំពីការផ្តល់ជាថ្មីនូវសិទ្ធិកាន់ដីធ្លីជូនសហគមន៍មូលដ្ឋានក៏ដោយ ក៏ប៉ុន្តែក្របខ័ណ្ឌដដែលមិនបានចែងឲ្យបានច្បាស់លាស់ថាតើការផ្តល់ជាថ្មីនោះតើ រដ្ឋសំអាងលើគោលការណ៍ឬលក្ខខណ្ឌណាខ្លះ។[43] បច្ច័យនេះបង្កជាការព្រួយបារម្ភដល់សហគមន៍មូលដ្ឋានខណៈ ពេលដែលកម្ពុជាកំពុងទទួលយកនូវការអភិវឌ្ឍដ៏លឿននិងឆាប់រហ័សនាពេលបច្ចុប្បន្ន។[44] ឧទាហរណ៍៖ សហគមន៍មូលដ្ឋានមួយនៅខេត្តរតនគិរីបានសម្តែងការព្រួយបារម្ភនូវលទ្ធភាពដែលរដ្ឋអាចនឹងមិនផ្តល់ជាថ្មីនូវកិច្ចព្រមព្រៀងដើម្បីបន្តគ្រប់គ្រងដីសហគមន៍ដោយសារដីសហគមន៍របស់ពួកគេទទួលបានចាប់អារម្មណ៍ចង់បានពីសំណាក់វិស័យឯកជន។[45]

## ការបែងចែកសារជាថ្មីនូវសម្បទានដីសេដ្ឋកិច្ចដែលមិនត្រូវបានប្រើប្រាស់

សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ត្រូវដាក់ពាក្យសុំសិទ្ធិកាន់កាប់ដីធ្លី ដែលពួកគេកំពុងនៅ និងប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត។ ទោះជាយ៉ាងណា តាមរយៈការដាក់ពាក្យស្នើសុំសហគមន៍បានទទួលដំណឹងថា ដីទាំងនោះត្រូវបានផ្តល់ជូនជាសម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជនរួចបាត់ទៅហើយដែលមានសុពលភាពដល់ទៅ ៥០ ឆ្នាំ។ ក្នុងករណីជាច្រើន ក្រុមហ៊ុនឯកជនដែលទទួលបានសម្បទានដីសេដ្ឋកិច្ច មិនបានប្រើប្រាស់ដីទាំងនោះឡើយ។ ក៏ប៉ុន្តែ នីតិវិធីក្នុងការបង្វែរពីសម្បទានដីសេដ្ឋកិច្ចទៅជាដីសហគមន៍តំបន់ ការពារធម្មជាតិត្រូវការរយៈពេលយ៉ាងតិចពី ២ ទៅ ៣ ឆ្នាំ ហើយត្រូវពាក់ព័ន្ធនឹងក្រសួងជាច្រើន បន្ថែមពីក្រសួងបរិស្ថាន។ឧទាហរណ៍៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់គឺជាស្ថាប័នដែលទទួល បន្ទុកទទួលបណ្តឹងស្តីពីសម្បទានដីសេដ្ឋកិច្ចមិនត្រូវបានប្រើប្រាស់។[46] ការបង្កើនតម្លាភាពលើសម្បទានដីសេដ្ឋកិច្ចជាទូទៅ (ឧទាហរណ៍៖ ការផ្តល់នីតិវិធីនៃការបង្វែរពីសម្បទានដីសេដ្ឋកិច្ចទៅជាដីសហគមន៍មានភាពច្បាស់លាស់ និងកាត់បន្ថយជាងនេះបញ្ហានេះនឹងត្រូវបានដោះស្រាយឆាប់រហ័សជាងនេះ។ ការបង្វែរសម្បទានដីសេដ្ឋកិច្ចដែលមិនត្រូវបានប្រើប្រាស់ បង្វែរទៅជាដីសហគមន៍នឹងជួយឲ្យមានការដាំដុះព្រៃឈើឡើងវិញ និងជួយលើកកម្ពស់ជីវភាពសហគមន៍។[47]

## បញ្ហាមួយចំនួនកើតចេញពីការអនុវត្តៈ

### កង្វះឱកាសសេដ្ឋកិច្ច

នាពេលបច្ចុប្បន្ន សកម្មភាពសេដ្ឋកិច្ចទាំងឡាយត្រូវបានអនុញ្ញាតនៅតាមតែតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដោយមិនរាប់បញ្ចូល តំបន់ស្នូល និងតំបន់អភិរក្សឡើយ។ បញ្ហានេះត្រូវបានមើលឃើញថា បានរាំងខ្ទប់ឱកាសសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋានក្នុងកិច្ចការសេដ្ឋកិច្ចមួយចំនួន ដូចជាធុរកិច្ចអេកូទេសចរណ៍ខ្នាតតូច។ បន្ថែមពីលើនេះ ក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ មានភាពរឹតត្បិតខ្លាំងពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច។ ចំណុចនេះគួរត្រូវបានកែតម្រូវ ដោយសម្រួលឲ្យសហគមន៍មានលទ្ធភាពប្រើប្រាស់ឲ្យអស់លទ្ធភាពក្នុងការប្រើប្រាស់ដីសហគមន៍ដើម្បីលើកកម្ពស់ជីវភាពរបស់ពួកគេ។ ទិសដៅដែលរដ្ឋគួរធ្វើ គឺផ្តល់ជូនសហគមន៍មូលដ្ឋាននូវសិទ្ធិកាន់កាប់ដីសហគមន៍រយៈពេលយ៉ាងតិច ៣០ឆ្នាំ ដើម្បីឲ្យពលរដ្ឋក្នុងសហគមន៍មានលទ្ធភាពក្នុងការបង្កើតផែនការធុរកិច្ច និងដាក់ចេញនូវយុទ្ធសាស្ត្រផ្សេងៗក្នុងការទាក់ទាញការវិនិយោគមកសហគមន៍ ដើម្បីលើកកម្ពស់ជីវភាពពលរដ្ឋក្នុងសហគមន៍។

កាលពីឆ្នាំ ២០១៧ រាជរដ្ឋាភិបាល បានចាប់ផ្តើមនីតិវិធីក្រៅផ្លូវការ ក្នុងការបើកឲ្យមានសកម្មភាពសេដ្ឋកិច្ចអេកូទេសចរណ៍នៅលើដីចំនួន ១០ ហិចតា នៃតំបន់ការពារធម្មជាតិ។ នេះគឺជាវិធីមួយដែលបើកផ្លូវឲ្យប្រជាពលរដ្ឋក្នុងសហគមន៍មានលទ្ធភាពក្នុងការអាស្រ័យផលពីសហគមន៍របស់ពួកគេដើម្បីលើកកម្ពស់ជីវភាព ក៏ដូចជាជួយដល់កិច្ចការទ្រទ្រង់សកម្មភាពអភិរក្សសហគមន៍ផងដែរ។[48] ទោះជាយ៉ាងណា រដ្ឋគួរគិតគូរអំពីយុទ្ធសាស្ត្រ និងគោលនយោបាយឲ្យបានច្បាស់លាស់ជាងនេះ ដើម្បីធានាឲ្យបានថារាល់សកម្មភាពសេដ្ឋកិច្ចដែលត្រូវបានប្រព្រឹត្តឡើងនៅតំបន់សហគមន៍ គឺអាចផ្តល់ប្រយោជន៍ជូនដល់ពលរដ្ឋសហគមន៍បាន។ បើមិនដូច្នេះទេ ក្រុមហ៊ុនឯកជនទៅវិញទេ ដែលទទួលបានផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ចទាំងនេះ មិនមែនសហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិចនោះឡើយ។

### បញ្ហាទំនាក់ទំនងរដ្ឋបាលរវាងអាជ្ញាធរខេត្ត និងថ្នាក់ជាតិ

ករណីសហគមន៍មូលដ្ឋាននៅខេត្តរតនៈគីរីបានបង្ហាញយ៉ាងច្បាស់អំពីបញ្ហាមិនមានទំនាក់ទំនងនឹងគ្នា រវាងកំរិតរដ្ឋបាលតំបន់នៃតំបន់ការពារធម្មជាតិដោយថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ នៅឆ្នាំ ១៩៩៧ អាជ្ញាធរខេត្តរតនៈគីរីបានបង្កើតកិច្ចព្រមព្រៀងក្រៅផ្លូវការពិសេសមួយរយៈពេល ២៥ឆ្នាំជាមួយសហគមន៍មូលដ្ឋាន ដើម្បីឲ្យសហគមន៍មូលដ្ឋានមានសិទ្ធិគ្រប់គ្រងធនធានធម្មជាតិបានច្រើនជាងមុន។ កិច្ចព្រមព្រៀងនេះមិនបានធ្វើឡើងស្របទៅតាមដំណើរការផ្លូវការជាមួយអាជ្ញាធរថ្នាក់ជាតិឡើយ ដែលធ្វើឲ្យមានការចោទជាបញ្ហាខាងផ្លូវច្បាប់។ អាជ្ញាធរថ្នាក់ខេត្តបានព្យាយាមបញ្ចប់កិច្ចព្រមព្រៀងនេះមុនការកំណត់ ២៥ឆ្នាំ ដើម្បីពួកគេអាចចុះកិច្ចព្រមព្រៀងថ្មីរយៈពេល ៧៥ឆ្នាំជាមួយអ្នកវិនិយោគចិន។ ការណ៍នេះត្រូវបានបញ្ឈប់ដោយមានការអន្តរាគមន៍ដោយផ្ទាល់ពីសម្តេចនាយករដ្ឋមន្ត្រី នៅពេលដែលសហគមន៍ចាប់ផ្តើមដំណើរការស្នើសុំសិទ្ធិកាន់កាប់សហគមន៍ព្រៃឈើជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រោយមក ការស្នើសុំសិទ្ធិនេះត្រូវបានផ្ទេរទៅក្រសួងបរិស្ថាន និងផ្លាស់ប្តូរជាការស្នើសុំសិទ្ធិកាន់កាប់សហគមន៍តំបន់ការពារធម្មជាតិវិញ។[49]

### ទំនោរចង់ទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព ជាជាងដីសហគមន៍តំបន់ការពារធម្មជាតិ ដោយសារសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លី

ដូចបានរៀបរាប់ខាងលើ ជម្រើសមួយផ្សេងពីដីសហគមន៍តំបន់ការពារធម្មជាតិ គឺការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព អនុលោមតាមច្បាប់ស្តីពីដីធ្លី ដែលបានផ្តល់សិទ្ធិក្នុងការកាន់កាប់ដីធ្លីជូនសហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិចជាង ដីសហគមន៍តំបន់ការពារធម្មជាតិ។ បើទោះជានីតិវិធីក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាពត្រូវការរយៈពេលយូរ ស្មុគស្មាញ ហើយទំហំដីដែលទទួលបានមានទំហំតូចក៏ដោយ ក៏ពលរដ្ឋសហគមន៍មានទំនោរចង់បានកម្មសិទ្ធិដីសមូហភាព ដោយសារតែវិធីនេះធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី និងសិទ្ធិផ្តាច់មុខរបស់សហគមន៍ទៅលើដីសមូហភាព។ ឧទាហរណ៍នៃសុវត្ថិភាពនៃការកាន់កាប់ដីសមូហភាពត្រូវបានសបង្ហាញនៅពេលដែលដីសមូហភាព ជាន់ជាមួយដីតំបន់ការពារធម្មជាតិ។ នៅក្នុងករណីនេះ រាជរដ្ឋាភិបាលតែងតែសម្រេចថាដីវិវាទជាកម្មសិទ្ធិរបស់សហគមន៍នៅក្រោមដីសមូហភាព ក្រោយពេលដែលបានធ្វើការវាយតម្លៃលើប្រវត្តិនៃការប្រើប្រាស់ដីរបស់សហគមន៍។[50] ផ្ទុយពីនេះទៅវិញ ពេលមានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនឯកជន សហគមន៍តំបន់ការពារធម្មជាតិច្រើនតែចាញ់ប្រៀបខាងក្រុមហ៊ុន។

មួយរយៈពេលចុងក្រោយនេះ ការវាតទីលើដីសហគមន៍តំបន់ការពារធម្មជាតិមានការកើនឡើង ដោយអ្នកវាតទីដីនោះលើកសំអាងអំពីប្រវត្តិនៃការប្រើប្រាស់ដីរបស់គេពីអតីតកាល។ អនុវត្តតាមសារាចរណ៍លេខ ៦ ដែលទើបតែចេញថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារពិសេស និងនីតិវិធីមួយចំនួនដើម្បីពិនិត្យការទាមទារសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ រាប់បញ្ចូលទាំងដីធ្លីក្នុងតំបន់ការពារធម្មជាតិផងដែរ។ ក្រុមការងារពិសេស និងនីតិវិធីទាំងនេះ គឺជាវិធីមួយក្នុងការជួយសម្រួលឲ្យមានភាពច្បាស់លាស់នៃសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍តំបន់ការពារធម្មជាតិមួយចំនួន ក៏ដូចជាអាចជួយធានាឲ្យសិទ្ធិកាន់កាប់ដីសហគមន៍តំបន់ការពារធម្មជាតិឲ្យមានសុវត្ថិភាពជាងមុន។[51]

## អនុសាសន៍ណែនាំ៖

i. ពង្រីកសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍តំបន់ការពារធម្មជាតិ។ ឧទាហរណ៍៖ ក្រមខណ្ឌច្បាប់ សហគមន៍តំបន់ការពារធម្មជាតិ គួរបញ្ជាក់ឲ្យច្បាស់ៗអំពីសិទ្ធិបន្ថែមក្នុងការកាន់កាប់ដីធ្លីរបស់សហគមន៍ រួមមានសិទ្ធិក្នុងការហាមឃាត់អ្នកដទៃមិនឲ្យចូលដីពួកគេ។

ii. បន្ថែមរយៈពេលកាន់កាប់ដីធ្លីរបស់សហគមន៍តំបន់ការពារធម្មជាតិ យ៉ាងតិច ៣០ ឆ្នាំ។

iii. ចុះបញ្ជីជាផ្លូវការនៃសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍តំបន់ការពារធម្មជាតិ (មើល ផ្នែក យន្តការដោះស្រាយវិវាទ)។

iv. បញ្ជាក់ឲ្យបានច្បាស់អំពី "អត្ថប្រយោជន៍សង្គម និងសាធារណៈ" ក្នុងក្របខ័ណ្ឌគតិយុត្តិ, អនុញ្ញាតឲ្យភាពាក់ព័ន្ធចូលរួមក្នុងការវាយតម្លៃថាតើ "អត្ថប្រយោជន៍សង្គម និងសាធារណៈ" ច្រើនជាងអត្ថប្រយោជន៍ដែលកើតចេញពីសហគមន៍តំបន់ការពារធម្មជាតិ ឬមួយយ៉ាងណា បញ្ជាក់ឲ្យបានច្បាស់ពីនីតិវិធីនៃការប្រៀបធៀបអត្ថប្រយោជន៍សង្គម និងសាធារណៈ និងអត្ថប្រយោជន៍ដែលកើតចេញពីសហគមន៍តំបន់ការពារធម្មជាតិដើម្បីឲ្យមានភាពចុះសម្រុងក្នុងការអនុវត្តច្បាប់។

v. ធានាឲ្យបានថាសហគមន៍តំបន់ការពារធម្មជាតិទទួលបានសំណងសមរម្យមុនពេលដកហូតដីធ្លី ដោចេញគោលការណ៍ណែនាំស្ដីពីសំណង ថាតើសំណងត្រូវបានផ្ដល់ជូនសហគមន៍ដោយរបៀបណា ជាប្រភេទអ្វី ទំហំប៉ុណ្ណា និងពេលណាជាដើម។

vi. ដើម្បីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ត្រូវផ្ដល់គោលការណ៍អេហ្វពិកជូនដល់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិច ហើយត្រូវមានតាក់តែងគោលការណ៍ណែនាំពីការបំពេញគោលការណ៍អេហ្វពិក នៅក្នុងដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។

vii. កែសម្រួល និងពន្លឿននីតិវិធីឲ្យសហគមន៍បង្វែរសម្បទានដីសេដ្ឋកិច្ចដែលមិនត្រូវបានប្រើប្រាស់ និបង្កើត ដំណើរការក្នុងការកែប្រែសម្បទានដីសេដ្ឋកិច្ចដែលមិនបានប្រើប្រាស់ ឬបោះបង់ចោល ឬត្រូវបានលុបចោលទៅជាដីសហគមន៍តំបន់ការពារធម្មជាតិ។

viii. ផ្ដល់គោលការណ៍ច្បាប់មួយចំនួន ស្ដីពីការផ្ដល់ជាថ្មីនៃសិទ្ធិកាន់កាប់ដីសហគមន៍តំបន់ការពារធម្មជាតិ ដូចជា រយៈពេលនៃសិទ្ធិកាន់កាប់ដីថ្មី លក្ខណៈវិនិច្ឆ័យក្នុងការទទួលបានសិទ្ធិកាន់កាប់ដីជាថ្មី រយៈពេលនៃការសម្រេចចិត្ត និងលទ្ធផលនៃការសម្រេចចិត្តប្រសិនបើពុំបានការឆ្លើយតបទាក់ទងនឹងសំណើសុំសិទ្ធិកាន់កាប់ដីធ្លីបន្ត ។ល។ (ឧទាហរណ៍៖ ច្បាប់ស្ដីពីសហគមន៍ព្រៃឈើលើការបន្តសិទ្ធិកាន់កាប់ដីធ្លីអាចផ្ដល់ការណែនាំមួយចំនួន[52])។



# ២. ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

## និយមន័យ៖

ក្នុងបរិបទកម្ពុជា ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិត្រូវបានផ្តួចផ្តើមឡើងដោយសហគមន៍មូលដ្ឋាន រដ្ឋាភិបាល ដៃគូអភិវឌ្ឍ និង/ឬក៏អង្គការមិនមែនរដ្ឋាភិបាល។ សហគមន៍តំបន់ការពារធម្មជាតិអាចត្រូវបានបង្កើតឡើងនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ។ នីតិវិធីក្នុងការបង្កើតត្រូវមានច្រើនដំណាក់កាល ហើយសម្រេចចុងក្រោយជាផ្លូវការដោយក្រសួងបរិស្ថាន។.

## ច្បាប់ទាក់ទងនឹងការកាន់កាប់ដីធ្លី៖

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧) គោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ។

## ភាគីពាក់ព័ន្ធ៖

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាឃុំ សហគមន៍មូលដ្ឋាន និងដៃគូ

## បរិបទទូទៅ៖

ក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ បានចែងថា ដីសហគមន៍តំបន់ការពារធម្មជាតិអាចត្រូវបានបែងចែកជូនសហគមន៍ដែលរស់នៅក្នុង និងជិតតំបន់ការពារធម្មជាតិ។[53] ពាក្យថា "សហគមន៍" សំដៅទៅលើ "ក្រុមអ្នកភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានចំណាប់អារម្មណ៍ចំពោះបញ្ហាសង្គម បរិស្ថាន ប្រពៃណី និងសេដ្ឋកិច្ច ព្រមទាំងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព នៅក្នុង ឬនៅជិតតំបន់ដែលពួកគេកំពុងរស់ ក្នុងគោលបំណងចិញ្ចឹមជីវិត និងលើកកម្ពស់ជីវភាពរស់នៅ។"[54]

ក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ ក៏បានបញ្ជាក់អំពីទីតាំងនៃសហគមន៍ផងដែរ។ សហគមន៍តំបន់ការពារធម្មជាតិស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ហើយនៅក្នុងតំបន់ការពារធម្មជាតិនោះទៀតសោតមានតែតំបន់មួយចំនួនប៉ុណ្ណោះ ដែលអាចបង្កើតសហគមន៍តំបន់ការពារធម្មជាតិបាន។ តំបន់ការពារធម្មជាតិ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយតំបន់ការពារធម្មជាតិស្ថិតនៅក្នុងប្រភេទមួយ ក្នុងចំណោមតំបន់ចំនួន ៨ប្រភេទផ្សេងទៀត។[55] តំបន់ការពារធម្មជាតិនីមួយៗត្រូវបានបែងចែកជា ៤ តំបន់ រួមមាន តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ហើយតំបន់នីមួយៗមានដែនសមត្ថភាពរៀងៗខ្លួន។[56]

ការកំណត់បែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិគឺផ្អែកលើទិដ្ឋភាពចំនួន ៥ រួមមាន គោលបំណងនៃការគ្រប់គ្រងតំបន់ ទិដ្ឋភាពអេកូឡូស៊ី ទិដ្ឋភាពសេដ្ឋកិច្ចសង្គម និងទិដ្ឋភាពវប្បធម៌ សមត្ថភាពក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ និងទីតាំងភូមិសាស្ត្រនៃតំបន់។[57] ការកំណត់បែងចែកគឺជាភារកិច្ចរបស់ក្រសួងបរិស្ថាន ជាមួយការចូលរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។[58]

ដោយសារតែការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានអនុញ្ញាតឲ្យបង្កើតតែនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ដូច្នេះការចូលរួមរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិចក្នុងការពិភាក្សាកំណត់បែងចែកតំបន់គ្រប់គ្រង គឺមានសារសំខាន់ណាស់។[59] តាមពិតទៅ បើយោងតាមច្បាប់បច្ចុប្បន្ន សហគមន៍មូលដ្ឋានអាចចូលរួមក្នុងដំណើរការបែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដោយធ្វើជាប្រភពផ្តល់ព័ត៌មាន និងទិន្នន័យសម្រាប់អាជ្ញាធររដ្ឋាភិបាល។[60] ទោះជាយ៉ាងណា ក្នុងទិដ្ឋភាពជាក់ស្តែង ការចូលរួមរបស់សហគមន៍មូលដ្ឋានត្រូវបានមើលរំលង ឬធ្វើមិនបានគ្រប់ជ្រុងជ្រោយ។

ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិមួយ អាចត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយចំនួន។ តួយ៉ាង សហគមន៍មូលដ្ឋានអាចដាក់ពាក្យស្នើបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ឬរដ្ឋាភិបាលអាចជាអ្នកផ្តួចផ្តើម និង/ឬ ដៃគូអភិវឌ្ឍអាចពិគ្រោះជាមួយសហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិច ដើម្បីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។[61] ដើម្បីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ សមាជិកសហគមន៍ត្រូវតែធ្វើពាក្យស្នើសុំសមាជិកភាព ពាក្យស្នើសុំបង្កើតសហគមន៍ ការបោះឆ្នោតសហគមន៍ ការបោះបង្គោលព្រំប្រទល់សហគមន៍ ការបង្កើតលក្ខន្តិកៈសហគមន៍ ការបង្កើតផែនការអភិវឌ្ឍសហគមន៍ និងការបង្កើតកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍។[62]

## នីតិវិធីនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិតម្រូវឲ្យសម្រេចអនុវត្តចំណុចចំនួន ៧ ដូចខាងក្រោម៖

**១. វាយតម្លៃតាមរយៈការចូលរួម និងកិច្ចពិគ្រោះយោបល់**

ការប្រមូលព័ត៌មាន និងទិន្នន័យដោយមន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ដោយមានកិច្ចសហការជាមួយសហគមន៍មូលដ្ឋាន ដើម្បីស្វែងយល់ពីទិដ្ឋភាពពិតនៃសហគមន៍ និងវិភាគអំពីភាពសមស្របនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។

**២. កិច្ចស្នើសុំការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ**

ការដាក់ពាក្យស្នើសុំបង្កើតសហគមន៍ ដោយក្រុមគ្រួសារនីមួយៗដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងកិច្ចការសហគមន៍ ក៏ដូចជាការដាក់ពាក្យស្នើសុំបង្កើតសហគមន៍ ដោយសហគមន៍តំបន់ការពារធម្មជាតិផ្ទាល់។

**៣. ការរៀបចំរចនាសម្ព័ន្ធសហគមន៍តំបន់ការពារធម្មជាតិ**

ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ត្រូវបានរៀបចំឡើងដើម្បីបង្កើតគណៈកម្មការរបស់សហគមន៍។ គណៈកម្មការរបស់សហគមន៍ត្រូវមាន ២ ឬ ៣ថ្នាក់ អាស្រ័យលើចំនួនអ្នកភូមិចូលរួមផ្ទាល់។ ក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយជាប់ឆ្នោត គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិត្រូវតែទទួលបានលិខិតទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់ ដើម្បីបញ្ជាក់ពីភាពស្របច្បាប់របស់គណៈកម្មការសហគមន៍ក្នុងការដឹកនាំ និងតំណាងពលរដ្ឋក្នុងសហគមន៍។

**៤. ការបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ**

ការបោះបង្គោលព្រំប្រទល់សហគមន៍ ត្រូវបានធ្វើឡើងផ្អែកលើកត្តាភូមិសាស្ត្រ និងគោលបំណងរបស់គណៈកម្មការរបស់សហគមន៍។ នីតិវិធីមួយចំនួន ត្រូវបានធ្វើឡើង៖

ក/ កិច្ចពិភាក្សាស្តីពីការបោះបង្គោលព្រំប្រទល់សហគមន៍រវាងគណៈកម្មការសហគមន៍ ក្រុមការងារបច្ចេកទេស និងអាជ្ញាធរមូលដ្ឋាន

ខ/ ទស្សនកិច្ចផ្ទាល់នៅតំបន់បោះបង្គោលព្រំដីជាមួយប្រធានទទួលបន្ទុកតំបន់ការពារធម្មជាតិ ហើយនឹងមានការបោះបង្គោលព្រំដីបណ្តោះអាសន្ន ដើម្បីបង្កលទ្ធភាពឲ្យមានពាក្យបណ្តឹងទាក់ទិននឹងការបោះបង្គោល

គ/ ការដោះស្រាយវិវាទ

ឃ/ ការបោះបង្គោលព្រំប្រទល់សហគមន៍ ដោយមានជំនួយផ្នែកបច្ចេកទេស និងសម្ភារៈ ក្រោមកិច្ចសម្របសម្រួលរបស់ក្រុមការងារសហគមន៍

ង/ រៀបចំផែនទី ផ្អែកតាមមាត្រដ្ឋាន DATUM: WGS 84 ក្រោមកិច្ចសម្របសម្រួលដោយនាយកដ្ឋានជីវភាពសហគមន៍ និង

ច/ ការបោះបង្គោលព្រំប្រទល់ ដែលមានវាយលេខបង្គោលតាមលំដាប់លំដោយជាមួយនឹងឈ្មោះសហគមន៍តំបន់ការពារធម្មជាតិ និងចំណុចនិយាមសហគមន៍ (UTM) ទៅតាមស្ថានព្រំដីរបស់សហគមន៍ ហើយក៏មានតម្លើងផ្លាកដែលអនុញ្ញាត ឬមិនអនុញ្ញាតឲ្យចូលក្នុងដីសហគមន៍។

**៥. ការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ**

ការរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ មានដំណាក់កាលមួយចំនួន រួមមាន៖

ក/ ការរៀបចំនីតិវិធីបង្កើតលក្ខន្តិកៈ

ខ/ ពង្រាងលក្ខន្តិកៈ

គ/ កិច្ចពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ស្តីពីសេចក្តីពង្រាងលក្ខន្តិកៈ

ឃ/ កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធស្តីពីសេចក្តីពង្រាងលក្ខន្តិកៈ

ង/ ការទទួលស្គាល់លក្ខន្តិកៈ។

នៅក្នុងដំណាក់រៀបចំបង្កើតលក្ខន្តិកៈ គណៈកម្មការរបស់សហគមន៍អាចធ្វើការស្នើសុំជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ ប្រធានទទួលបន្ទុកតំបន់ការពារធម្មជាតិ មន្ទីរបរិស្ថានខេត្ត ឬនាយកដ្ឋានជីវភាពសហគមន៍។ ក្នុងអំឡុងពេលពង្រាងសេចក្តីព្រាងលក្ខន្តិកៈ សមាសភាពអង្គប្រជុំរួមមានគណៈកម្មការសហគមន៍ មេភូមិ ក្រុមប្រឹក្សាឃុំ និងសមាជិកសំខាន់ផ្សេងៗទៀតរបស់សហគមន៍។

**នីតិវិធីនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិតម្រូវឲ្យសម្រេចអនុវត្តចំណុចចំនួន ៧ ដូចខាងក្រោម៖**

**៦. ការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ**

ការអភិវឌ្ឍផែនការគ្រប់គ្រងសហគមន៍ រាប់បញ្ចូល ការគ្រប់គ្រងតំបន់ចំណុះនានា និងការវាយតម្លៃស្ថានភាពធនធានធម្មជាតិ និងតម្រូវការផ្សេងៗរបស់សហគមន៍។ ពង្រាងផែនការគ្រប់គ្រងសហគមន៍ ត្រូវតែទទួលបានមតិយោបល់នានាពីសមាជិកសហគមន៍ ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងទៀត។ គណៈកម្មការសហគមន៍ត្រូវតែធ្វើពាក្យស្នើសុំការទទួលស្គាល់ផែនការគ្រប់គ្រងសហគមន៍ ហើយផែនការនេះត្រូវតែបានចុះហត្ថលេខាជាផ្លូវការដើម្បីចូលជាធរមាន។

**៧. ការបង្កើតកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ**

ក្រោមជំនួយបច្ចេកទេសពីសំណាក់អាជ្ញាធរមូលដ្ឋាន កិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍ ត្រូវបានរៀបចំធ្វើឡើង ហើយនឹងត្រូវបានចុះហត្ថលេខា ក្នុងពិធីប្រកាសជាផ្លូវការនូវសុពលភាពរបស់កិច្ចព្រមព្រៀង។

បច្ចុប្បន្ន សហគមន៍តំបន់ការពារធម្មជាតិចំនួន ១៨២ កន្លែង ត្រូវបានបង្កើតឡើង ក្នុងតំបន់ការពារធម្មជាតិចំនួន ៣១។ ក្នុងចំណោមចំនួនសហគមន៍ទាំងអស់ ក្នុងនោះ សហគមន៍ចំនួន ១៤១ បានទទួលប្រកាសក្នុងការទទួលស្គាល់ជាផ្លូវការពីសំណាក់ក្រសួងបរិស្ថាន (ដែលបានផ្តល់ជូនសហគមន៍ក្រោយសហគមន៍ធ្វើបានសម្រេចនីតិវិធីទី ៥ ខាងលើ ក្នុងការរៀបចំបង្កើតលក្ខន្តិកៈ) សហគមន៍ចំនួន ៣៩ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍ ហើយសហគមន៍ចំនួន ៤៨ មានផែនការគ្រប់គ្រងសហគមន៍។.[63]

## ចន្លោះប្រហោងផ្លូវច្បាប់៖

### បញ្ហានីតិវិធីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងការមើលរំលងភាពសំខាន់នៃការគ្រប់គ្រងសហគមន៍ក្នុងអំឡុងពេលដំណើរការបង្កើតតំបន់ការពារធម្មជាតិ

នីតិវិធីទាំង ៧ចំណុចខាងលើ ដែលដាក់ចេញក្នុងសេចក្តីណែនាំស្តីពីបង្កើតសហគមន៍ បើមើលមួយភ្លែត ហាក់មានភាពសាមញ្ញ និងសមហេតុផល។ ទោះជាយ៉ាងណា នៅពេលអនុវត្តផ្ទាល់ នីតិវិធីទាំងនេះនាំមកនូវបញ្ហាអនុវត្តដែលត្រូវប្រើរយៈពេលវែងសម្រាប់សហគមន៍។ បើទោះជាក្នុងពាក្យស្នើសុំបង្កើតសហគមន៍ហាក់មានលក្ខណៈសាមញ្ញ ប៉ុន្តែនិរន្តរភាពនៃសហគមន៍ហាក់មិនត្រូវបានពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយក្នុងនីតិវិធីចំណុចទី ១ និងចំណុចទី ២។ នីតិវិធីចំណុចទី ១ ជាទូទៅច្រើនត្រូវបានធ្វើឡើងដោយមានលក្ខណៈលឿន ហើយខ្វះការពិភាក្សាឲ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសលើអនាគតនៃកិច្ចការងារទាំងឡាយរបស់សហគមន៍។ បន្ថែមពីលើនេះ នីតិវិធីចំណុចទី ៣ ដល់ទី ៦ គឺច្រើនត្រូវបានមើលរំលងតែម្តង ឬចំណុចទាំងអស់នេះ ត្រូវបានធ្វើឡើងបន្ទាប់ពីបង្កើតសហគមន៍រួចប៉ុណ្ណោះ។ ជាលទ្ធផល ចំណុចផ្សេងៗស្តីពីកិច្ចគ្រប់គ្រង និងអភិបាលកិច្ច នៃសហគមន៍ មិនត្រូវបានពិចារណា និងពិភាក្សាឲ្យបានល្អិតល្អន់ ដែលជាហេតុរារាំងភាពជោគជ័យនៃកិច្ចការសហគមន៍។[64] ការអនុវត្តនីតិវិធីចំណុចទី ៦ ពោលគឺការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ នៅមុនពេលបង្កើតសហគមន៍អាចជួយធានាបានថាសហគមន៍មានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដោយពួកគេបានចូលរួមនៅក្នុងការវាយតម្លៃនៅជំហានដំបូង និងអាចបញ្ជាក់ជាមួយសហគមន៍ថាតើពួកគាត់មានគម្រោងក្នុងការគ្រប់គ្រងសហគមន៍ការពារធម្មជាតិរបស់ពួកគាត់ដោយរបៀបណា។

បើយោងតាមប្រភពជាច្រើន សហគមន៍មូលដ្ឋានមើលឃើញការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ជាឱកាសមួយដើម្បីដណ្តើមកាន់កាប់ដីរដ្ឋ ដោយមិនបានពិចារណា និងគិតគូរឲ្យបានគ្រប់ជ្រុងជ្រោយអំពីអនាគតនៃសហគមន៍ ឬក៏ប្រយោជន៍សហគមន៍ជារួមឡើយ។ និយាយជារួម គណៈកម្មាការប្រតិបត្តិសហគមន៍មួយចំនួនមើលឃើញដីសហគមន៍ គឺជាទ្រព្យសម្បត្តិដែលពួកគេត្រូវការការពារ ឬប្រើប្រាស់ដើម្បីជាលាភសក្ការៈ ពីព្រោះតំបន់ព្រៃជុំវិញសហគមន៍តំបន់ការពារធម្មជាតិច្រើនត្រូវបានលក់ឲ្យឈ្មួញដែលហ៊ានឲ្យតម្លៃថ្លៃ។.[65]

### ភាពស្មុគស្មាញផ្នែករដ្ឋបាល

ដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលមានចែងក្នុងច្បាប់ជាធរមាន គឺតម្រូវឲ្យមានការពិគ្រោះយោបល់ក្រោមជំនួយបច្ចេកទេសដោយមន្ត្រីរាជរដ្ឋាភិបាល។ សហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិចមានការលំបាកក្នុងការអនុវត្តតាមនីតិវិធីទាំងអស់ដែលត្រូវបានដាក់ចេញ។ គ្រប់ជំហាននៃនីតិវិធីទាំងនេះ គឺត្រូវការជំនួយបច្ចេកទេស ឬកិច្ចពិគ្រោះយោបល់ជាមួយមន្ត្រីរាជរដ្ឋាភិបាល។.[66]

យោងតាមបទពិសោធន៍កន្លងទៅ បានបញ្ជាក់ឲ្យឃើញថា សហគមន៍មូលដ្ឋានត្រូវការពេលយ៉ាងតិច ៦ ទៅ៧ឆ្នាំ ដើម្បីបង្កើត និងឈានដល់ចុះកិច្ចព្រមព្រៀងបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដែលក្នុងនោះរាប់បញ្ចូលទាំងការរៀបចំឲ្យមានឯកសារសំខាន់ៗមួយចំនួន ដូចជាផែនការគ្រប់គ្រងសហគមន៍។ កត្តានេះធ្វើឲ្យសហគមន៍ មានភាពទន់ខ្សោយ និងយឺតយ៉ាវក្នុងការឆ្លើយតបបញ្ហាប្រឈមសំខាន់រួមមាន បញ្ហាបរិស្ថាន និងបញ្ហាជីវភាពប្រជាជនក្នុងសហគមន៍។[67] ( **សុំមើល ចំណុច ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីព័ត៌មានបន្ថែម** )។

## ការបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ

ការបោះបង្គោលព្រំប្រទល់សហគមន៍គឺជាក្តីព្រួយបារម្ភមួយសម្រាប់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិភាគតិច។ ជាគោលការណ៍ច្បាប់ បញ្ហាបោះបង្គោលព្រំប្រទល់ គឺតម្រូវឲ្យមានការចូលរួមយ៉ាងជិតស្និទ្ធពីសំណាក់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច។ ទោះជាយ៉ាងណា ការអនុវត្តជាក់ស្តែងត្រង់ចំណុចនេះ នៅមានកម្រិតនៅឡើយ។ ការចូលរួមរបស់សហគមន៍ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន មានលក្ខណៈសំខាន់ ពីព្រោះតាមផ្លូវច្បាប់ មិនមានកំណត់ណាមួយថា ទំហំសហគមន៍តំបន់ការពារធម្មជាតិ ដែលគ្រាន់តែបានចែងថា ទំហំសហគមន៍ គឺមានទំហំសមស្របប៉ុណ្ណោះ។[68] បញ្ហានេះចុងក្រោយ ត្រូវបានសម្រេចដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បើទោះជាកិច្ចការបោះបង្គោលព្រំប្រទល់សហគមន៍ គួរតែត្រូវបានធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ក្រុមជនជាតិដើមភាគតិច និងអាជ្ញាធរមូលដ្ឋានក៏ដោយ។[69] ជារឿយៗ ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ មិនបានឆ្លុះបញ្ចាំងពីទីតាំងសហគមន៍មូលដ្ឋាន ឬផ្តល់ឱកាសសកម្មភាពសេដ្ឋកិច្ចផ្សេងៗដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋឡើយ ដែលនេះជាបច្ច័យបង្កការលំបាកថែមមួយកម្រិតទៀតដល់ការអនុវត្តកិច្ចការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។[70]

> "ការចូលរួមរបស់សហគមន៍ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន មានលក្ខណៈសំខាន់ ពីព្រោះតាមផ្លូវច្បាប់ មិនមានកំណត់ណាមួយថា ទំហំសហគមន៍តំបន់ការពារធម្មជាតិ ដែលគ្រាន់តែបានចែងថា ទំហំសហគមន៍ គឺមានទំហំសមស្របប៉ុណ្ណោះ។"

## ដំណាក់កាលនៃការដាក់ពាក្យស្នើសុំមានរយៈពេលយូរ

ក្របខ័ណ្ឌច្បាប់សហគមន៍តំបន់ការពារធម្មជាតិមិនបានចែងអំពីដំណាក់កាលជាក់លាក់ណាដែលបញ្ជាក់ពីរដ្ឋបាលណាមួយដែលទទួលរ៉ាប់រងលើគ្រប់ដំណាក់កាលនីមួយៗនៃការដាក់ស្នើសុំរបស់សហគមន៍សម្រាប់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនោះទេ ហើយក៏មិនមានច្បាប់ណាមួយបញ្ជាក់ថា ការមិនបានឆ្លើយតបពីរដ្ឋបាលមានន័យថាជាការអនុញ្ញាត ឬការប្រានចោលពាក្យស្នើសុំឡើយ ក៏គ្មានច្បាប់ណាដែលចែងអំពីកត្តាអាចធ្វើការតវ៉ាបន្ត ប្រសិនបើការដាក់ស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិត្រូវបានបដិសេធ។[71] រយៈពេលដែលមិនមានការកំណត់ជាក់លាក់ត្រឹមត្រូវសម្រាប់អាជ្ញាធររដ្ឋាភិបាលធ្វើការពិនិត្យ និងធ្វើការអនុញ្ញាត ឬបដិសេធពាក្យស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ បង្កឲ្យមានភាពមិនប្រាកដយ៉ាងខ្លាំងសម្រាប់សហគមន៍ក្នុងអំឡុងពេលដាក់ស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ ទោះបីជាអាជ្ញាធរបានធ្វើការលើពាក្យស្នើសុំក្នុងករណីនីមួយៗឲ្យបានរហ័សក៏ដោយ ក៏ការខ្វះខាតនៃរយៈពេលកំណត់ដោយច្បាប់ ក៏អាចធ្វើឲ្យពាក្យស្នើសុំមានភាពទន់ខ្សោយ និងមិនមានតម្រូវការឲ្យខាងអាជ្ញាធរធ្វើសកម្មភាពទាន់ពេលវេលានោះទេ។[72]

លើសពីនេះទៅទៀត ទោះបីជាការធ្វើវិមជ្ឈការកំពុងដំណើរការទៅមុខ ហើយមានការបែងចែកតួនាទី និងការទទួលខុសត្រូវផ្សេងគ្នារវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺបន្តនៅក្រោមរដ្ឋបាលកណ្តាលដដែរ ដែលតម្រូវការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺត្រូវមានការអនុញ្ញាតចុងក្រោយពីក្រសួងបរិស្ថាន។[73]

វិមជ្ឈការនៃដំណាក់កាលបង្កើត ឧទាហរណ៍ដូចជាការប្រគល់សិទ្ធិក្នុងការអនុញ្ញាតឲ្យបង្កើតសហគមន៍តំបន់ការពារធម្មជាតិទៅឲ្យអាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ អាចធ្វើឲ្យការបង្កើតសហគមន៍តំបន់ការពារធម្មជាតិមានរយៈពេលខ្លី និងពង្រឹងការសម្រេចចិត្តដែលមានភាពជិតស្និទ្ធជាមួយទីតាំងបង្កើតផ្ទាល់ បង្កើនភាពងាយស្រួលសម្រាប់ការចូលរួមជាសហគមន៍តំបន់ការពារធម្មជាតិ។ ប៉ុន្តែការធ្វើបែបនេះក៏អាចធ្វើឲ្យមានបញ្ហាវិញដែរប្រសិនបើអាជ្ញាធរមូលដ្ឋានដែលមានកាតព្វកិច្ចក្នុងការយល់ព្រមលើសហគមន៍តំបន់ការពារធម្មជាតិ មានកត្តាអាទិភាពផ្សេងទៀតដើម្បីប្រកួតប្រជែងជាមួយការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ ដែលអាចមានភាពល្អៀងទៅការអភិវឌ្ឍឯកជនជាងការលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍។

# បញ្ហានៃការអនុវត្ត៖

## ដំណាក់កាលនៃការចុះឈ្មោះមានតម្លៃថ្លៃ និងរយៈពេលយូរ

ដំណាក់កាលនៃការចុះឈ្មោះជាសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រ មើលឃើញថាមានលក្ខណៈថ្លៃ និងប្រើប្រាស់រយៈពេលយូរ។ ទោះបីការដាក់ពាក្យស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិដោយឥតគិតថ្លៃ ក៏នៅមានថ្លៃបង់សម្រាប់ប្រតិបត្តិការផ្សេងៗក្នុងដំណាក់កាលនេះដែរ។ ឧទាហរណ៍ចំណាយលើការធ្វើដំណើរសម្រាប់ការរៀបចំការជួបពិភាក្សារវាងអាជ្ញាធរ និងសហគមន៍ និងថ្លៃចំណាយសម្រាប់ការកំណត់ព្រំដី។ បន្ទុកនៃការបង់ថ្លៃនេះភាគច្រើនជាបន្ទុករបស់អង្គការមិនមែនរដ្ឋាភិបាលដែលជួយដល់សហគមន៍ដែលកំពុងឆ្លងកាត់ដំណាក់កាលនេះ ព្រោះវាអាចជាបន្ទុកធ្ងន់មួយដល់សហគមន៍ក្នុងការធ្វើប្រតិបត្តិការតែឯង។[74]

សហគមន៍បានបង្ហាញអំពីការខកចិត្តជាមួយនឹងដំណាក់កាលបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដោយលើកឡើងថាមានតម្រូវការឲ្យបំពេញការងារជាច្រើនជំហាន ហើយត្រូវមានអាជ្ញាធរចូលរួមជាច្រើនផ្សេងទៀត។ ដំណាក់កាលនីមួយៗ តម្រូវឲ្យសហគមន៍ធ្វើការប្រគល់ជូនផ្ទាល់ និងត្រូវមានការយល់ព្រមពីអាជ្ញាធរ។ ការពន្យារកើតឡើងជាញឹកញយ កើតឡើងដោយសារសមត្ថភាពរបស់សហគមន៍នៅមានកម្រិត និងសមត្ថកិច្ចមានកង្វះខាតធនធានបច្ចេកទេស ថវិកា និងធនធានមនុស្ស។ កន្លងមកធ្លាប់មាន អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នផ្សេងទៀតជួយជាជំនួយក្រៅផ្លូវការសម្រាប់ដំណើរការឲ្យបានលឿន ប៉ុន្តែកត្តានេះអាចនាំមកនូវភាពមិនស្មើគ្នាដល់សហគមន៍ពេលដែលដាក់សំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិឲ្យទាន់ពេលសមរម្យ និងដំណើរការប្រកបដោយប្រសិទ្ធភាព។ ដំណាក់កាលបង្កើតសហគមន៍ព្រៃឈើ ត្រូវបានគេយល់ថាជាសកម្មភាពមួយដែលមានភាពហត់នឿយ ហើយសហគមន៍មួយចំនួនទៀតយល់ឃើញថាដំណាក់កាលនេះមានលក្ខណៈងាយស្រួលជាង សហគមន៍តំបន់ការពារធម្មជាតិ។[75]



## តម្រូវការនៃការពង្រឹងឥទ្ធិពលរបស់សហគមន៍បន្ថែមទៀតលើការបែកវិលែកដីសហគមន៍តំបន់ការពារធម្មជាតិ

ភាពមិនច្បាស់លាស់នៃលក្ខខ័ណ្ឌនៃការចូលរួមរបស់សហគមន៍នៅក្នុងការដំណាក់កាលការបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ បាននាំឲ្យកម្រិតនៃការចូលរួមខុសគ្នា បណ្តាលឲ្យកម្រិតនៃការពេញចិត្តរបស់សហគមន៍លើការបែងចែកដីសហគមន៍តំបន់ការពារធម្មជាតិក៏ខុសគ្នាដែរ។[76] ក្នុងករណីធ្ងន់ធ្ងរ ដីសហគមន៍តំបន់ការពារធម្មជាតិដែលបានចែកជាក់ស្តែងឲ្យទៅសហគមន៍គឺមានទំហំតូច ហើយមានទីតាំងខុសពីអ្វីដែលបានដាក់ពាក្យស្នើសុំ។[77] ការអនុវត្តដែលមិនរាប់បញ្ចូលដីដែលបានដាក់ស្នើសុំពីការបែងចែងដីសហគមន៍តំបន់ការពារធម្មជាតិ ដែលភាគច្រើនមានព្រៃច្រើន និងជីវៈចម្រុះច្រើន បានធ្វើឲ្យមានកម្រិតនូវឱកាសរបស់សហគមន៍ក្នុងការរក្សាទំនៀមទំលាប់ប្រពៃណី និងអភិវឌ្ឍសកម្មភាពជីវភាពរស់នៅ ដូចជាអេកូទេសចរណ៍ និងការប្រមូលផ្ដុំអនុផលព្រៃឈើ ដែលធ្វើឲ្យសេដ្ឋកិច្ច និងសក្តានុពលក្នុងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការប្តេជ្ញាចិត្តរបស់សហគមន៍ទាំងមូលក្នុងការចូលរួមក្នុងយន្តការត្រូវបានធ្លាក់ចុះ។

ក្នុងករណីភាគច្រើន អង្គការមិនមែនរដ្ឋាភិបាលបានជួយដល់សហគមន៍ក្នុងដំណាក់កាលបង្កើតសហគមន៍តំបន់ការពារធម្មជាតិ រួមទាំងការបោះបង្គោលព្រំប្រទល់ និងបែងចែងតំបន់គ្រប់គ្រង។ នៅថ្នាក់មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលជាធម្មតាជួយសហគមន៍នូវសកម្មភាព ចំនួន០៣ ដែលទាក់ទងទៅនឹងការបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ៖ ការគូរព្រំប្រទល់នៅលើផែនទី បញ្ជាក់ការគូរព្រំប្រទល់នៅលើទីតាំងផ្ទាល់ និងការប្រគល់ឯកសារទៅឲ្យក្រសួងបរិស្ថាន។ ការប្រគល់ឯកសារត្រូវមានការអនុញ្ញាតពីអាជ្ញាធររកម្រិតផ្សេងៗគ្នា ដូចជាពីមេឃុំ អាជ្ញាធរថ្នាក់ស្រុក និងអាជ្ញាធរថ្នាក់ខេត្ត និងមន្ទីរបរិស្ថានខេត្ត។[78] សហគមន៍បានបង្ហាញឲ្យឃើញពីការខកចិត្តលើដំណាក់កាលនៃការបោះបង្គោលព្រំប្រទល់ ដែលភាគច្រើនធ្វើឡើងដោយអ្នកជំនាញមកពីមន្ទីរបរិស្ថានខេត្ត ដែលមិនសូវមានការពិភាក្សាគ្រប់គ្រាន់ និងមានការឯកភាពគ្រប់គ្រាន់ពីខាងសមាជិកសហគមន៍។ ហេតុដូចនេះ ការបែងចែងសហគមន៍តំបន់ការពារធម្មជាតិនៅពេលខ្លះត្រូវបានធ្វើឡើងដោយគ្មានការគោរពដល់ ការប្រើប្រាស់ដី និងព្រៃឈើតាមប្រពៃណីរបស់សហគមន៍ ដែលជាលទ្ធផលធ្វើឲ្យសហគមន៍មានការមិនពេញចិត្តលើចំណុចសហគមន៍តំបន់ការពារធម្មជាតិ ដូចជាទីតាំង និងទំហំ។[79] ជាពិសេស វាបង្កឲ្យមានឧបសគ្គសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដោយសារការប្រើប្រាស់ភាសាខុសគ្នា ធ្វើឲ្យមានការពិបាកក្នុងការទំនាក់ទំនង។[80] នៅក្នុងកម្រិតថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាលបានធ្វើការផ្ទាល់ជាមួយក្រសួងបរិស្ថានលើការកំណត់បែងចែកតំបន់គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ នៅពេលដែលទទួលបានព័ត៌មានអំពីការបោះបង្គោលព្រំប្រទល់ដីពីសហគមន៍តំបន់ការពារធម្មជាតិ។

## ការជាន់គ្នារវាងសម្បទានដីសេដ្ឋកិច្ចជាមួយដីសហគមន៍តំបន់ការពារធម្មជាតិ

សម្បទានដីសេដ្ឋកិច្ចភាគច្រើនត្រូវបានផ្តល់ឲ្យដោយមិនមានការពិភាក្សាឲ្យបានត្រឹមត្រូវជាមួយសហគមន៍ដែល រងប៉ះពាល់ផលប៉ះពាល់។ ហេតុដូចនេះ បានធ្វើឲ្យមានការជាន់គ្នារវាងសម្បទានដីសេដ្ឋកិច្ចដែលមានក្នុងដីសហគមន៍មូលដ្ឋាន និងដីរបស់កសិករ ដីសហគមន៍តំបន់ការពារធម្មជាតិ និងដីរបស់ជនជាតិដើមភាគតិច ដែលជាលទ្ធផលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ជីវៈចម្រុះ ព្រៃឈើ និងសត្វព្រៃ វិវាទដីធ្លី និងស្ថិរភាពនៃជំនឿក្នុងថ្នាក់មូលដ្ឋាន និងវប្បធម៌។[81] លើសពីនេះទៅទៀត ដីភាគច្រើនត្រូវបានផ្តល់ឲ្យជាដសម្បទានដីសេដ្ឋកិច្ចលឿនជាង ការផ្តល់ដីជាដីសហគមន៍តំបន់ការពារធម្មជាតិ។ ជាក់ស្តែង បច្ចុប្បន្នមិនទាន់មានយន្តការច្បាប់ណាមួយដែលច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទរវាងការបែងចែកសម្បទានដីសេដ្ឋកិច្ច និងសហគមន៍តំបន់ការពារធម្មជាតិឡើយ។ ការប្រតិបត្តិរបស់សហគមន៍មូលដ្ឋានក្នុងការដាក់ពាក្យបណ្តឹងទៅអាជ្ញាធរថ្នាក់ខេត្តនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ។[82] ការបោះបង្គោលកំណត់ព្រំប្រទល់ដីសម្រាប់សម្បទានដីសេដ្ឋកិច្ច និងសហគមន៍តំបន់ការពារធម្មជាតិឲ្យបានជាក់លាក់ត្រូវបានគេទទួលស្គាល់ថាជាកត្តាសំខាន់ក្នុងការទប់ស្កាត់វិវាទ ក៏ដូចជាសម្រាប់ការដោះស្រាវិវាទ។ ជាក់ស្តែង ភាគីពាក់ព័ន្ធទាំងអស់ភាគច្រើនមិនសូវដឹងអំពីព្រំប្រទល់ដីនៅត្រង់ចំណុចណាឲ្យប្រាកដនោះទេ។[83]

## មិនមានយន្តការផ្លាស់ប្តូរពីសហគមន៍ព្រៃឈើ ទៅសហគមន៍តំបន់ការពារធម្មជាតិ

បច្ចុប្បន្ននេះ មិនទាន់យន្តការច្បាប់ណាដែលបញ្ជាក់អំពីវិធីកែប្រែពីសហគមន៍ព្រៃឈើ ទៅសហគមន៍តំបន់ការពារធម្មជាតិទេ (ឬទៅវិញទៅមក) នាំឲ្យមានការយល់ច្រឡំក្នុងពេលអនុវត្តនៅត្រង់ចំណុចដែនសមត្ថកិច្ច និងនីតិវិធីរដ្ឋបាល។ សហគមន៍ដែលបានធ្លាប់ព្យាយាមផ្លាស់ប្តូរ បានជួបប្រទះនឹងការរាំងស្ទះដោយសារតែមានការទាមទារឲ្យមានការអនុញ្ញាតពីអាជ្ញាធរថ្នាក់ក្រោមជាតិទៅអាជ្ញាធរថ្នាក់ជាតិ ដែលត្រូវធ្វើប្រតិបត្តិការទាំងផ្នែកជំនាញ និងមិនមាននីតិវិធីជាក់លាក់ក្នុងការធ្វើ។[84] អាជ្ញាធរថ្នាក់ក្រោមជាតិបន្តធ្វើការជាមួយអាជ្ញាធរមិនពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ ដូចជាក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ដើម្បីភាពងាយស្រួលដោះស្រាយបញ្ហា ទាក់ទងសហគមន៍តំបន់ការពារធម្មជាតិ។[85] ការបង្កើតឲ្យមានយន្តការផ្លាស់ប្តូរឲ្យបានជាក់លាក់ និងងាយស្រួល គឺជាការបន្ទាន់ និងចាំបាច់ដើម្បីលើកទឹកចិត្តដល់ការពង្រីកប្រព័ន្ធសហគមន៍តំបន់ការពារធម្មជាតិ។

## អនុសាសន៍ណែនាំ៖

**i.** ធានានូវវត្តមានចូលរួមដ៏សំខាន់ពីសហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិចក្នុងពេលគូរផែនទី និងកំណត់តំបន់នៃតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិជារួមដែលជាផ្នែកមួយក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ហើយទាំងនេះក៏អាចផ្តល់ការយល់ដឹងគ្រប់គ្រាន់អំពីប្រវត្តិ វប្បធម៌ និងប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ដែលមានការផ្សាភ្ជាប់យ៉ាងជិតស្និតជាមួយការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់នោះ។

**ii.** កែសម្រួលឲ្យមានភាពសាមញ្ញសម្រាប់ដំណាក់កាលបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីធ្វើឲ្យមានភាពងាយស្រួលដល់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិចអាចចូលរួមបាន (ឧទាហរណ៍៖ការគូរផែនទីត្រូវធ្វើដោយមិនចាំបាច់បច្ចេកខ្លាំង ហើយត្រូវផ្អែកលើផែនទីដែលគូរចេញពីសហគមន៍) ហើយការគ្រប់គ្រងប្រកបដោយលក្ខណៈសាមញ្ញធ្វើឡើងដោយសហគមន៍ផ្ទាល់ក៏គ្រប់គ្រាន់ដែរ។

**iii.** ការអភិវឌ្ឍដោយស្ថិតស្ថេរបានផ្តល់កម្មវិធីពង្រឹងសមត្ថភាពជំនាញដល់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ដើម្បីបង្កើតលទ្ធភាពក្នុងការធ្វើការដោយខ្លួនឯង ហើយកាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ (គិតគូរអំពីរយៈពេលដែលត្រូវឆ្លងកាត់ដំណាក់កាលទាំងមូលនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ហើយក៏ដូចជាការគិតគូរអំពីកត្តាដែលផ្នែកគ្រប់គ្រងនៅមានកម្រិតទាបនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ បូករួមទាំងការពង្រឹងសមត្ថភាពគ្រប់គ្រងប្រកបដោយចីរភាព ឱកាសជីវភាព និងកាតព្វកិច្ច ចូលជាជំហានទី១ និងទី២ ទាំងអស់នេះអាចធ្វើឲ្យផ្នែកគ្រប់គ្រងសហគមន៍មានប្រសិទ្ធភាពជាងមុនក្នុងអំឡុងពេលឆ្លងកាត់ដំណាក់កាលបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ហើយអាចនាំឲ្យការអនុវត្តគម្រោងគ្រប់គ្រងប្រសើរជាងមុន)។

**iv.** បញ្ជាក់ពីលក្ខខ័ណ្ឌសម្រាប់ការអនុញ្ញាត ឬការបដិសេធនូវពាក្យស្នើសុំសហគមន៍តំបន់ការពារធម្មជាតិ ក៏ដូចជាលើកឡើងអំពីជម្រើសផ្សេងទៀត សម្រាប់ពេលដែលពាក្យស្នើសុំត្រូវបានបដិសេធ ដូចជាយន្តការប្តឹងតវ៉ា ឬលទ្ធភាពក្នុងការដាក់ពាក្យស្នើសុំដែលបានកែសម្រួលរួចរាល់ម្តងទៀត ដើម្បីជៀសវាងការសម្រេចចិត្តដោយឆន្ទានុសិទ្ធិ។

**v.** ត្រូវរាប់បញ្ចូលដីព្រៃក្នុងការបែងចែកសហគមន៍តំបន់ការពារធម្មជាតិ ដែលភាគច្រើនត្រូវបានគេមិនរាប់បញ្ចូល (ការរាប់បញ្ចូលដីព្រៃអាចផ្តល់ការការពារដី ប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងព្រៃឈើប្រសើរជាងមុនប្រកបដោយចីរភាព និងអាចរកប្រាក់ចំណូលបានពីអេកូទេសចរណ៍ សហគ្រាស និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន)។

**vi.** ផ្តល់ជាយន្តការសមរម្យ និងមានប្រសិទ្ធភាពសម្រាប់ការបែងចែកការផ្លាស់ប្តូរពីសហគមន៍ព្រៃឈើ និសហគមន៍តំបន់ការពារធម្មជាតិ ដោយបង្កើតដែនសមត្ថកិច្ច នីតិវិធី តម្រូវការ ការវិភាគ តួនាទី និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ និងយន្តការប្តឹងតវ៉ាឲ្យបានជាក់លាក់ ប្រសិនបើពាក្យស្នើសុំត្រូវបានបដិសេធ។

# ៣. អភិបាលកិច្ចផ្ទៃក្នុងសហគមន៍

### និយមន័យ៖

គឺជាមធ្យោបាយដែលសហគមន៍តំបន់ការពារធម្មជាតិត្រូវបានគ្រប់គ្រងដោយសមាជិកសហគមន៍ផ្ទាល់ និងជាប្រព័ន្ធសម្រាប់ធ្វើប្រតិបត្តិការគ្រប់គ្រងនេះ។ ក្នុងនោះគួរមានបញ្ជាក់អំពីការបែងចែកអំណាច ដំណាក់កាលនៃការធ្វើសេចក្តីសម្រេចចិត្ត ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងការអនុវត្តបែបប្រពៃណីនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។

### ច្បាប់ទាក់ទងនឹងការកាន់កាប់ដីធ្លី៖

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ(២០១៧) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់(២០០១) អនុក្រឹត្យលេខ២៦ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់(២០០២)

### ភាគីពាក់ព័ន្ធ៖

ក្រសួងមហាផ្ទៃ ប្រធានសហគមន៍ សមាជិកដែលបានជាប់ឆ្នោតក្នុងសហគមន៍ និងរតនាគារជាតិ

## បរិបទទូទៅ៖

រចនាសម្ព័ន្ធអភិបាលកិច្ចក្នុងប្រទេសកម្ពុជាចែកចេញជាពីរថ្នាក់៖ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ(រួមមានអាជ្ញាធរថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ)។ អាជ្ញាធរថ្នាក់ក្រោមជាតិបានបំពេញកាតព្វកិច្ចដែលមានក្នុងដែនសមត្ថកិច្ចរបស់ពួកគេ ប៉ុន្តែត្រូវស្ថិតនៅក្រោមបង្គាប់រដ្ឋាភិបាលថ្នាក់ជាតិ។[86] ចាប់តាំងពីឆ្នាំ២០០៨មក អាជ្ញាធរថ្នាក់ក្រោមជាតិបានចាប់ផ្តើមទទួលបានស្វ័យភាពដោយមានកំណែកែទម្រង់ឲ្យមានលក្ខណៈវិមជ្ឈការដែលនៅក្រោមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅក្នុងថ្នាក់សហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំគឺជាអាជ្ញាធររដ្ឋបាលខ្ពស់ជាងគេ ដែលមានសមាជិកដែលទទួលបានការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាជនមូលដ្ឋាន។[87]

ក្រុមប្រឹក្សាឃុំត្រូវមានការទទួលខុសត្រូវផ្ទាល់សម្រាប់ការបែងចែកការចំណាយសម្រាប់សកម្មភាពឃុំ។ ធនធានភាគច្រើនគឺបានមកពីមូលនិធិរបស់ឃុំ ឬសង្កាត់ ដែលបានចែកមកពីថវិកាជាតិផ្ទាល់មកឲ្យថ្នាក់ឃុំ។ ថវិកានេះជួយដល់ក្រុមប្រឹក្សាលើប្រតិបត្តិការចំនួនពីរ រួមមានការចំណាយលើផ្នែករដ្ឋបាល និងការពង្រីកការអភិវឌ្ឍរបស់មូលដ្ឋាន។ ការចំណាយលើផ្នែករដ្ឋបាលគឺត្រូវបានបែងចែកទៅឲ្យក្រុមប្រឹក្សានីមួយៗយោងទៅតាមចំនួនសមាជិកក្រុមប្រឹក្សាឃុំដែលត្រូវបានជាប់ឆ្នោត។ ការពង្រីកការអភិវឌ្ឍមូលដ្ឋានគឺត្រូវបែងចែកដោយផ្អែកទៅលើជាតុផ្សំចំនួនបី៖ មួយចំណែកស្មើគ្នាៗសម្រាប់សមាជិកក្រុមប្រឹក្សា មួយចំណែកដែលសមាមាត្រទៅនឹងចំនួនប្រជាជនក្នុងឃុំ និងចំណែកចុងក្រោយត្រូវបានគណនាទៅតាមសន្ទស្សន៍ភាពក្រីក្រក្នុងឃុំ។ ក្រុមប្រឹក្សាក៏ប្រមូលបានពីការចូលរួមរបស់ប្រជាជនផងដែរ។ លើសពីនេះទៅទៀតក្រុមប្រឹក្សាមួយចំនួនបានទទួលការឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលដែរ។[88] គ្រប់ឃុំត្រូវឆ្លងកាត់វដ្តនៃផែនការអភិវឌ្ឍឃុំដែលមានរយៈពេល៥ឆ្នាំ ដែលជាផែនការដឹកនាំគម្រោង និងផែនការចំណាយប្រចាំឆ្នាំ។ ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំគឺសិក្ខាសាលាស្តីអំពីសមាហរណកម្មស្រុកដែលធ្វើឡើងដើម្បីសម្រេចនៅគម្រោងថវិការបស់ឃុំ។ ព្រឹត្តិការណ៍នេះតម្រូវឲ្យមានការចូលរួមដោយផ្ទាល់ពីភាគីពាក់ព័ន្ធទាំងអស់ដូចជាមន្ទីរបរិស្ថានខេត្ត និងសមាជិកក្រុមប្រឹក្សាឃុំ ហើយបើកសម្រាប់ភាគីដែលចាប់អារម្មណ៍ផ្សេងទៀតដូចជាការចូលរួម និងយល់ព្រមឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល។

> "នៅក្រោមក្រមខណ្ឌច្បាប់សហគមន៍តំបន់ការពារធម្មជាតិ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាទូទៅផ្អែកលើការគ្រប់គ្រងរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិដែលបានជាប់ឆ្នោត ដែលមានការត្រួតពិនិត្យពីអាជ្ញាធរ។"

នៅក្រោមក្រមខណ្ឌច្បាប់សហគមន៍តំបន់ការពារធម្មជាតិ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាទូទៅផ្អែកលើការគ្រប់គ្រងរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិដែលបានជាប់ឆ្នោតដែលមានការត្រួតពិនិត្យពីអាជ្ញាធរ។[89] គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិមួយត្រូវធ្វើប្រតិបត្តិការមួយអាណត្តិដែលមានរយៈពេល៥ឆ្នាំ ហើយសេចក្តីណែនាំស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិរៀបរាប់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់គណៈកម្មការ។[90] សេចក្តីណែនាំក៏បានបញ្ជាក់អំពីរចនាសម្ព័ន្ធជាក់លាក់មួយនៃការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលមានការបង្កើតក្រុមការងារគ្រប់គ្រង អនុគណៈកម្មការ ដែលមានចាប់ពី ២ ទៅ៣កម្រិត យោងតាមចំនួនភូមិជាក់ស្តែងដែលបានចូលរួម។[91]

**7-15**

សមាជិកនៅក្នុង
គណៈកម្មាធិការ CPA

ការអនុវត្តបច្ចុប្បន្នបានបង្ហាញថាចំនួនសមាជិកនៃគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិមានចំនួនពី ០៧នាក់ ទៅ១៥នាក់ ដែលជាមធ្យមភាគនៃសហគមន៍តំបន់ការពារធម្មជាតិមានចាប់ពី ៨០ ទៅ១៥០គ្រួសារ។ សេចក្តីណែនាំស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិបានណែនាំលើការបង្កើតក្រុមការងារបណ្តោះអាសន្នដើម្បីសម្របសម្រួលសកម្មភាពដែលទាក់ទងនឹងការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ហើយក្រុមការងារនេះត្រូវមានការទទួលខុសត្រូវលើការជ្រើសរើសបេក្ខជន។[92] ជាក់ស្តែង បេក្ខជនអាចត្រូវបានជ្រើសរើសដោយក្រុមសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់ជំនួយ ឬដោយការស្ម័គ្រចិត្ត។[93]

ដោយសម្របតាមច្បាប់គ្រប់គ្រង សមាជិកសហគមន៍តំបន់ការពារធម្មជាតិត្រូវអនុវត្តតាមច្បាប់ទម្លាប់ដែលបង្កើតក្នុងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ (ដែលត្រូវបានធ្វើឡើងដោយសហគមន៍ ដែលមានការទទួលស្គាល់ដោយអាជ្ញាធររដ្ឋាភិបាល)។[94] គំរូលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមានភ្ជាប់ក្នុងឧបសម្ព័ន្ធក្នុងសេចក្តីណែនាំស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិ។

## ចន្លោះប្រហោងផ្លូវច្បាប់៖

### កម្រិតនៃការប្រកាន់ខ្ជាប់ចំពោះឯកសារគ្រប់គ្រងគំរូសហគមន៍តំបន់ការពារធម្មជាតិ

ភាគីពាក់ព័ន្ធមួយបានលើកឡើងអំពីតម្រូវការនៃការបញ្ជាក់ឲ្យបានច្បាស់ថា តើសហគមន៍តំបន់ការពារធម្មជាតិត្រូវតែប្រតិបត្តិតាមឯកសារគំរូឲ្យបានខ្ជាប់ខ្ជួនដល់កម្រិតណា។[95] កន្លងមកធ្លាប់មានហេតុការណ៍ដែលសហគមន៍តំបន់ការពារធម្មជាតិបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពិភាក្សា និងរៀបចំលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិដែលធ្វើឡើងសម្រាប់បំពេញតម្រូវការ និងគោលបំណងរបស់សហគមន៍ពួកគេ ព្រមទាំងទាញយកជំនួយ និងអ្នកជំនាញមកពីខាងក្រៅ ប៉ុន្តែពួកគេត្រូវបានអាជ្ញាធរប្រាប់ថាពួកគេមិនអាចងាកចេញពីគំរូលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិដែលមានចែងក្នុងសេចក្តីណែនាំស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិនោះទេ។ គោលជំហរនេះមិនត្រូវបានគាំទ្រដោយបញ្ញត្តិណាមួយដែលមានចែងក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិឡើយ។[96] វាក៏អាចបណ្តាលឲ្យមានហានិភ័យក្នុងការមិនការរាប់បញ្ចូលនៅការអនុវត្ត និងចំណេះដឹងតាមបែបប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចក្នុងឯកសារគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ប្រសិនបើជាតុផ្សំរបស់សហគមន៍នូវមានកម្រិតខ្លាំង។ ដូចនេះ គួរធ្វើការបំភ្លឺឲ្យបានច្បាស់អំពីការយល់ដឹង និងប្រើប្រាស់ចំពោះគំរូដែលមានចែងក្នុងឧបសម្ព័ន្ធក្នុងសេចក្តីណែនាំស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិ។

### គណនេយ្យភាព

យន្តការគណនេយ្យភាពដែលជាឧបករណ៍ដ៏សំខាន់សម្រាប់អភិបាលកិច្ចល្អ គឺមានសារៈសំខាន់ក្នុងការធ្វើឲ្យអ្នកធ្វើសេចក្តីសម្រេចចិត្តដូចជាសមាជិកគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ ទទួលខុសត្រូវចំពោះសមាជិកក្នុងសហគមន៍តំបន់ការពារធម្មជាតិទាំងអស់។ ក្របខ័ណ្ឌច្បាប់ស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិមិនសូវបានចែងអំពីយន្តការទទួលខុសត្រូវឲ្យបានជាក់លាក់ណាមួយឡើយ។ យន្តការដែលមានគឺរកឃើញនៅក្នុងក្របខ័ណ្ឌច្បាប់ គឺនិយាយអំពីលទ្ធភាពដែលអាចបញ្ឈប់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងធ្វើការបោះឆ្នោតជ្រើសរើសថ្មីប្រសិនបើយ៉ាងតិច ៦០ភាគរយនៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិស្នើសុំការអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីលើកឡើងអំពីការគ្រប់គ្រងពីគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ។[97] ក្របខ័ណ្ឌច្បាប់ស្តីអំពីសហគមន៍តំបន់ការពារធម្មជាតិបានគិតទុកជាមុននូវការបង្កើតយន្តការគណនេយ្យភាព និងរាប់បញ្ចូលទាំងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ដូចជាតម្រូវឲ្យមានកិច្ចប្រជុំទៀងទាត់រវាងសមាជិកសហគមន៍តំបន់ការពារធម្មជាតិ។[98]

### តម្លាភាព

តម្លាភាពគឺជាជំហានមួយទៀតនៃអភិបាលកិច្ចល្អ។ ទោះបីជាតម្លាភាពនេះមាននៅពាសពេញនៅក្នុងឯកសារយោងក៏ដោយ ក៏ប្រសិទ្ធភាពជាក់ស្តែងគឺនៅមានភាពមិនច្បាស់លាស់នៅឡើយ ហើយគោលការណ៍នៃតម្លាភាពក៏ជាត្រូវបានលើកឡើងក្នុងបរិបទនៃការបែងចែងផលចំណេញ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិផងដែរ៩[99]

## បញ្ហាការអនុវត្ត៖

### ការឧបត្ថម្ភពីសាធារណៈមានកំណត់ និងមិនស្មើគ្នា

សហគមន៍ពឹងផ្អែកយ៉ាងខ្លាំងលើការឧបត្ថម្ភពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍសម្រាប់សកម្មភាពសហគមន៍។ ការឧបត្ថម្ភដល់ការអភិវឌ្ឍគម្រោងសហគមន៍ភាគច្រើនគឺក្នុងមូលនិធិឃុំ ឬសង្កាត់ និងការផ្ទេរសារពើពន្ធថ្នាក់ជាតិ។ យោងតាមការព្យាករណ៍ មូលនិធិឃុំជាទូទៅមានត្រឹម១០០,០០០ដុល្លាក្នុងមួយឆ្នាំ ដែល៤០%គឺត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍ។[100]

**$100,000**

ក្នុងមួយឆ្នាំ គឺជាដែនកំណត់ទូទៅចំពោះមូលនិធិឃុំ

ការផ្តល់ការឧបត្ថម្ភសម្រាប់ការអភិវឌ្ឍគឺមានភាពប្រកួតប្រជែងខ្លាំង ដែលភាគច្រើនផ្តោតលើហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជាផ្លូវថ្នល់ ជាជាងផ្តោតលើការអភិរក្ស។ ជាញឹកញាប់ ក្រុមប្រឹក្សាឃុំត្រូវបានរង់ចាំការពន្យារពេលក្នុងការទទួលការឧបត្ថម្ភ។[101] ការឧបត្ថម្ភសម្រាប់ការអភិវឌ្ឍសំខាន់ៗគឺបានមកពីដៃគូអភិវឌ្ឍខ្នាតធំ ហើយត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹងដោយភ្នាក់ងារកណ្តាលរបស់រដ្ឋាភិបាល និងចែកចាយដោយតាមខ្សែរយៈផ្លូវការ។

នៅកម្រិតថ្នាក់ជាតិ ក្រសួងបរិស្ថានជាធម្មតាចូលរួមជាថវិកាមិនសូវគ្រប់គ្រាន់ក្នុងការកំណត់ថវិកាថ្នាក់ជាតិឡើយ ហើយមានផលប៉ះពាល់ផ្ទាល់ដល់មូលនិធិឃុំសង្កាត់។ មូលនិធិបរិស្ថាន និងសង្គមរបស់ក្រសួងបរិស្ថានគឺត្រូវបានផ្តល់ឲ្យការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍។ មូលនិធិនេះក៏ទាក់ទងទៅនឹងការបែងចែកថវិកាថ្នាក់ជាតិរបស់ក្រសួងបរិស្ថានដែរ។ ចំនួនដែលមានសម្រាប់សហគមន៍ លក្ខន្តិកៈដែលអាចទទួលបាន និងដំណាក់កាលនៃការចែកចាយធនធានតាមរយៈមូលនិធិនេះគឺមិនទាន់បានកំណត់ឲ្យច្បាស់នៅឡើយ។

លើសពីនេះ បើទោះបីជាច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានផ្តល់មូលនិធិសម្រាប់តំបន់ការពារធម្មជាតិ ដែលត្រូវបានរៀបចំ និងគ្រប់គ្រងដោយគណៈកម្មការដែលមានសហប្រធានជាក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ប៉ុន្តែវាមុខងាររបស់វានៅមិនទាន់ច្បាស់លាស់នៅឡើយ។

សហគមន៍ក៏បានទទួលការឧបត្ថម្ភមានកំណត់ពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយដល់ថ្លៃចំណាយផ្នែករដ្ឋបាល និងការបណ្តុះបណ្តាលដើម្បីពង្រឹងអភិបាលកិច្ច។ មានសហគមន៍មួយចំនួនបានចាប់ផ្តើមបង្កើតគ្រោងការណ៍នៃការគ្រប់គ្រងបដិភាគដើម្បីបង្កើតមូលនិធិសម្រាប់ការអភិវឌ្ឍ។ បច្ចុប្បន្ន មូលនិធិនេះនៅមានទំហំតូចនៅឡើយ (២៥ដុល្លាក្នុងមួយបដិភាគ) ហើយការចូលរួមក៏នៅមានកម្រិត (២០ទៅ៥០នាក់)។ កម្រិតផ្នែកអប់រំមូលដ្ឋាន ក្នុងសហគមន៍គឺត្រូវបានកត់សម្គាល់ថាជាឧបសគ្គមួយនៃការចូលរួម។ ការបណ្តុះបណ្តាល និងការអភិវឌ្ឍរយៈពេលយូរ មានភាពចាំបាច់ដើម្បីឲ្យផែនការនេះអាចប្រព្រឹត្តិទៅយ៉ាងពេញលេញ និងមាននិរន្តរភាព។[102]

## ការគោរពដល់ការអនុវត្តអភិបាលកិច្ចផ្ទៃក្នុងបែបប្រពៃណី

សហគមន៍ជនជាតិដើមភាគតិចផ្តល់តម្លៃខ្ពស់ទៅលើការជឿទុកចិត្តគ្នាទៅវិញទៅមក សូម្បីតែចំពោះក្រុមផ្សេងៗគ្នានៅក្នុងសហគមន៍ផ្សេងគ្នា ដែលនិយាយភាសាខុសគ្នាក៏ដោយ។ ពួកគេប្រតិបត្តិតាមការអនុវត្តអភិបាលកិច្ចផ្ទៃក្នុងបែបប្រពៃណី ឧទាហរណ៍ដូចជាក្រុមដែលងាយរងផលប៉ះពាល់ ដែលជាធម្មតាយល់ព្រមតាមការសម្រេចចិត្តរបស់ចាស់ទុំនៅក្នុងសហគមន៍។[103]កម្រិតនៃការអប់រំនៅតាមសហគមន៍ជនជាតិដើមភាគតិចភាគច្រើននៅមានកម្រិតទាប ដែលបណ្តាលឲ្យមានការយល់ដឹងអំពីដំណាក់កាលនៃការអភិវឌ្ឍនៅមានកម្រិត ជាពិសេសការយល់ដឹងលើផែនការអភិវឌ្ឍ និងគោលការណ៍អភិបាលកិច្ចដែលត្រូវបានកំណត់ដោយស្ថាប័នកណ្តាល។ កម្រិតមហិច្ឆតាសម្រាប់ការអភិវឌ្ឍក៏មានភាពខុសគ្នារវាងសហគមន៍ផ្សេងគ្នា។[104] ដោយហេតុថាមានភាពខុសគ្នាច្រើន ដូចនេះគំរូតែមួយនៃអភិបាលកិច្ចរបស់សហគមន៍តំបន់ការពារធម្មជាតិ គឺមិនអាចយកមកប្រើប្រាស់គ្រប់ស្ថានការណ៍បាននោះទេ។ ការគ្រប់គ្រងទៅតាមករណីនីមួយៗដែលមានការចូលរួមពីសហគមន៍ ការពឹងផ្អែកលើចំណេះដឹងមូលដ្ឋាន និងបញ្ហាផ្ទាល់នៅក្នុងមូលដ្ឋានទើបនាំឲ្យមានប្រសិទ្ធភាពក្នុងការឈានទៅរកគោលដៅរបស់សហគមន៍តំបន់ការពារធម្មជាតិប្រកបដោយភាពជោគជ័យ។

អាស្រ័យលើទីតាំង សហគមន៍មូលដ្ឋានមានលក្ខណៈ និងសក្តានុពលសង្គមខុសៗគ្នា ដោយហេតុនេះហើយ អភិបាលកិច្ចផ្ទៃក្នុងរបស់គេក៏មានភាពខុសគ្នាដែរ។ ក្នុងសហគមន៍ដែលមានចំនួនជនអន្តោប្រវេសន៍ច្រើន ដែលជាហេតុធ្វើឲ្យពួកគេមិនសូវមានទំនាក់ទំនងជាមួយនឹងសហគមន៍នោះ យើងសង្កេតឃើញថាសហគមន៍នោះមានការចូលរួមក្នុងអភិបាលកិច្ចសហគមន៍តិចតួច។ ហេតុការណ៍ប្រវត្តិសាស្រ្តថ្មីៗក្នុងប្រទេសកម្ពុជាក៏ហាក់ដូចជាមានឥទ្ធិពលយ៉ាងខ្លាំងលើទំនាក់ទំនងរបស់សហគមន៍ជាមួយនឹងអំណាច និងអាជ្ញាធរ។ ក្នុងករណីមួយចំនួន មេដឹកនាំសហគមន៍គិតថាវាជាកាតព្វកិច្ចរបស់ពួកគេក្នុងការទទួលយកនូវការសម្រេចចិត្តមួយចំនួនរបស់អាជ្ញាធរខេត្ត ឬថ្នាក់លើផ្សេងទៀត ជាពិសេសទាក់ទងទៅនឹងការប្រើប្រាស់ដី ឬសកម្មភាពសេដ្ឋកិច្ច ទោះបីជាការសម្រេចចិត្តទាំងនោះមិនមានផលល្អដល់ខាងសហគមន៍យ៉ាងណាក៏ដោយ។

### អនុសាសន៍ណែនាំ៖

i. ត្រូវធ្វើការបញ្ជាក់អំពីកម្រិតស្វ័យភាពដែលសហគមន៍តំបន់ការពារធម្មជាតិមានក្នុងការកំណត់ និងបង្កើតឯកសារលក្ខន្តិកៈផ្សេង (ដូចជា លក្ខន្តិកៈនៃសហគមន៍តំបន់ការពារធម្មជាតិ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ កិច្ចព្រមព្រៀងស្តីអំពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ រួមមានការកែសម្រួលលើគំរូ)។

ii. ផ្តល់យន្តការគណនេយ្យភាពបន្ថែមទៀតនៅក្នុងក្របខ័ណ្ឌច្បាប់ ដូចជារៀបចំកិច្ចប្រជុំឲ្យបានទៀងទាត់ជាមួយសមាជិកសហគមន៍ ធ្វើរបាយការណ៍ស្តីអំពីហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង។ ល។

iii. បញ្ជាក់ពីគោលការណ៍តម្លាភាពឲ្យបានទូលំទូលាយ និងច្បាស់លាស់ជាងមុននៅក្នុងនីតិកម្មសហគមន៍តំបន់ការពារធម្មជាតិ រួមមានតម្រូវការជាក់លាក់ ដូចជាសិទ្ធិរបស់សមាជិកសហគមន៍ក្នុងការទាញយកព័ត៌មានអំពីរចនាសម្ព័ន្ធក្នុងទាក់ទងនឹងសេចក្តីសម្រេចចិត្ត ដំណាក់កាល និងសកម្មភាពផ្សេងៗក្នុងសហគមន៍តំបន់ការពារធម្មជាតិ។

iv. ធ្វើការបែងចែកមូលនិធិឃុំសង្កាត់មួយចំណែកសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ រួមមានការគ្រប់គ្រសហគមន៍តំបន់ការពារធម្មជាតិ។

v. ផ្តល់អំណាច និងលើកទឹកចិត្តដល់សហគមន៍ដើម្បីឲ្យមានសម្លេងច្រើនជាមុនក្នុងដំណាក់កាលបែងចែកមូលនិធីឃុំសង្កាត់ (ឧទាហរណ៍៖ គិតគូរបញ្ចូលសមាជិកគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិយ៉ាងតិចចំនួន០១ នៅក្នុងក្រុមប្រឹក្សាឃុំ ក្នុងករណីដែលសហគមន៍តំបន់ការពារធម្មជាតិមានដែនសមត្ថកិច្ចគ្រប់គ្រងច្រើន ដូចនេះដំណាក់កាលនៃការបែងចែងមូលនិធិត្រូវបញ្ចូលយ៉ាងតិចអ្នកតំណាងមួយរូបពីដែនសមត្ថកិច្ចនីមួយៗ)។



# ៤. ការចូលរួម និងតំណាងពីខាងសហគមន៍

**និយមន័យ៖**

ក្នុងបរិបទសហគមន៍តំបន់ការពារព្រៃឈើក្នុងប្រទេសកម្ពុជា ការចូលរួមគឺសំដៅដល់ការចូលរួមយ៉ាងសកម្មរបស់សមាជិកសហគមន៍ក្នុងដំណាក់កាលដែលមានទំនាក់ទំនងទៅវិញទៅមក ហើយភាគីពាក់ព័ន្ធរួមគ្នាធ្វើការសម្រេចចិត្តលើបញ្ហាដែលពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ។ អ្នកតំណាង គឺសំដៅដល់ក្រុមផ្សេងគ្នានៅក្នុងសហគមន៍ដែលអាចចូលរួម មានសម្លេង និងឥទ្ធិពលក្នុងការសម្រេចចិត្តរួមគ្នា។ ក្រុមទាំងនេះអាចកំណត់បានដោយភេទ អាយុ ក្រុមជាតិពន្ធុ ស្ថានភាពសេដ្ឋកិច្ចសង្គម និងផ្សេងៗ។

**ច្បាប់ទាក់ទងនឹងការកាន់កាប់ដីធ្លី៖**

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧)

**ភាគីពាក់ព័ន្ធ៖**

មន្ទីរបរិស្ថានខេត្ត ក្រុមប្រឹក្សាឃុំ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ សមាជិកសហគមន៍

## បរិបទទូទៅ៖

ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិបានចែងខ្លះៗអំពីការចូលរួមរបស់សហគមន៍ដែរ។ ជាដំបូង ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិតម្រូវឲ្យមានការចូលរួមស្ម័គ្រចិត្តយ៉ាងតិច៦០%នៃចំនួនគ្រួសារសរុបក្នុងភូមិ។[105] មានវិធានការជាច្រើនដែលត្រូវមានការយល់ព្រម ៦០%ដូចជា៖ ដើម្បីឲ្យការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមបោះឆ្នោតយ៉ាងតិច ៦០%នៃចំនួនសរុបនៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិ តម្រូវឲ្យមានយ៉ាងតិច៦០%នៃចំនួនសរុបនៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិធ្វើការពិភាក្សានៅពេលដែលវាយតម្លៃលើសេចក្តីព្រាងលក្ខន្តិកៈ ក៏ដូចជាផែនការគ្រប់គ្រង តម្រូវឲ្យមានយ៉ាងតិច៦០%នៃចំនួនសរុបនៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិដើម្បីធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងលក្ខន្តិកៈនៃសហគមន៍តំបន់ការពារធម្មជាតិអាចធ្វើការកែសម្រួលបានលុះត្រាទទួលបានការយល់ព្រមពី៦០%នៃសមាជិកសុរបរបស់សហគមន៍តំបន់ការពារធម្មជាតិ។[106] វាជាទំនួលខុសត្រូវទូទៅរបស់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិក្នុងការទទួលបានការអនុញ្ញាតពីសមាជិកសហគមន៍តំបន់ការពារធម្មជាតិភាគច្រើនដើម្បីធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ។[107]

**60%**

ការចូលរួមដោយស្ម័គ្រចិត្តពីគ្រួសារសរុបនៅក្នុងភូមិមួយដើម្បីបង្កើត CPA

ក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិមិនកំណត់និមយន័យទូទៅរបស់ "ក្រុមដែលងាយរងគ្រោះ"ទេ ក៏ប៉ុន្តែបានទទួលស្គាល់យ៉ាងទូលំទូលាយ និងលើកទឹកចិត្តឲ្យមានការចូលរួមពីក្រុមមួយចំនួន ជាពិសេសក្រុមជនជាតិដើមភាគតិច និងស្ត្រី។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានកំណត់នូវសិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចក្នុងការចូលរួមក្នុងដំណាក់កាលនៃការសម្រេចចិត្តដែលទាក់ទងនឹងតំបន់ការពារធម្មជាតិ និងលើកទឹកចិត្តឲ្យមានការចូលរួមពីក្រុមជនជាតិដើមភាគតិចក្នុងការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិ។[108] ក៏ប៉ុន្តែ វានៅមិនទាន់មានការអធិប្បាយថាតើការចូលរួមនេះនឹងត្រូវបានទទួលស្គាល់ ឬមានការធានានៅក្នុងនីតិកម្មសហគមន៍តំបន់ការពារធម្មជាតិបានតាមរបៀបណានៅឡើយទេ។[109]

ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ ការចូលរួមរបស់ស្ត្រីត្រូវបានបញ្ជាក់យ៉ាងច្បាស់ជាងការចូលរួមរបស់ក្រុមដែលងាយរងគ្រោះព្រមទាំងមានភ្ជាប់ជាមួយវិធានការច្បាស់លាស់។ ស្ត្រីត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិដោយលើកទឹកចិត្តឲ្យឈរឈ្មោះជាសមាជិកគណៈកម្មាការនឹងចូលរួមក្នុងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងសហគមន៍តំបន់ការពារធម្មជាតិ។[110] ស្ត្រីក៏ត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការរៀបចំសេចក្តីព្រាងលក្ខន្តិកៈរបស់សហគមន៍តំបន់ការពារធម្មជាតិ ដែលជាដំបូងត្រូវរៀបរៀងឡើងដោយក្រុមសមាជិកសហគមន៍សំខាន់ៗ។[111]

## ចន្លោះប្រហោងផ្លូវច្បាប់៖

ដូចបានរៀបរាប់ខាងលើ ទោះបីក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិបានលើកទឹកចិត្តឲ្យមានការចូលរួមរបស់ក្រុមជនជាតិដើមភាគតិច និងស្ត្រី ក៏នៅតែមិនទាន់មានវិធានការជាក់ស្ដែងណាមួយដែលធានាឲ្យបាននូវការចូលរបស់ក្រុមជនជាតិដើមភាគតិចឡើយ។ លើសពីនេះទៀត ក្រុមដែលងាយរងគ្រោះនៅមិនទាន់បានរាប់បញ្ចូលក្រុមផ្សេងទៀតដែលក្រៅពីក្រុមជនជាតិដើមភាគតិច និងស្ត្រីឡើយ។ ក្រុមដែលងាយរងគ្រោះផ្សេងទៀតគួរតែរាប់បញ្ចូលដូចជាប្រជាជនក្រីក្រ និងក្រុមមនុស្សដែលត្រូវគេផាត់ចេញពីសង្គម។

## បញ្ហាការអនុវត្ត៖

### អ្នកតំណាងរបស់ក្រុមជនដែលងាយរងគ្រោះ

អ្នកតំណាងដែលជាគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិជាធម្មតាគឺជាសមាជិកដែលចូលរួមច្រើនជាងគេបំផុត និងក្រុមយុវជន។[112] ស្ត្រី មនុស្សចាស់ និងសមាជិកសហគមន៍ដែលមិនមែនជាថ្នាក់ដឹកនាំជាទូទៅមានតួនាទីតូចតាចក្នុងការងារផ្ទៃក្នុងរបស់សហគមន៍តំបន់ការពារធម្មជាតិ។[113] ការចូលរួមតិចតួចរបស់សមាជិកសហគមន៍នេះមួយផ្នែកដោយសារតែទំនៀមទំលាប់ក្នុងការចាំការសម្រេចចិត្តរបស់មនុស្សចាស់ ឬថ្នាក់ដឹកនាំ ម្យ៉ាងទៀតកង្វះខាតការអប់រំ និងការយល់ដឹងអំពីដំណាក់កាលនៃសហគមន៍តំបន់ការពារធម្មជាតិ ក៏អាចជាកត្តាមួយអាចធ្វើឲ្យមានការយល់ច្រឡំសម្រាប់សមាជិកសហគមន៍តំបន់ការពារធម្មជាតិទៅលើគោលបំណង និងប្រតិបត្តិការរបស់សហគមន៍តំបន់ការពារធម្មជាតិ។[114] ជាលទ្ធផល កង្វះខាតនៃតំណាងរបស់ក្រុមដែលងាយរងគ្រោះនៅក្នុងគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិបណ្ដាលឲ្យតម្រូវការរបស់ក្រុមងាយរងគ្រោះត្រូវបានមើលរំលង និងចាត់ទុកថាជាតម្រូវការបន្ទាប់បន្សំពីតម្រូវការរបស់ក្រុមដែលមានការចូលរួមច្រើន។[115]

ការរាប់បញ្ចូលស្ត្រី និងយុវជន ជាពិសេសក្នុងតួនាទីថ្នាក់ដឹកនាំ អាចផ្ដល់ជាផលប្រយោជន៍ដល់អភិបាលកិច្ច និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ ឧទាហរណ៍ ដោយសារតែក្រុមមនុស្សចាស់ភាគច្រើននៃក្រុមជនជាតិដើមភាគតិចមិនចេះភាសាខ្មែរ ពួកគាត់តែងតែមានផលវិបាកនៅក្នុងការស្វែងយល់អំពីបទបញ្ញត្តិរបស់សហគមន៍តំបន់ការពារធម្មជាតិ។[116] ការអនុញ្ញាតឲ្យមានការចូលរួមរបស់យុវជនមូលដ្ឋានជាជំនួយក្នុងការទំនាក់ទំនងជាមួយមនុស្សចាស់របស់អង្គការមិនមែនរដ្ឋាភិបាល គេសង្កេតឃើញថាមានប្រសិទ្ធភាព។[117] ការសិក្សាស្រាវជ្រាវក៏បានបង្ហាញឲ្យឃើញថា ស្ត្រីភាគច្រើនមានការយកចិត្តទុកដាក់ខ្លាំងលើនិរន្តរភាពក្នុងពេលដែលគ្រប់គ្រងធនធានធម្មជាតិ។ មធ្យោបាយមួយដើម្បីលើកទឹកចិត្តដល់ការចូលរួមពីស្ត្រី គឺតាមផ្នែកអប់រំ។ ក្នុងប្រទេសឡាវ នៅតាមភូមិដែលជាគោលដៅទទួលជំនួយផ្នែកអប់រំអស់រយៈពេលច្រើនឆ្នាំ គេសង្កេតឃើញថាចាប់ផ្ដើមមានភាពកើនឡើងនៃការចូលរួមរបស់ស្ត្រី។[118]

### ផលប៉ះពាល់ដែលបណ្ដាលមកពីភាពមានកម្រិតនៃសក្ដានុពលភាពពាណិជ្ជកម្ម

សក្ដានុពលភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម និងការទាញយលផលប្រយោជន៍សេដ្ឋកិច្ចគឺជាកត្តាសំខាន់ក្នុងការទាក់ទាញការចូលរួមនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ ភាពមានកម្រិតនៃសកម្មភាពពាណិជ្ជកម្មនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិបានធ្វើឲ្យសហគមន៍បាត់បង់ចំណូលចិត្តក្នុងការចូលរួមក្នុងសហគមន៍តំបន់ការពារធម្មជាតិ។[119] លើសពីនេះទៅទៀត ភាពមានកម្រិតនៃឱកាសសេដ្ឋកិច្ចបានធ្វើឲ្យមានកំណើននៃចំណាកស្រុករបស់យុវជន ដែលនាំឲ្យមានកង្វះខាតធនធានមនុស្សនៅក្នុងសហគមន៍។ សហគមន៍តំបន់ការពារធម្មជាតិដែលផ្ដួចផ្ដើម និងដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាលដូចជាយន្តការបែងចែកភាគហ៊ុនភាគច្រើនតម្រូវឲ្យមានការចូលរួមផ្នែកហិរញ្ញវត្ថុជាមុន ដែលជាហេតុបង្កឲ្យមានផលវិបាកក្នុងការចូលរួមរបស់សមាជិកសហគមន៍ដែលមានការអប់រំនិងធនធានទាប និងធ្វើឲ្យមានកំណើននៃវិសមភាពក្នុងសហគមន៍។[120]

### មធ្យោបាយក្នុងការលើកទឹកចិត្តឲ្យចូលរួម

សាមគ្គីភាព និងការខិតខំប្រឹងប្រែងនៅក្នុងសហគមន៍គឺជាគន្លឹះមួយដ៏សំខាន់សម្រាប់ការចូលរួម។[121] លើសពីនេះវិធានការក្នុងការផ្សព្វផ្សាយព័ត៌មានក៏ត្រូវបានសម្គាល់ថាអាចជះឥទ្ធិពលមកលើការចូលរួមផងដែរ។ ការធ្វើការទំនាក់ទំនងដោយផ្ទាល់ត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពជាងការចែកឯកសារ ឬក្រដាសស្នាមក្នុងការផ្សព្វផ្សាយព័ត៌មានដោយសារតែវាត្រូវបានគេមើលឃើញថាមិនលើកទឹកចិត្តឲ្យមានការចូលរួម។[122] បទពិសោធន៍ពីប្រទេសឡាវបានបង្ហាញអំពីផែនការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការរៀបចំការពិភាក្សាក្នុងសហគមន៍ដែលលើកទឹកចិត្តឲ្យមានការចូលរួមច្រើនជាមុន។ ឧទាហរណ៍នៃការយកចិត្តទុកដាក់ក្នុងការរៀបចំរួមមាន៖ ការរៀបចំកិច្ចប្រជុំរយៈពេលកន្លះថ្ងៃដើម្បីឲ្យសមប្រកបទៅនឹងកាលវិភាគនៃលទ្ធកម្មកសិកម្មរបស់សមាជិកសហគមន៍ និងគួរតែផ្ដល់នូវមធ្យោបាយធ្វើដំណើរដល់សហគមន៍ប្រសិនបើអាច។ លើសពីនេះទៅទៀត កិច្ចប្រជុំគួរតែរៀបចំនៅតំបន់ដែលផ្ដល់ភាពងាយស្រួលក្នុងការចេញចូលដូចជាសាលាឆទាន។[123] បន្ថែមពីនេះ ច្បាប់គួរតែអនុញ្ញាតឲ្យសហគមន៍កំណត់នូវយន្តការនៃការចូលរួមដែលសមស្របសម្រាប់ពួកគេ។

## ឧបសគ្គផ្នែកវប្បធម៌

ការធានាការចូលរួមប្រកបដោយប្រសិទ្ធភាព រួមមានការទទួលស្គាល់នូវវប្បធម៌ និងការអនុវត្តរបស់ក្រុមដែលមិនសូវមានអំណាច ដូចជាក្រុមជនជាតិដើមភាគតិច។ ក្រុមជនជាតិដើមភាគតិចនៅបន្តជួបបញ្ហាប្រឈមទាក់ទងទៅនឹងវប្បធមន៍ខ្មែរដែលជាវប្បធម៌គោល ដូចជាវប្បធម៌ខ្មែរនៅតែមិនមានការទទួលស្គាល់លើការធ្វើចម្ការវិលជុំរបស់ក្រុមជនជាតិដើមភាគតិច។ វិធីតែមួយដែលអាចដោះស្រាយបញ្ហានេះបានគឺតាមរយៈវិស័យអប់រំ។ ការអប់រំ ដែលបច្ចុប្បន្ននៅមានកង្វះខាតនៅក្នុងសហគមន៍ជនបទ អាចជាឧបករណ៍សំខាន់ក្នុងការលើកកម្ពស់នូវបរិយាប័ន្នភាព។ ការបង្រៀនពីការរស់នៅរបស់ក្រុមជនជាតិដើមភាគតិចនៅក្នុងសាលារៀនទូទាំងប្រទេសអាចបង្កើនឲ្យមានការយល់ដឹងពីគ្នា។[124]

### អនុសាសន៍ណែនាំ៖

**i.** ពង្រឹងការការពារនៅក្នុងក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីលើកទឹកចិត្ត និងធានាឲ្យបាននូវការចូលរួមពីក្រុមដែលងាយរងគ្រោះ។ វិធានការសម្រាប់ក្រុមជនជានដើមភាគតិច និងស្ត្រីអាចកែសម្រួលឲ្យប្រសើរជាងមុនបាន ឧទាហរណ៍ដូចជាតម្រូវឲ្យមានកិច្ចប្រជុំសហគមន៍ឲ្យបានទៀងទាត់ ដែលមានការចូលរួមពីសមាជិកសហគមន៍ទាំងអស់ ឬធ្វើការកំណត់ចំនួនឲ្យមានតំណាងពីក្រុមនីមួយៗនៅក្នុងថ្នាក់សេចក្តីសម្រេចចិត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ។

**ii.** រាប់បញ្ចូលក្រុមដែលងាយរងគ្រោះដទៃទៀត ក្រៅពីក្រុមដែលត្រូវបានកំណត់រួចរាល់ក្នុងក្របខ័ណ្ឌច្បាប់ (ដូចជា ប្រជាជនក្រីក្រ ក្រុមមនុស្សដែលត្រូវបានផាត់ចេញពីសង្គម)។

**iii.** បង្កើតស្តង់ដារអនុវត្តឲ្យបានច្បាស់ក្នុងការចែកចាយព័ត៌មានអំពីដំណាក់កាលនៃសហគមន៍តំបន់ការពារធម្មជាតិទៅឲ្យសហគមន៍មូលដ្ឋាន ដោយបញ្ជាក់អំពីវិធីសាស្ត្រទំនាក់ទំនងដែលមានលក្ខណៈសមរម្យសម្រាប់វប្បធម៌ និងយុទ្ធសាស្ត្រទំនាក់ទំនងដោយផ្ទាល់ដែលងាយស្រួលយល់។



# ៥. ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

## និយមន័យ៖

ការអភិវឌ្ឍផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលមានចែងអំពីបទបញ្ញាគ្រប់គ្រងដែលភ្ជាប់ជាមួយនឹងស្ថានការណ៍របស់មូលដ្ឋានផ្ទាល់ ដូចជាប្រភេទសកម្មភាពដែលត្រូវបានរំពឹងទុក និងទំហំរបស់សហគមន៍ និងកំណត់នូវសកម្មភាពណាដែលស្របច្បាប់ ឬត្រូវបានហាមដែលសកម្មភាពទាំងនោះបានទទួលបានការយល់ស្របពីសមាជិករបស់សហគមន៍ អនុញ្ញាតដោយក្រសួងបរិស្ថាន និងប្រតិបត្តិជាបន្តបន្ទាប់ដោយសមាជិកសហគមន៍។

## ច្បាប់គ្រប់គ្រង៖

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧)

## ភាគីពាក់ព័ន្ធ៖

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត អភិបាលនៃគណៈអភិបាលខេត្ត អភិបាលរងខេត្ត គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ និងសមាជិកសហគមន៍

## បរិបទ៖

ក្របខ័ណ្ឌគ្រប់គ្រងសម្រាប់សហគមន៍តំបន់ការពារធម្មជាតិគឺផ្អែកលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងបរិស្ថាន។ ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវតែអនុវត្តតាមផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលធ្វើឡើងដោយក្រសួងបរិស្ថាន ហើយបានពិនិត្យ និងកែសម្រួលយ៉ាងតិច៥ឆ្នាំម្តង ក៏ដូចជាអនុវត្តតាមផែនការសកម្មភាពរបស់តំបន់ការពារធម្មជាតិនីមួយៗដែលសហគមន៍តំបន់ការពារធម្មជាតិស្ថិតក្នុង ដែលធ្វើឡើងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។[125]

ក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិមួយ សហគមន៍ដែលចូលរួមត្រូវបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលត្រូវធ្វើការពិនិត្យរាល់ពេល៣ឆ្នាំម្តង ឬមុន៣ឆ្នាំប្រសិនបើមានការចាំបាច់។[126] (**មើលផ្នែក "ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ" សម្រាប់ការពិភាក្សាបន្ថែមលើដំណាក់ការនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដែលការអភិវឌ្ឍផែនការគ្រប់គ្រងគឺជាជំហានមួយក្នុងចំណោមជំហានផ្សេងទៀត**)។ ផែនការគ្រប់គ្រងមានសុពលភាពរយៈពេល៥ឆ្នាំ ហើយនឹងរំពឹងថាត្រូវមានផែនការសកម្មភាពសម្រាប់រយៈពេល៥ឆ្នាំ។[127] ផែនការគ្រប់គ្រងត្រូវបានកំណត់ឲ្យរយៈពេលមួយឆ្នាំដើម្បីអភិវឌ្ឍន៍ ហើយត្រូវបានរំពឹងទុកថាសហគមន៍តំបន់ការពារធម្មជាតិនឹងត្រូវការជំនួយផ្នែកជំនាញ និងសម្ភារៈពីអាជ្ញាធររដ្ឋាភិបាល និង/ឬពីដៃគូអភិវឌ្ឍដទៃទៀត។[128]

លក្ខខណ្ឌមួយចំនួនដើម្បីបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលបានចែងក្នុងការណែនាំរបស់សហគមន៍តំបន់ការពារធម្មជាតិមានដូចជា៖

១) ការបែងចែកតំបន់គ្រប់គ្រង

២) ការវាយតម្លៃលើធនធានធម្មជាតិ (បញ្ជីសារពើភ័ណ្ឌសហគមន៍ព្រៃឈើ)

៣) ការវាយតម្លៃលើតម្រូវការប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៍,

៤) ពិភាក្សាលើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ,

៥) ពិភាក្សាលើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាមួយសមាជិកសហគមន៍ ,

៦) ពិភាក្សាសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិជាមួយភាគីពាក់ព័ន្ធ (ដូចជា អាជ្ញាធររដ្ឋាភិបាល ដៃគូអភិវឌ្ឍ) និង

៧) ការទទួលស្គាល់ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិពីអាជ្ញាធររដ្ឋាភិបាល។[129]

ចំណុចមួយចំនួនគួរលើកឡើងក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ហើយគំរូសម្រាប់ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមានបានចែងនៅក្នុងសេចក្តីណែនាំស្តីពីសហគមន៍តំបន់ការពារធម្មជាតិ។[130] វាមិនមានការកំណត់ច្បាស់លាស់ឡើយថាផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិចាំបាច់ត្រូវរាប់បញ្ចូលរាល់ចំណុចទាំងអស់ដែលបានលើកឡើងក្នុងគំរូនៃផែនការគ្រប់គ្រង ក៏ប៉ុន្តែជាទូទៅក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិហាក់បីដូចជាមិនគាំទ្រការរៀបចំនូវផែនការគ្រប់គ្រងដែលមានលក្ខណៈសាមញ្ញ និងសមស្របទៅតាមសមត្ថភាពរបស់សហគមន៍មូលដ្ឋាននីមួយៗនោះទេ។ ឧទាហរណ៍ គេឃើញថាសហគមន៍តំបន់ការពារធម្មជាតិត្រូវបានតម្រូវឲ្យប្រមូល និងផ្តល់ពត៌មានជាច្រើនក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរបស់ពួកគេ។

ក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិបានកំណត់នូវសកម្មភាពដែលសហគមន៍តំបន់ការពារធម្មជាតិអាចធ្វើបាន និងសកម្មភាពផ្សេងទៀតដែលត្រូវបានហាមឃាត់។ សហគមន៍តំបន់ការពារធម្មជាតិមិនត្រូវរានឬធ្វើការលើដីព្រៃក្នុងតំបន់ពួកគេឡើយ មិនត្រូវធ្វើសកម្មភាពកសិកម្ម មិនត្រូវធ្វើការទាមទារកម្មសិទ្ធិដីធ្លី ឬលក់ ជួល បញ្ចាំ ប្រទាន ចែករំលែក ឬផ្ទេរដីសហគមន៍តំបន់ការពារធម្មជាតិឲ្យទៅបុគ្គល ឬនីតិបុគ្គលណាមួយឡើយ។[131] សហគមន៍តំបន់ការពារធម្មជាតិក៏មិនត្រូវដុតព្រៃ ឬទាញយកផល ឬ អនុផលធនធានធម្មជាតិណាមួយ (ឬនៅក្នុងដីតំបន់ការពារធម្មជាតិ) ឬធ្វើឲ្យមានការប៉ះពាល់ដល់រុក្ខជាតិ និងសត្វព្រៃឡើយ។[132] សហគមន៍តំបន់ការពារធម្មជាតិត្រូវធ្វើសកម្មភាពទាក់ទងទៅនឹងការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព អេកូទេសចរណ៍ ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍ និងអភិបាលកិច្ចក្នុងសហគមន៍។[133]

## ចន្លោះប្រហោងផ្នែកច្បាប់៖

### ភាពស្មុគស្មាញនៃពេលវេលាក្នុងការបង្កើតផែនការគ្រប់គ្រង

យោងតាមសេចក្ដីណែនាំស្ដីពីសហគមន៍តំបន់ការពារធម្មជាតិ ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិគឺជាដំណាក់កាលទី៦ ក្នុងប្រាំពីដំណាក់កាល នៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ហើយត្រូវធ្វើឲ្យបានរួចរាល់មុនពេលកិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានចុះហត្ថលេខា។ ប៉ុន្តែ ភាគច្រើនរាល់ពេលបង្កើតសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍តែងតែរំលងដំណាក់កាលបង្កើតផែនការគ្រប់គ្រង។ ទោះបីជាការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមិនគួរប្រើប្រាស់ពេលវេលាលើសពី១ឆ្នាំក៏ដោយ នៅក្នុងការអនុវត្តជាក់ស្ដែងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវរង់ចាំពី ៦ ទៅ៧ឆ្នាំ ក្រោយបានពេលសហគមន៍ត្រូវបានបង្កើតឡើងដើម្បីទទួលបានបានការអនុញ្ញាត (មើល "ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ" សម្រាប់ការពិភាក្សាបន្ថែម)។

### សិទ្ធិគ្រប់គ្រងនៅមានកម្រិត

សិទ្ធិគ្រប់គ្រងដែលបានផ្ដល់ឲ្យក្រោមក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្នគឺនៅមានកម្រិត។ សិទ្ធិក្នុងការធ្វើសកម្មភាពគួរតែមានការគិតគូរ និងលើកឡើងបន្ថែមនៅក្នុងពេលធ្វើវិសោធនកម្មលើក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិក្នុងពេលអនាគត ជាពិសេសសិទ្ធិដែលអាចធ្វើការចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ ដូចជាក្រុមហ៊ុនឯកជន និងស្ថាប័នហិរញ្ញប្បទាន សិទ្ធិគ្រប់គ្រងលើសកម្មភាពពាណិជ្ជកម្ម និងសិទ្ធិក្នុងការចូលរួមក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិទាំងមូលប្រកបដោយប្រសិទ្ធភាព (ជាជាងកម្រិតឲ្យមានការគ្រប់គ្រងនៅត្រឹមសហគមន៍តំបន់ការពារធម្មជាតិតូចមួយ)។ សិទ្ធិបន្ថែមទាំងនេះផងដែរគួរតែចែងឲ្យច្បាស់ក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

### ការបញ្ជាក់អំពីច្បាប់ដែលទាក់ទង

លើសពីនេះ ផ្នែកមួយដែលត្រូវការបញ្ជាក់បន្ថែមគឺថាតើច្បាប់ដែលទាក់ទងទៅនឹងព្រៃឈើ ដែលមានចែងអំពីសកម្មភាពព្រៃឈើដែលត្រូវបានអនុញ្ញាត និងហាមឃាត់ អាចប្រើប្រាស់បានក្នុងសហគមន៍តំបន់ការពារធម្មជាតិបានយ៉ាងដូចម្ដេច។ ច្បាប់ពាក់ព័ន្ធនឹងបញ្ហានេះគឺច្បាប់ស្ដីពីព្រៃឈើ (២០០២) ដែលបានកំណត់អំពីក្របខ័ណ្ឌសម្រាប់គ្រប់គ្រង ប្រមូលផល ប្រើប្រាស់ អភិវឌ្ឍន៍ និងអភិរក្សព្រៃឈើក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ។[134] គេសង្កេតឃើញថាមានមាត្រាមួយចំនួននៅក្នុងច្បាប់ស្ដីពីព្រៃឈើដែលអាចប្រើប្រាស់ក្នុងសហគមន៍តំបន់ការពារធម្មជាតិបាន ទោះបីជាប្រព័ន្ធតំបន់ការពារធម្មជាតិបច្ចុប្បន្នគឺស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថានក៏ដោយ។ ទាំងនេះនាំឲ្យមានការយល់ច្រឡំលើដែនសមត្ថកិច្ច និងអាចបង្កឲ្យមានវិវាទរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយធ្វើឲ្យអាជ្ញាធរទាំងពីរ និងសហគមន៍បន្តស្ថិតនៅក្រោមភាពមិនច្បាស់លាស់។ (មើលផ្នែក "ការចូលរួមក្នុងទីផ្សារ" ដើម្បីធ្វើការពិភាក្សាបន្ថែម។)

## បញ្ហានៃការអនុវត្ត៖

### ដំណាក់កាលនៃការអនុញ្ញាតមានរយៈពេលយូរ

ដំណាក់កាលនៃការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរួមមានការបង្កើតឯកសារព័ត៌មាន(ដូចជាគណនីសម្រាប់ធនធានក្នុងសហគមន៍ដែលមានស្រាប់) ជាមួយការពិភាក្សា ការយល់ព្រមពីសហគមន៍ (ដោយថ្នាក់ដឹកនាំ/អ្នកតំណាងរបស់សហគមន៍) និងការអនុញ្ញាត (ពីក្រសួងបរិស្ថាន)។ បច្ចុប្បន្ន ដំណើរការទាំងនេះគឺភាគច្រើនត្រូវបានសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល និងជាធម្មតាប្រើប្រាស់រយៈពេលលើសពី១ឆ្នាំ។[135] សហគមន៍ដែលខ្វះបទពិសោធន៍ និងស្ថិតនៅទីឆ្ងាយជារឿយៗ ត្រូវការប្រើប្រាស់ពេលវេលាប៉ុន្មានឆ្នាំបន្ថែមទៀតដើម្បីធ្វើការបង្កើតសកម្មភាពគ្រប់គ្រង។[136] ភាពយឺតយ៉ាវនេះ ធ្វើឲ្យសហគមន៍មិនមានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពសេដ្ឋកិច្ចសម្រាប់រយៈពេលយូរ ដូចជាការរៀបចំសកម្មភាពអេកូទេសចរណ៍ ឬសកម្មភាពជីវភាពដែលប្រកបដោយចីរភាព នៅក្នុងរយៈពេល ១៥ ឆ្នាំនៃសិទ្ធិកាន់កាប់ដីធ្លីដែលសហគមន៍ទទួលបាន។ ការណ៍នេះបានធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានលើសក្ដានុពលសេដ្ឋកិច្ចរបស់សហគមន៍តំបន់ការពារធម្មជាតិ និងជាលទ្ធផលធ្វើឲ្យសហគមន៍បាត់បង់ទំនុកចិត្ត និងការខិតខំប្រឹងប្រែងលើយន្តការសហគមន៍តំបន់ការពារធម្មជាតិ។

ការតម្រូវគោលបំណងផ្សេងៗគ្នាក្នុងសហគមន៍ត្រូវបានគេទទួលស្គាល់ថាជាផលវិបាកមួយនៅក្នុងការបង្កើតផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ។ សហគមន៍ក៏បានបង្ហាញភាពមិនពេញចិត្តចំពោះភាពស្មុគស្មាញនៃផែនការគ្រប់គ្រង។ អ្វីដែលសហគមន៍ត្រូវការក្នុងការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិគឺការសម្រួលឲ្យមានភាពសាមញ្ញជាងមុននៅក្នុងរចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការគ្រប់គ្រង (យកល្អគួរតែជាឯកសារសង្ខេបមួយដែលមានព័ត៌មានបច្ចេកទេសសមប្រកបនឹងសមត្ថភាពរបស់សហគមន៍មូលដ្ឋាន និងសកម្មភាពដែលបានដាក់ស្នើ) និងភាពបត់បែននៃទម្រង់ និងខ្លឹមសារ។[137]

## តម្រូវការនៃសមត្ថភាពគ្រប់គ្រងឲ្យប្រសើរជាងមុន

តាមការសង្កេតកន្លងមកបានបង្ហាញឲ្យឃើញថា សហគមន៍មិនមានភាពម្ចាស់ការលើផែនការគ្រប់គ្រងសហគមន៍របស់ខ្លួនផ្ទាល់នោះទេ ហើយភាគច្រើនពួកគេពឹងផ្អែកលើជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។ ភាពខុសគ្នារវាងការអនុវត្តតាមបែបប្រពៃណី និងគោលការណ៍គ្រប់គ្រងដែលបានមកពីគំរូមកពីបរទេសរបស់អង្គការមិនមែនរដ្ឋាភិបាលជាលទ្ធផលធ្វើឲ្យមានការយល់ច្រឡំ និងមានការសង្ស័យ។ នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលបានបញ្ចប់គម្រោងរបស់គេដែលផ្តល់ជំនួយដល់សហគមន៍តំបន់ការពារធម្មជាតិ កង្វះខាតនៃជំនាញ និងឆន្ទៈរបស់សហគមន៍បានធ្វើឲ្យសកម្មភាពគ្រប់គ្រងធ្លាក់ចុះ ឬសាបរលាភបាត់។[138] យ៉ាងណាក្តី ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងផ្នែកបណ្តុះបណ្តាលសមត្ថភាពមានតម្លៃយ៉ាងខ្លាំងសម្រាប់សហគមន៍ ឧទាហរណ៍ដូចជា ក្នុងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយគណនីយ្យភាព (គ្រប់គ្រងគណនីធនាគារ) ការកសាងសម្ព័ន្ធភាព (ការចែករំលែកធនធានរវាងភូមិជិតខាង) និងផ្នែកអប់រំស្តីពីបទបញ្ញត្តិសហគមន៍តំបន់ការពារធម្មជាតិ។[139]

ឥទ្ធិពលរបស់អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានក៏ត្រូវបានទទួលស្គាល់ថានៅមានកម្រិត ហើយទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិពិតជាសំខាន់សម្រាប់សហគមន៍ក្នុងការទទួលបាននូវការគាំទ្រ និងសន្តិសុខសម្រាប់សហគមន៍តំបន់ការពារធម្មជាតិរបស់ពួកគេ។ សហគមន៍ត្រូវបានផ្តល់យោបល់ឲ្យចូលរួមយ៉ាងសកម្ម និងធ្វើការបញ្ចុះបញ្ចូលអាជ្ញាធរមូលដ្ឋានទាក់ទងទៅនឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។[140] យ៉ាងណាមិញដោយសារតែការធ្វើវិមជ្ឈកម្ម អភិបាលនៃគណៈអភិបាលខេត្តបច្ចុប្បន្នមានអំណាចជាងមុនក្នុងការសម្រេចចិត្តលើបញ្ហាបច្ចេកទេសរបស់សហគមន៍តំបន់ការពារធម្មជាតិ។ អាជ្ញាធរមូលដ្ឋានចាំបាច់ត្រូវមានការបណ្តុះបណ្តាល និងធនធានគ្រប់គ្រាន់ដើម្បីសហការយ៉ាងមានប្រសិទ្ធភាពជាមួយសហគមន៍មូលដ្ឋាន ដើម្បីធានាថាផែនការគ្រប់គ្រងបានដាក់រួមបញ្ចូលការអនុវត្តល្អក្នុងសហគមន៍ផ្ទាល់ ជាជាងដាក់បញ្ចូលនូវការណែនាំរបស់អាជ្ញាធរថ្នាក់លើ។[141]



### អនុសាសន៍ណែនាំ៖

i. ពង្រឹងការការពារនៅក្នុងក្របខ័ណ្ឌសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីលើកទឹកចិត្ត និងធានាឲ្យបាននូវការចូលរួមពីក្រុមដែលងាយរងគ្រោះ។ វិធានការសម្រាប់ក្រុមជនជាតិដើមភាគតិច និងស្ត្រីអាចកែសម្រួលឲ្យប្រសើរជាងមុនបាន ឧទាហរណ៍ដូចជាតម្រូវឲ្យមានកិច្ចប្រជុំសហគមន៍ឲ្យបានទៀងទាត់ ដែលមានការចូលរួមពីសមាជិកសហគមន៍ទាំងអស់ ឬធ្វើការកំណត់ចំនួនឲ្យមានតំណាងពីក្រុមនីមួយៗនៅក្នុងថ្នាក់សេចក្តីសម្រេចចិត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ។

ii. ពង្រីកសិទ្ធិគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីអនុញ្ញាតឲ្យសហគមន៍តំបន់ការពារធម្មជាតិអាចចុះកិច្ចព្រមព្រៀងបានជាមួយភាគីទី៣ និងអាចគ្រប់គ្រងលើសកម្មភាពពាណិជ្ជកម្មដែលធ្វើឡើងដោយស្របច្បាប់ និងប្រកបដោយចីរភាពដែលស្របតាមផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនៅតាមតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាព។

iii. ពង្រីកសិទ្ធិគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដោយអនុញ្ញាតឲ្យសហគមន៍របស់សហគមន៍តំបន់ការពារធម្មជាតិអាចទទួល និងគ្រប់គ្រងថវិកាដោយផ្ទាល់ ដែលបានមកពីការវិនិយោគឯកជន និងសកម្មភាពពាណិជ្ជកម្មក្រោមសិទ្ធិនៃការប្រើប្រាស់ដី និងការទទួលការឧបត្ថម្ភពីប្រភពសាធារណៈ (ឧទាហរណ៍ អេកូទេសចរណ៍ ការប្រមូល និងប្រើប្រាស់ធនធានអនុផលព្រៃឈើ យន្តការហិរញ្ញប្បទានកាបូន មូលនិធិហិរញ្ញប្បទានអភិរក្ស និងវិនិយោគ ថវិកាដែលបានមកពីកិច្ចសន្យា ឬកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍ ជំនួយ ការបរិច្ចាគ មូលនិធិបរិស្ថាន និងសង្គម មូលនិធិឃុំសង្កាត់ និងចំណូលពីប្រភពផ្សេងទៀត)។

iv. ពង្រីកសិទ្ធិគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដើម្បីអនុញ្ញាតឲ្យសហគមន៍អាចចូលរួមបានយ៉ាងសកម្ម និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធររដ្ឋាភិបាល ទៅលើគ្រប់ផ្នែកនៃការកំណត់ផែនទីធនធាន ការកំណត់ផែនការប្រើប្រាស់ដី ការកំណត់បែងចែកតំបន់គ្រប់គ្រង ការធ្វើផែនការគ្រប់គ្រង និងការធ្វើល្បាតរួមក្នុងតំបន់ដែលពាក់ព័ន្ធក្នុងតំបន់ការពារធម្មជាតិ។

v. ស្វែងយល់ និងលើកទឹកចិត្ត ក៏ដូចជាដាក់កម្រិតសមហេតុផល លើសកម្មភាពជីវភាពរបស់ប្រជាជនជនជាតិដើមភាគតិច (ឧទាហរណ៍ ធ្វើពិពិធកម្មដី(កែប្រែដី) ដែលប្រើប្រាស់ដោយប្រជាជនជនជាតិដើមភាគតិច ដែលពួកគេតែងតែធ្វើសមាហរណកម្មដីផលិតកម្មរបស់ពួកគេចូលក្នុងតំបន់ដីព្រៃឈើ)។

vi. បញ្ជាក់ពីការប្រើប្រាស់ច្បាប់ស្តីពីព្រៃឈើក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងធ្វើវិសោធនកម្មលើក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិដើម្បីបំពេញនូវចំណុចខ្វះខាតដែលមាន។

# ៦. ការទទួលបាន (ស្វែងរកបាន) ទីផ្សារ

### និយមន័យ៖

ការទទួលបានទីផ្សារសំដៅដល់លទ្ធភាពរបស់សហគមន៍តំបន់ការពារធម្មជាតិមួយក្នុងការលក់ផលិតផល និងផ្តល់សេវាកម្មដែលបានមកពីការប្រើប្រាស់សហគមន៍តំបន់ការពារធម្មជាតិ។ លទ្ធភាពក្នុងការលក់នៅក្នុងទីផ្សារត្រូវអមដោយបទបញ្ញត្តិដែលច្បាស់លាស់ និងមានផលប្រយោជន៍ដល់សហគមន៍ រួមមានសកម្មភាពដែលទាក់ទងនឹងការបង់ពន្ធ ការអនុញ្ញាត ការដឹកជញ្ជូន និងការបង្កើតផលិតផល ហើយគួរមានរាប់បញ្ចូលនៅការផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចផងដែរ។[142]

### ច្បាប់គ្រប់គ្រង៖

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ(២០១៧) គោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ (២០១៧) ច្បាប់ស្តីពីព្រៃឈើ (២០០២) អនុក្រឹត្យលេខ៣៤ ស្តីពីការរៀបចំកាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅលើដែនសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់សម្បទានដីសេដ្ឋកិច្ច ការគ្រប់គ្រង និងដែនសមត្ថកិច្ចលើតំបន់ការពារធម្មជាតិ និងការអភិរក្សរុក្ខាប្រមាញ់ និងនេសាទ (២០១៦)

### ភាគីពាក់ព័ន្ធ៖

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ មន្ទីរពាណិជ្ជកម្មខេត្ត រដ្ឋបាលព្រៃឈើសហគមន៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល។

### បរិបទ៖

សហគមន៍ដែលរស់នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិអាចផ្គត់ផ្គង់ជីវភាពរបស់ពួកគេបានតាមរយៈមធ្យោបាយផ្សេងគ្នាអាស្រ័យទៅតាមតំបន់។[143] ក្នុងឆ្នាំ២០១៤ ចន្លោះពី៣០% ទៅ៤២%នៃប្រភពចំណូលរបស់គ្រួសារនៅក្នុងសហគមន៍មូលដ្ឋានបានមកពីធនធានព្រៃឈើ ដែលចំណូលនេះស្មើនឹង២៨០ដុល្លា ទៅ៣៤៥ដុល្លាក្នុងមួយឆ្នាំ។[144]

ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិអាចធ្វើឲ្យប្រសើរជាងមុនដើម្បីត្រៀមរួចរាល់ដល់ការសម្របសម្រួលនិងបើកលទ្ធភាពក្នុងការស្វែងរកទីផ្សារ ដែលជាកត្តាសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍រយៈពេលយូរអង្វែង។ មធ្យោបាយមួយដែលសហគមន៍តំបន់ការពារធម្មជាតិអាចបង្កើតចំណូលគឺតាមរយៈសកម្មភាពអេកូទេសចរណ៍។ បច្ចុប្បន្ន សកម្មភាពទាំងនេះគឺត្រូវបានកម្រិតត្រឹមតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។[145] សកម្មភាពអេកូទេសចរណ៍ដែលមានផលប៉ះពាល់តិចក៏អាចអនុញ្ញាតឲ្យធ្វើបានក្នុងតំបន់អភិរក្សដែរ ប្រសិនបើសកម្មភាពនោះត្រូវបានគេសម្គាល់ថាមានផលប៉ះពាល់ជាអប្បបរិមាដល់ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ។[146]

**30-42%**

ជីវភាពរស់នៅរបស់គ្រួសារមូលដ្ឋានបានមកពីធនធានដែលទទួលបានព្រៃ

កាលពីថ្មីៗនេះ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយជាតិទេសចរណ៍ឆ្នាំ២០១៩-២០៣០ ដែលបានផ្តល់ការណែនាំទូទៅលើការលើកទឹកចិត្តអេកូទេសចរណ៍តាមរយៈការអភិរក្សធនធានធម្មជាតិ និងការការពារបរិស្ថានដោយសហគមន៍មូលដ្ឋាន។[147] គោលនយោបាយនេះមានគោលបំណងសម្រេចបាននូវអេកូទេសចរណ៍ប្រកបដោយចីរភាពដោយបង្កើតផែនការអភិវឌ្ឍសម្រាប់គម្រោងធនធាន និងទេសចរណ៍ ស្វែងរកការគាំទ្រពីសហគមន៍មូលដ្ឋាន និងបង្កើនចំនួនភ្ញៀវទេសចរដែលទៅលេងតាមគោលទីតាំងដែលបានកំណត់។[148]

លក្ខខណ្ឌច្បាស់លាស់លើការប្រមូលផល ការផលិត ការដឹកជញ្ជូន និងលក់ផលិតផល និងអនុផលព្រៃឈើ (ឬក៏សំដៅថា ផលិតផលព្រៃឈើ និងធនធានអនុផលព្រៃឈើ) អាចពង្រឹងលទ្ធភាពសហគមន៍ក្នុងការស្វែងទីផ្សារ។[149] ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្នមានបទបញ្ញត្តិពាក់ព័ន្ធតែបន្តិចប៉ុណ្ណោះ ដូចជាការហាមឃាត់មិនឲ្យផលិតផល និងអនុផលធនធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ការដឹកជញ្ជូន និងការប្រមូលផលអនុផលធនធនធានធម្មជាតិដោយគ្មានការអនុញ្ញាត និងការប្រមូលសន្និធិផល អនុផលធនធម្មជាតិដោយគ្មានការអនុញ្ញាត។[150]

មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក៏មានកាតព្វកិច្ចត្រួតពិនិត្យអាជ្ញាប័ណ្ណ និងការអនុញ្ញាត ហើយរដ្ឋមន្ត្រីក្រសួងបរិស្ថានបានទទួលការអនុញ្ញាតឲ្យផ្តល់ការអនុញ្ញាត កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្រាប់គោលបំណងដែលមិនរកប្រាក់ចំណេញ។[151] ប៉ុន្តែនៅមិនទាន់មានបញ្ជាក់បន្ថែមទៀតលើប្រព័ន្ធនៃការអនុញ្ញាតនៅឡើយទេ។[152]

គួរកត់សម្គាល់យ៉ាងខ្លីផងដែរថា ការស្វែងរកទីផ្សារត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិជាច្រើន ដែលភាគច្រើននៅក្រៅវិសាលភាពនៃច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ។[153] នេះបានបង្កើតជាបញ្ហាប្រឈមមួយដល់សហគមន៍។

# ចន្លោះប្រហោងផ្នែកច្បាប់៖

## ការអនុញ្ញាត

កង្វះខាតនៃភាពច្បាស់លាស់ និងព័ត៌មានលម្អិតក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិគឺជាបញ្ហាដ៏សំខាន់ ដែលបង្កើតភាពមិនច្បាស់លាស់សម្រាប់សហគមន៍តំបន់ការពារធម្មជាតិដែលខិតខំប្រឹងប្រែងអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ចដែលមានភាពស្ថិតស្ថេរ។ វាក៏អាចបង្កើតឲ្យមានភាពមិនប្រាកដដល់ផលិតកម្មធនធានអនុផលព្រៃឈើនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ក្រសួងបរិស្ថានជាទូទៅ។ ក៏ប៉ុន្តែ ច្បាប់ស្តីពីព្រៃឈើបានចែងយ៉ាងច្បាស់អំពីការប្រមូលផល ការផលិត ការដឹកជញ្ជូន និងការលក់ផលិតផលព្រៃឈើ និងអនុផលព្រៃឈើដែលមានការអនុញ្ញាត និងការលើកលែង។[154]

ទោះបីក្នុងឆ្នាំ២០១៦ មានការផ្លាស់ប្តូរដែនសមត្ថកិច្ចរវាងក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើដែលនៅជាចំណុះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលភាគច្រើនដីព្រៃស្ថិតនៅក្រោមរដ្ឋបាលព្រៃឈើ ត្រូវបានផ្លាស់ប្តូរឲ្យទៅជាតំបន់ការពារធម្មជាតិដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថានវិញ[155] មាត្រាក្នុងច្បាប់ស្តីពីព្រៃឈើនៅតែបន្តមានប្រសិទ្ធភាពក្នុងការប្រើប្រាស់លើដីព្រៃដែលនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន រហូតច្បាប់ទាំងនេះត្រូវបានលុបចោល ឬត្រូវបានរំលងចោល/ជំនួសដោយច្បាប់ដទៃផ្សេងទៀត។ ឧទាហរណ៍ ក្នុងមាត្រា២៤ នៃច្បាប់ស្តីពីព្រៃឈើ បានចែងថា រូបវន្តបុគ្គល នីតិបុគ្គ ឬសហគមន៍ ដែលមានបំណង ប្រមូលផល អនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្មត្រូវមានលិខិតអនុញ្ញាតប្រមូលផលព្រៃឈើចេញដោយ រដ្ឋបាលព្រៃឈើ។ មាត្រានេះត្រូវបានមតិទូទៅយល់ថា នៅតែអាចបន្តមានការអនុវត្តបានយ៉ាងទូលំទូលាយនាពេលបច្ចុប្បន្ន ជាហេតុរក្សាអំណាចក្នុងការផ្តល់ការអនុញ្ញាតឲ្យរដ្ឋបាលព្រៃឈើ ដោយមិនគិតថាតើការប្រមូលផល អនុផលព្រៃឈើនោះធ្វើឡើងនៅក្នុងដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ឬក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាននោះទេក្រោយពេលដែលមានការផ្ទេរដែនសមត្ថកិច្ចក្នុងឆ្នាំ២០១៦។

សម្រាប់សហគមន៍តំបន់ការពារធម្មជាតិ វាបង្កើតជាស្ថានការណ៍ដ៏ច្របូកច្របល់មួយ ដែលមួយផ្នែកពួកគាត់ស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងបរិស្ថាន ប៉ុន្តែមួយផ្នែកទៀតនៅតែបន្តស្ថិតក្រោមដែនសមត្ថកិច្ចនៃរដ្ឋបាលព្រៃឈើ។ ដោយពិចារណាទៅលើទំនាក់ទំនងជាក់ស្តែងរវាងរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានចាប់តាំងពីឆ្នាំ២០១៦មក វាបានបង្កើតជាបញ្ហាជាក់ស្តែងក្នុងស្ថានការណ៍មួយចំនួន ដែលភាគីពាក់ព័ន្ធបានដាក់ចេញនូវវិធានការក្នុងការដោះស្រាយភាពមិនច្បាស់លាស់នេះ។ ជាឧទាហរណ៍ ភាគីពាក់ព័ន្ធមួយបានចែករំលែកថា ដរាបណាច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិមិនត្រូវបានធ្វើជាក់លាក់ ឬវិសោធនកម្មដើម្បីដោះស្រាយបញ្ហាមួយចំនួនដូចជាការចេញអាជ្ញាប័ណ្ណដឹកជញ្ជូន សហគមន៍ត្រូវសំអាងដោយស្វ័យប្រវត្តិទៅលើច្បាប់ស្តីពីព្រៃឈើ និងធ្វើការជាមួយរដ្ឋបាលព្រៃឈើចំណុះឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។[156] ជាលទ្ធផលភាពជាន់គ្នា និងអស្ថេរភាពនៃដែនសមត្ថកិច្ច និងខ្វះខាតនូវការណែនាំ សហគមន៍តំបន់ការពារធម្មជាតិជាច្រើនបន្តការលក់ធនធានអនុផលព្រៃឈើតែនៅក្នុងសហគមន៍របស់ខ្លួន ហើយធ្វើឲ្យការទទួលបានទីផ្សារបន្ថែមនៅមានកម្រិត។

ក្រសួងបរិស្ថានបានទទួលស្គាល់នូវបញ្ហាដែលកើតចេញពីបញ្ហាដែនសមត្ថកិច្ចនេះ ហើយថ្មីៗនេះបានចាប់ផ្តើមចេញនូវលិខិតពិសេសដែលអនុញ្ញាតសកម្មភាពពាណិជ្ជកម្មលើធនធានអនុផលព្រៃឈើស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ខណៈជាការប៉ុនប៉ងដោះស្រាយបញ្ហាដែលទទួលការសាទរ លិខិតទាំងនោះខ្វះមូលដ្ឋានច្បាប់ និងគ្រាន់តែជាដំណោះស្រាយបណ្តោះអាសន្នតែប៉ុណ្ណោះ។ ការដោះស្រាយភាពមិនស្របគ្នា និងចន្លោះប្រហោងច្បាប់តាមរយៈការសើរើក្របខ័ណ្ឌច្បាប់ នឹងផ្តល់ភាពច្បាស់លាស់ដែលចាំបាច់ និងធ្វើឲ្យប្រសើរឡើងកាន់តែខ្លាំងទៅលើសមត្ថភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ ក្នុងការពង្រឹងជីវភាពរស់នៅ។

## ការប្រើប្រាស់ដែលទទួលបានការអនុញ្ញាត

បើទោះបីជាសកម្មភាពអេកូទេសចរណ៍ត្រូវបានអនុញ្ញាតយ៉ាងជាក់ច្បាស់ ក្របខ័ណ្ឌច្បាប់ពុំបានបង្ហាញឲ្យបានគ្រប់គ្រាន់ពីរបៀបដែលសហគមន៍តំបន់ការពារធម្មជាតិអាចប្រើប្រាស់ធនធានធម្មជាតិ ដូចជាធនធានអនុផលព្រៃឈើសម្រាប់សកម្មភាពអាជីវកម្មឡើយ។ ការលក់ធនធានអនុផលព្រៃឈើហាក់ដូចជាត្រូវបានអនុញ្ញាត ប៉ុន្តែការអភិវឌ្ឍបន្ថែមនូវក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិជាការចាំបាច់ក្នុងការបង្ហាញពីយន្តការពាក់ព័ន្ធក្នុងការទទួលបានទីផ្សារ។[157]

## បញ្ហាក្នុងការអនុវត្ត៖

### យន្តការទីផ្សារដែលមានការអភិវឌ្ឍតិចតួច

ក្រៅតែពីការប្រើប្រាស់ផ្ទាល់ខ្លួន ជាទូទៅសហគមន៍លក់ធនធានអនុផលព្រៃឈើតាមរដូវ (ឧទាហរណ៍ ទឹកឃ្មុំ ជ័រទឹក ផ្តៅ និងសិប្បកម្មឬស្សីជាដើម) ក្នុងបរិមាណតិចតួចដើម្បីទទួលបានប្រាក់ចំណូល។ ដោយសារតែការអភិវឌ្ឍតិចតួចលើសមត្ថភាពពាណិជ្ជកម្មក្នុងការផ្តល់ផលិតផលទៀងទាត់ និងជាក់លាក់ និងកង្វះខាតការភ្ជាប់ទៅកាន់ទៅទីផ្សារប្រើប្រាស់ចុងក្រោយ ផលិតផលទាំងនោះត្រូវបានលក់ក្នុងទីផ្សារសហគមន៍តៗគ្នាក្នុងតម្លៃទាប និងជួនកាលក្នុងទីផ្សារដាច់ស្រយាលនៅក្នុងតំបន់ប្រជុំជន។ ការលក់ដូរក្រៅប្រព័ន្ធ (ទីផ្សារ) កើតមានជាញឹកញាប់ ដោយឈ្មួញកណ្តាលកើបយកប្រាក់ចំណេញយ៉ាងច្រើន ខណៈសហគមន៍ទទួលបានប្រាក់ចំណូលតិចតួចត្រឡប់មកវិញ។[158]

សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលធ្លាប់បានបង្ហាញការខកចិត្ត ចំពោះការខ្វះខាតនូវការណែនាំជាក់លាក់ និងការគាំទ្រក្នុងការបង្កើនផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ក៏ដូចជាលើការបញ្ជាក់ពីប្រភព និងតម្លៃសមស្រប។[159] មានករណីមួយចំនួន ដែលអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចម្បងៗបានរៀបចំការប្រមូលទិញទឹកឃ្មុំពីបណ្តារសហគមន៍ និងប្រើប្រាស់យន្តការផលិតផលសម្គាល់ភូមិសាស្ត្រដែលទទួលស្គាល់ជាអន្តរជាតិក្នុងការបញ្ជាក់ពីប្រភពនៃផលិតផលដើម្បីលក់ក្នុងទីផ្សារអឺរ៉ុប។[160] គំនិតផ្តួចផ្តើមទាំងនេះកំពុងតែពឹងផ្អែកលើមូលនិធិពីម្ចាស់ជំនួយ និងតម្រូវឲ្យមានការបន្តកសាងសមត្ថភាព ដើម្បីអាចអាស្រ័យរស់ដោយខ្លួនឯងបាន។[161]

បន្ថែមពីនេះ ការរៀបចំប្រាក់លើកទឹកចិត្តត្រឹមត្រូវ មានភាពចាំបាច់ក្នុងការកាត់បន្ថយសកម្មភាពខុសច្បាប់ និងជានាសកម្មភាពពាណិជ្ជកម្មប្រកបដោយចីរភាព។ ការបង្កើនឱកាសស្វែងរកប្រាក់ចំណូលស្របច្បាប់ អាចជួយក្នុងការកាត់បន្ថយសកម្មភាពកាប់ព្រៃឈើខុសច្បាប់ដើម្បីលក់ឈើអុសដែលមានតម្លៃទាប។[162] តាមរយៈការកើនឡើងនូវការកត់សម្គាល់ជាសកលនៃទំនួលខុសត្រូវសង្គមផ្នែកបរិស្ថានរបស់ក្រុមហ៊ុន មានក្រុមហ៊ុនឯកជនមួយចំនួនកំពុងស្វែងរកឱកាសក្នុងការបង្កើតភាពជាដៃគូជាមួយសហគមន៍មូលដ្ឋាន ដើម្បីបង្កើតសកម្មភាពពាណិជ្ជកម្មដែលផ្តល់ផលចំណេញទាំងសងខាង។ នៅកម្ពុជា ឧទារណ៍នេះរួមបញ្ចូលនូវសហគ្រាសដែលធ្វើការជាមួយសហគមន៍ក្នុងការអភិវឌ្ឍចំការដាំដុះឈើ ដើម្បីប្រមូលផលផ្លែឈើ ឬបន្លែជាក់លាក់ណាមួយ ឬដើម្បីប្រមូលផលដើមឬស្សីប្រកបដោយចីរភាព។ ការពង្រឹងការសហការនៃភាពជាដៃគូ រវាងសហគមន៍ និងភាគីឯកជនមានសារៈសំខាន់ ដោយហេតុតែមានការសង្កេតឃើញថាភាគីឯកជនមានឥទ្ធិពលច្រើនជាង ការប្រាស្រ័យទាក់ទងរបស់សហគមន៍មូលដ្ឋាន ក្នុងការធ្វើកំណែទម្រង់គោលនយោបាយជាតិ និងពន្លឿនការផ្លាស់ប្តូរដែលចាំបាច់ក្នុងការលើកកម្ពស់និរន្តរភាពនៃធនធានព្រៃឈើ។[163] ប៉ុន្តែវាក៏មានសារៈសំខាន់ដូចគ្នាផងដែរ ក្នុងការបណ្តុះសមត្ថភាពរបស់សហគមន៍មូលដ្ឋានក្នុងការប្រាស្រ័យទាក់ទងជាមួយភាគីឯកជន ដោយសារតែមានហានិភ័យជាដរាបលើការគ្រប់គ្រងដោយមនុស្សមួយក្តាប់តូច ពោលគឺការយកចំណេញលើសហគមន៍ដែលខ្វះបទពិសោធន៍ និងមានសមត្ថភាពទាប។

### កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានមានការខ្វះខាតនៅតំបន់ជនបទជាច្រើននៅកម្ពុជា ដែលបណ្តាលឲ្យមានការទទួលបានតិចតួចនូវធនធានសម្ភារៈ និងបច្ចេកវិទ្យា។ កង្វះខាតនូវកន្លែងស្តុកទុក និងទីតាំងកែច្នៃកម្រិតតម្លៃផលិតផលក្នុងទីផ្សារ។ ស្ថានភាពអន់ខ្សោយនៃផ្លូវ និងការតភ្ជាប់ ក៏ដូចជាកង្វះខាតនូវយានយន្តដឹកជញ្ជូន រឹតត្បិតដល់ការដឹកជញ្ជូនផលិតផលរបស់សហគមន៍។ ភាពអន់ខ្សោយនៃបរិក្ខារទូរគមនាគមន៍ និងការទទួលបានអ៊ីនធឺណិត កម្រិតការទទួលមានព័ត៌មានសំខាន់សម្រាប់ភាពជោគជ័យផ្នែកពាណិជ្ជកម្ម និងកម្រិតបន្ថែមទៀតការដឹងឮពីផលិតផលរបស់សហគមន៍។ បន្ថែមពីនេះ សេវាគាំទ្រចាំបាច់ដូចជាភ្នាក់ងារនិយ័តកម្មទីផ្សារមូលដ្ឋាន ឬការទទួលបានសេវាមីក្រូហិរញ្ញវត្ថុនៅមានកម្រិតខ្លាំង។[164]

### កង្វះខាតការកសាងសមត្ថភាពសហគមន៍មូលដ្ឋាន

ភាពអន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធសង្គមសម្រាប់ការអប់រំ បង្កជាឧបសគ្គយ៉ាងធំធេងក្នុងការកសាងសមត្ថភាពសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ តែងតែសង្កេតឃើញថាអត្រាអក្ខរកម្មទាប និងកង្វះខាតចំណេះដឹងផ្នែកពាណិជ្ជកម្ម ធ្វើឲ្យមានការប៉ះពាល់ដល់ការយល់ដឹងរបស់សហគមន៍លើតម្លៃនៃផលិតផល និងសមត្ថភាពក្នុងការរៀបចំសកម្មភាពពាណិជ្ជកម្មសមស្រប។ ជាលទ្ធផល សហគមន៍ពឹងផ្អែកយ៉ាងខ្លាំងលើអង្គការមិនមែនរដ្ឋាភិបាលក្នុងការរៀបចំសកម្មភាពផលិតកម្ម ក្រៅតែពីការប្រើប្រាស់ផ្ទាល់ខ្លួន ដែលជាហេតុធ្វើឲ្យការប្រឹងប្រែងក្នុងការហ្វឹកហ្វឺនមានភាពយឺតយ៉ាងក្នុងការវិវត្តទៅមុខ។[165] ក្រុមហ៊ុនឯកជនក៏បង្ហាញក្តីបារម្ភផងដែរក្នុងការធ្វើការជាមួយសហគមន៍។[166] ក្រៅតែពីការផ្តល់ការអប់រំមូលដ្ឋាន និងការបណ្តុះបណ្តាលជំនាញពាណិជ្ជកម្ម អាជ្ញាធរមូលដ្ឋានអាចផ្តល់ការគាំទ្រតាមរយៈការបង្កើតសហករ ឬសមាគមន៍មូលដ្ឋានសម្រាប់ផលិតករ អ្នកជំនួញ និងអ្នកនាំចេញ ដើម្បីអាចបែងចែកធនធាន និងបង្កើនអំណាចចរចាក្នុងទីផ្សារ។ រដ្ឋាភិបាល ក៏អាចពិចារណាជានាផ្តល់នូវលក្ខខណ្ឌមិនតឹងរឹង ដល់ការវិនិយោគឯកជនសំខាន់ៗមួយចំនួន។

បន្ថែមពីនេះ ទស្សនៈសង្គមទាក់ទាលើពាក្យ«សហគ្រាស» ជារឿយៗភ្ជាប់មកជាមួយនូវភាពអវិជ្ជមានដូចជាការបំផ្លិចបំផ្លាញទីតាំងបៃតង និងការកាប់បំផ្លាញព្រៃឈើ។ ការសង្ស័យលើសកម្មភាពពាណិជ្ជកម្ម មានពាសពេញសហគមន៍ដែលឈានទៅដល់ភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយសកម្មភាពទាំងនេះ។ វាត្រូវការការរួមបញ្ចូលគ្នានូវនិយ័តកម្មដ៏មានប្រសិទ្ធភាព ការបណ្តុះបណ្តាល និងការត្រួតពិនិត្យដើម្បីអភិវឌ្ឍបរិស្ថានសម្រាប់បែដលឈានដល់ការសហការ និងការប្រាស្រ័យទាក់ទងបែបចីរភាពរវាងសហគមន៍ និងសហគ្រាសឲ្យបានកាន់តែទូលំទូលាយ។[167]

## អនុសាសន៍ណែនាំ៖

**i.** បញ្ជាក់ និងអភិវឌ្ឍក្របខ័ណ្ឌច្បាប់ស្តីពីការទទួលបានទីផ្សារសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ (អាជ្ញាធរទទួលខុសត្រូវ បទប្បញ្ញត្តិជាក់លាក់ជាដើម) និងធានាដោះស្រាយវិវាទស្តីពីដែនសមត្ថកិច្ច និងដែនសមត្ថកិច្ចជាន់គ្នារវាងបណ្តាក្រសួង និងរដ្ឋបាល។

**ii.** បញ្ជាក់ពីការអនុវត្តច្បាប់ស្តីពីព្រៃឈើទៅលើសហគមន៍តំបន់ការពារធម្មជាតិ បញ្ជាក់ឲ្យច្បាស់លាស់ពីដែនសមត្ថកិច្ចគ្រប់គ្រងនៃក្រសួងបរិស្ថាន និងអំណាចក្នុងការអនុញ្ញាតលើរាល់ផ្នែកទាំងអស់នៃសកម្មភាពពាណិជ្ជកម្មធនធានអនុផលព្រៃឈើ ការប្រមូលផល និងដឹកជញ្ជូននៅក្នុង និងមានប្រភពពីសហគមន៍តំបន់ការពារធម្មជាតិ និងតំបន់ការពារធម្មជាតិគ្រប់គ្រងដោយក្រសួងបរិស្ថាន។

**iii.** កាត់បន្ថយហានិភ័យសម្រាប់សហគមន៍ក្នុងការស្វែងរកភាពជាដៃគូជាមួយវិស័យឯកជន ដើម្បីទប់ស្កាត់ផលប៉ះពាល់បណ្តាលមកពីអតុល្យភាពនៃអំណាច ឬការកាន់កាប់ដោយអភិជនមួយក្រុមតូច។

**iv.** ផ្តល់ការធានាបែបណាមួយដល់ភាគីឯកជនដោយរដ្ឋាភិបាលដើម្បីធានាដល់សុវត្ថិភាពក្នុងការវិនិយោគរបស់សហគ្រាសដើម្បីអាចសម្រេចបាននូវលក្ខខណ្ឌស្តីពីចីរភាពដែលបានដាក់ចេញ។

**v.** ផ្តល់តាមរយៈរដ្ឋាភិបាលនូវធនធានបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការគាំទ្រសហគមន៍មូលដ្ឋានក្នុងការបង្កើតអាជីវកម្មមូលដ្ឋាន ក៏ដូចជាការកសាងសមត្ថភាពស្តីពីការគ្រប់គ្រងពាណិជ្ជកម្ម និងការអភិវឌ្ឍផលិតផលប្រកបដោយចីរភាព។



# ៧.ការបែងចែកផលប្រយោជន៍

### និយមន័យ៖

យន្តការនៃការបែងចែកផលប្រយោជន៍រួមមានការកំណត់ផលប្រយោជន៍ដែលកើតចេញពីសកម្មភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ និងការបែងចែករវាងសមាជិកសហគមន៍ខ្លួនឯងផ្ទាល់ ( ការបែងចែកផលប្រយោជន៍ខ្សែដេក ) និងរវាងសហគមន៍ និងរដ្ឋ/ភាគីទី៣ ( ការបែងចែកផលប្រយោជន៍ខ្សែឈរ ) និងការធានាពីគណនេយ្យភាពនៃកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍ ដូចជាយន្តការធានាការចូលរួមជាសាធារណៈ និងតម្លាភាព។[168]

### ច្បាប់គ្រប់គ្រង៖

ប្រកាសស្ដីពីគោលការណ៍ណែនាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ( ២០១៧ )

### ភាគីពាក់ព័ន្ធ៖

រតនាគារជាតិ អាជ្ញាធរខេត្ត ក្រុមប្រឹក្សាឃុំ សមាជិកសហគមន៍

## បរិបទ៖

ជាទូទៅ ក្របខ័ណ្ឌច្បាប់បានណែនាំថាការបែងចែកផលប្រយោជន៍គួរតែធ្វើឡើងដោយមានតម្លាភាព គណនេយ្យភាព និងសមភាព ប៉ុន្តែពុំបានបញ្ជាក់ពីថាការបែងចែកផលប្រយោជន៍នោះគួរធ្វើឡើងដោយរបៀបណាឡើយក្នុងសហគមន៍តំបន់ការពារធម្មជាតិ[169] ក្របខ័ណ្ឌនេះទំនងជារំពឹងថាការរៀបចំបែងចែកផលប្រយោជន៍នឹងត្រូវអភិវឌ្ឍឡើងដោយសហគមន៍តំបន់ការពារធម្មជាតិនីមួយៗ និងត្រូវបានបញ្ជាក់ក្នុងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រង។[170]

ទស្សនៈមួយយល់ឃើញថា ក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិអនុញ្ញាតឲ្យសហគមន៍មានភាពបត់បែនក្នុងការកំណត់យន្តការសមស្របក្នុងការបែងចែកផលប្រយោជន៍ក្នុងបរិបទនៃសហគមន៍រៀងៗខ្លួន។ យ៉ាងណាក្ដី វិធីនេះរំពឹងលើសហគមន៍តំបន់ការពារធម្មជាតិនីមួយៗក្នុងការអភិវឌ្ឍ និងអនុវត្តការបែងចែកផលប្រយោជន៍ក្នុងសហគមន៍ដែលគ្រប់គ្រាន់ និងប្រកបដោយសមធម៌ក្នុងសហគមន៍របស់ខ្លួន ហើយនិងរំពឹងថាសហគមន៍មានអំណាច និងមានសមត្ថភាពក្នុងការចរចារលើការរៀបចំជាមួយតួអង្គពាណិជ្ជកម្មខាងក្រៅ។

## ចន្លោះប្រហោងផ្លូវច្បាប់៖

### ការខ្វះខាតគោលការណ៍ណែនាំ

ខណៈក្របខ័ណ្ឌច្បាប់ស្ដីពីសហគមន៍តំបន់ការពារធម្មជាតិ លើកឡើងពីការបែងចែកផលប្រយោជន៍ជាទូទៅ ពុំមានផ្ដល់ខ្លឹមសារលំអិតគ្រាប់គ្រាន់ សម្រាប់សហគមន៍ និងភាគីពាក់ព័ន្ធដទៃនូវមូលដ្ឋានគ្រឹះរឹងមាំក្នុងការរៀបចំការបែងចែកផលប្រយោជន៍ខ្សែរដេក និងខ្សែរឈរ។

### ការស្ទួរនាំពីខាងក្រៅ

ការតាមដានទៅលើការបែងចែកផលប្រយោជន៍ ត្រូវបានមើលឃើញថាចាត់ចែងដោយគណៈកម្មការរបស់សហគមន៍តំបន់ការពារធម្មជាតិ ដោយមានការស្ទួរនាំតិចតួចពីខាងក្រៅ។ ការមានការស្ទួរនាំតិចតួចនេះធ្វើឲ្យមានកម្រិតទៅលើទំនោរនៃការធានាការបែងចែកផលប្រយោជន៍ដោយស្មើរភាព និងសមភាព ដោយសារតែភាពមានកម្រិតនៃសមត្ថភាពរបស់គណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ និងភាពមានកម្រិតនៃអំណាចជាក់ស្ដែងក្នុងការតទល់ជាមួយភាគីពាក់ព័ន្ធខាងក្រៅដូចជារដ្ឋាភិបាល និងតួអង្គភាគីឯកជន។[171]

## បញ្ហាក្នុងការអនុវត្ត៖

### វិសមភាពដែលមានជាស្រេច

វិសមភាពដែលមានជាស្រេចក្នុងសហគមន៍អាចនឹងមានសភាពធ្ងន់ធ្ងរបើសិនជាមិនមានការរៀបចំដោយប្រុងប្រយ័ត្នក្នុងការរៀបចំយន្តការបែងចែកផលប្រយោជន៍ ដែលក្នុងសហគមន៍តំបន់ការពារធម្មជាតិមួយភាគធំកំពុងស្ថិតក្នុងដំណាក់កាលដំបូងបង្អស់ ។ ជាឧទាហរណ៍ កម្មវិធីបដិភាគដែលអភិវឌ្ឍដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានការចូលបដិភាគហិរញ្ញវត្ថុជាមុន អាចមានការចូលរួមបានតែពីសមាជិកសហគមន៍ដែលមានចំណូលក្នុងកម្រិតណាមួយប៉ុណ្ណោះ។ ជាលទ្ធផល ផលប្រយោជន៍ដែលទទួលបានពីសកម្មភាពគ្រប់គ្រង បានតែទៅលើ «ម្ចាស់ហ៊ុន» ជាជាងការផ្ដល់ផលប្រយោជន៍ស្មើៗគ្នាដល់សមាជិកសហគមន៍ទាំងអស់។[172]

## ទំនាស់ផលប្រយោជន៍

បន្ថែមពីនេះ មានការព្រួយបារម្ភលើកឡើងផងដែរជុំវិញទំនាស់ផលប្រយោជន៍រវាងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ក្នុងករណីដែលមេដឹកនាំសហគមន៍មូលដ្ឋានជាអ្នកទទួលបានធនធាន ឬផលប្រយោជន៍ ជាជាងសហគមន៍ទាំងមូល។[173] តម្លាភាពក្នុងការគ្រប់គ្រងធនធានគ្រប់កម្រិតទាំងអស់ រួមមានក្នុងសហគមន៍ រវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធត្រូវតែធ្វើឲ្យប្រសើរឡើង។

## ការកសាងសមត្ថភាពសហគមន៍ និងអាជ្ញាធរ

ឆន្ទៈ និងសមត្ថភាពរឹងមាំរបស់សហគមន៍ក្នុងការចូលរួមក្នុងការបែងចែកផលប្រយោជន៍មានសារៈសំខាន់ណាស់ក្នុងការធានានូវបរិយាប័ន្នភាពរបស់សមាជិកសហគមន៍នៅក្នុងកម្មវិធីបែងចែកផលប្រយោជន៍។ ឆន្ទៈ និងសមត្ថភាពរបស់សហគមន៍នេះអាចពង្រឹងបានតាមរយៈសកម្មភាពនានាដែលពង្រឹងសិទ្ធិអំណាចដល់សហគមន៍។

បន្ថែមពីនេះ ការបែងចែកអំណាច និងទំនួលខុសត្រូវដែលត្រឹមត្រូវនៅតាមកម្រិតរដ្ឋបាលនានា ក៏ដូចជាទំនាក់ទំនងបើកចំហរ និងអាចពឹងពាក់បានរវាងកម្រិតផ្សេងៗនៃរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានមានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងប្រតិបត្តិការនៃយន្តការបែងចែកផលប្រយោជន៍ ដែលតម្រូវឲ្យមានការអនុវត្តអភិបាលកិច្ចល្អនៅគ្រប់កម្រិតទាំងអស់ និងមានទំនាក់ទំនងជាប់លាប់រវាងភាគីពាក់ព័ន្ធ។[174]

ការកសាងទំនាក់ទំនងរវាងសហគមន៍ និងអាជ្ញាធរត្រូវការពេលវេលា និងកិច្ចខិតខំប្រឹងប្រែង។ កិច្ចប្រឹងប្រែងទាំងឡាយដែលស្តីពីការបែងចែកផលប្រយោជន៍គួរតែរួមបញ្ចូលការកសាងសមត្ថភាពសម្រាប់សហគមន៍ និងអាជ្ញាធរ។ វារួមបញ្ចូលមិនត្រឹមតែការបណ្តុះបណ្តាលខ្លឹមសារស្តីពីការរៀបចំបែងចែកផលប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែគួរមានផងដែរនូវនីតិវិធីក្នុងការគ្រប់គងការរៀបចំទាំងនោះ ក៏ដូចជាព័ត៌មានស្តីពីការបែងចែកសំខាន់ៗ និងការសហការរវាងអាជ្ញាធរ និងសហគមន៍។ ការបណ្តុះបណ្តាលលើបញ្ហាទាំងនេះ អាចរួមបញ្ចូលទាំងអាជ្ញាធរ និងសហគមន៍ក្នុងពេលតែមួយ ដើម្បីពង្រឹងទំនាក់ទំនងរបស់ពួកគេ។

### អនុសាសន៍ណែនាំ៖

i. ផ្តល់គោលការណ៍ណែនាំលម្អិតស្តីពីកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍ខ្សែដេក និងខ្សែឈរ (ឧទាហរណ៍ កត្តាដែលត្រូវពិចារណា ជម្រើស គំរូ បទដ្ឋានអប្បរមា ទម្រង់គំរូនៃកិច្ចព្រមព្រៀងបែងចែកផលប្រយោជន៍)។

ii. ដាក់ចេញនូវបទដ្ឋានតម្លាភាពដែលលម្អិត ដែលរួមបញ្ចូលការតាមដានជាសកម្មដោយស្ថាប័នឯករាជ្យ និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការរៀបចំបែងចែកផលប្រយោជន៍ ដែលអនុវត្តទៅលើភាគីពាក់ព័ន្ធទាំងអស់ (អាជ្ញាធរមូលដ្ឋាន ភាគីឯកជន និងសហគមន៍។ល។)។

iii. បង្កើនសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានតាមរយៈកម្មវិធីអប់រំ ត្រួតពិនិត្យ និងការទទួលបានផលប្រយោជន៍ និងប្រសិទ្ធភាពនៃការអនុវត្ត។

iv. រៀបចំការកសាងសមត្ថភាពរួមសម្រាប់សហគមន៍ និងអាជ្ញាធរពីតួនាទីដែលខ្លួនមានក្នុងការសម្របសម្រួល និងការបែងចែកផលប្រយោជន៍ដោយមានប្រសិទ្ធភាព។

v. កសាងទំនុកចិត្តជាមួយសហគមន៍តាមរយៈការសម្របសម្រួលកម្មវិធីបែងចែកផលប្រយោជន៍ និងភាពជាដៃគូជុំវិញជំនួយបច្ចេកទេសក្នុងការអនុវត្តកម្មវិធី។

# ៨.ដំណោះស្រាយវិវាទ

### និយមន័យ៖

សិទ្ធិរបស់សមាជិកសហគមន៍តំបន់ការពារធម្មជាតិក្នុងការទទួលបានយន្តការដោះស្រាយវិវាទដោយយុត្តិធម៌ អាចរំពឹងទៅលើវិធីសាស្ត្រដោះស្រាយវិវាទបែបប្រពៃណី ក៏ដូចជាការធានាក្នុងការទទួលបានយន្តការដោះស្រាយវិវាទតាមប្រព័ន្ធយុត្តិធម៌ (តុលាការ/អង្គជំនុំជម្រះ) ជាមធ្យោបាយក្នុងការដោះស្រាយបញ្ហាក្នុងដំណាក់កាលលំបាក។

### ច្បាប់គ្រប់គ្រង៖

ច្បាប់ស្តីពីតំបន់កាពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍ណែនាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧) គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ (២០២០)

### ភាគីពាក់ព័ន្ធ៖

ក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរបរិស្ថានខេត្ត សមាជិកសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល តួអង្គភាគីឯកជន

## បរិបទ៖

យន្តការ និងស្ថាប័នដោះស្រាយវិវាទជាច្រើនត្រូវបានចែងក្នុងក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ។ ជាទូទៅ គណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ អាចដោះស្រាយវិវាទក្នុងសហគមន៍ខ្លួនឯងផ្ទាល់ ប៉ុន្តែក៏អាចស្វែងរកការគាំទ្រពីខាងក្រៅផងដែរ។[175] ស្ថាប័នរដ្ឋាភិបាលមួយចំនួនក៏ទទួលភារកិច្ចក្នុងការពន្លឿនការដោះស្រាយវិវាទក្នុងសហគមន៍តំបន់ការពារធម្មជាតិផងដែរ ដែលក្នុងនោះរួមមានអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន នាយកដ្ឋានជីវភាពសហគមន៍ (ដែលស្ថិតនៅចំណុះអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន) មន្ទីរបរិស្ថានខេត្ត និងអគ្គនាយកតំបន់ការពារធម្មជាតិ។[176] យ៉ាងណាក្តី ពុំមានឡើយការចែងនូវនីតិវិធី ឬបទដ្ឋានណែនាំពីរបៀបដែលស្ថាប័នរដ្ឋាភិបាលទាំងនេះដោះស្រាយវិវាទ។[177]

បន្ថែមពីនេះ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានបង្កើតគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីជួយដោះស្រាយវិវាទទាក់ទងនឹងតំបន់ការពារធម្មជាតិ។[178] គណៈកម្មាធិការនេះមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន ដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ប៉ុន្តែ ពុំមានការចង្អុលបង្ហាញណាមួយដែលអះអាងថាគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិនេះមានដំណើរការសមស្របឡើយ។

នាខែកក្កដា ឆ្នាំ២០២០ សម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាឲ្យក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចេញប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋមូលដ្ឋានដែលកាន់កាប់ដីក្នុងតំបន់ការពារធម្មជាតិ និងតំបន់ព្រៃ អស់រយៈពេលជាយូរមកហើយ ដើម្បីបង្កើនដីបម្រុងសម្រាប់ការប្រើប្រាស់ដោយសម្ព័ហភាពដោយសហគមន៍មូលដ្ឋានឲ្យបាន១០% (ដប់) ភាគរយ បន្ថែមទៀត និងធ្វើសកម្មភាពប្រឆាំងការទន្ទ្រានដីនិងព្រៃខុសច្បាប់ (**មើលផ្នែក «កម្មសិទ្ធិដីធ្លី» សម្រាប់ការពិភាក្សាបន្ថែម**)។[179] វិធីក្នុងការអនុវត្តបទបញ្ជានេះ ក៏ដូចជាវិធីសាស្ត្រក្នុងការដោះស្រាយវិវាទដែលនឹងអាចកើតឡើងអំឡុងពេលអនុវត្តបទបញ្ជានេះ នៅពុំទាន់មាននៅឡើយទេ។

> “ក្នុងខែធ្នូ ឆ្នាំ២០២០ គោលការណ៍ណែនាំថ្មីមួយទៀតស្តីពីការដោះស្រាយវិវាទ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានផ្សព្វផ្សាយ។.”

ក្នុងខែធ្នូ ឆ្នាំ២០២០ គោលការណ៍ណែនាំថ្មីមួយទៀតស្តីពីការដោះស្រាយវិវាទ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានផ្សព្វផ្សាយ។ គោលបំណងដែលបានចែងក្នុងគោលការណ៍នោះ គឺការណែនាំសមាជិកសហគមន៍ និងគណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិពីការគ្រប់គ្រងវិវាទ ស្វែងរកដំណោះស្រាយ និងជ្រើសយកការសម្រុះសម្រួល។ ការយល់ដឹង និងប្រសិទ្ធភាពនៃគោលការណ៍នេះនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ។

## ចន្លោះប្រហោងផ្នែកច្បាប់៖

### ការបែងចែកសិទ្ធិ និងកាតព្វកិច្ចគ្រប់គ្រងដែលមិនមានការសម្របសម្រួល

អស់រយៈពេលជាយូរ វិវាទដីធ្លីបន្តជាបញ្ហាចម្បងនៅកម្ពុជា ដែលក្នុងនោះសហគមន៍តំបន់ការពារធម្មជាតិក៏មិនអាចចៀសរួចផងដែរ។ នៅពេលមានវិវាទដីធ្លីកើតមានឡើង សហគមន៍តំបន់ការពារធម្មជាតិជាទូទៅស្ថិតក្នុងស្ថានភាពពុំមានប្រៀបឡើយ ដោយប្រឈមទៅនឹងភាគីក្រៅសហគមន៍ដែលមានការគាំទ្រផ្លូវការក្នុងការកាន់កាប់ដីវិវាទ ដូចជាកម្មសិទ្ធិដី  កិច្ចព្រមព្រៀងសម្បទាន ឬការទាមទារប្រើប្រាស់ដោយមានការអនុញ្ញាត។ សហគមន៍តំបន់ការពារធម្មជាតិមានចំណុចខ្សោយដោយឡែករបស់ខ្លួនចំពោះស្ថានការណ៍ខាងលើនេះ ដោយសារតែពួកគាត់ពុំទទួលបានកម្មសិទ្ធិដី ឬការទទួលស្គាល់សិទ្ធិកាន់កាប់ដីតាមរយៈការបង្កើតសហគមន៍តំបន់ការពារឡើយ ពោលពួកគាត់មានត្រឹមតែកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថានតែប៉ុណ្ណោះ។ សហគមន៍តំបន់ការពារធម្មជាតិ ក៏ពុំត្រូវបានចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីដីធ្លី ដូចការចុះបញ្ជីដីក្រោមច្បាប់ភូមិបាលឡើយ ហើយដែលបណ្តាលឲ្យមានការកើនឡើងនូវហានិភ័យនូវការទាមទារដីជាន់គ្នា។

បទពិសោធន៍ពីសហគមន៍ព្រៃឈើក្នុងខេត្តកំពង់ស្ពឺគឺជាការឆ្លុះបញ្ចាំងមួយ។ ក្នុងករណីនេះ វិវាទរវាងសមាជិកសហគមន៍ព្រៃឈើ និងក្រុមហ៊ុនរុករកថ្មមួយឈានដល់ការកាន់អាវុធដណ្តើមកាន់កាប់យានយន្តឈូសដីរបស់ក្រុមហ៊ុនដែលប្រើសម្រាប់ឈូសព្រៃ។[180] វិវាទនេះចាប់ផ្តើមដោយសារតែការជាន់គ្នានៃព្រំប្រទល់ដី និងឯកសារកម្មសិទ្ធិ/ការគ្រប់គ្រងរបស់ភាគីទាំងពីរត្រូវបានប្រគល់ឲ្យដោយនាយកដ្ឋានផ្សេងគ្នា។[181] ក្រុមហ៊ុនរុករកថ្ម បន្តសកម្មភាពសម្អាតព្រៃ ខណៈសំណុំរឿងកំពុងជាប់នៅតុលាការ។ ជាការឆ្លើយតប សហគមន៍សម្រេចបញ្ឈប់ការកាប់ឆ្ការព្រៃដោយខ្លួនឯង ដោយកាន់កាប់យានយន្តឈូសដី ជាហេតុបង្ខំឲ្យក្រុមហ៊ុនសម្រេចចូលចរចា។ ចុងបញ្ចប់ទៅ ក្រុមហ៊ុនសម្រេចបោះបង់ចោលគម្រោងទាំងស្រុង។[182]

## បញ្ហាក្នុងការអនុវត្ត៖

### ភាពលំបាកក្នុងការស្វែងរកដំណោះស្រាយសមស្រប

វិសមភាពយ៉ាងធំធេងផ្នែកធនធានសេដ្ឋកិច្ច ឥទ្ធិពលនយោបាយ និងភាពទំនើបរវាងក្រុមហ៊ុនឯកជន និងសហគមន៍ធ្វើឲ្យការស្វែងរកដំណោះស្រាយនាពេលមានវិវាទមានភាពលំបាកជាខ្លាំងសម្រាប់សហគមន៍។ សកម្មភាពមិនសមរម្យត្រូវបានគេសង្កេតឃើញ ដូចជាការដែលក្រុមហ៊ុនយកចំណេញលើចន្លោះប្រហោងច្បាប់ដែលមានជាធរមាន។ ជាករណីដ៏ធ្ងន់ធ្ងរមួយក្នុងតំបន់ ក្រុមហ៊ុនកៅស៊ូវៀតណាមមួយបានចុះបញ្ជីក្នុងនាមជាស្ថាប័នជាច្រើន ដើម្បីអាចទទួលដីសម្បទានរហូតដល់ទៅ៥ដងនៃទំហំដែលអនុញ្ញាតឲ្យក្រុមហ៊ុនមួយក្រោមច្បាប់។[183]

បន្ថែមពីនេះ បណ្តឹងដាក់ដោយសហគមន៍ក្នុងការស្វែងរកដោះស្រាយតាមរយៈអាជ្ញាធរខេត្តពុំសូវជាទទួលបានការឆ្លើយតបឡើយ។[184] ក្នុងករណីដែលអាជ្ញាធរទទួលយកបណ្តឹងរបស់សហគមន៍ ដំណើរដោះស្រាយត្រូវបានពន្យាររហូតដល់ទៅរយៈពេល៣ឆ្នាំ ដែលបង្កឲ្យមានភាពមិនច្បាស់លាស់ និងបាត់បង់នូវផលិតភាពរបស់សហគមន៍។ ដំណោះស្រាយចុងក្រោយ ក៏ទំនងតែងតែពុំសមស្របទៅនឹងការចង់បានរបស់សហគមន៍។[185]

> “ក្នុងករណីដែលអាជ្ញាធរទទួលយកបណ្តឹងរបស់សហគមន៍ ដំណើរដោះស្រាយត្រូវបានពន្យាររហូតដល់ទៅរយៈពេល៣ឆ្នាំ ដែលបង្កឲ្យមានភាពមិនច្បាស់លាស់ និងបាត់បង់នូវផលិតភាពរបស់សហគមន៍។”

### ការកើនឡើងនៃការអាស្រ័យលើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

កត្តាចម្រុះដែលជះឥទ្ធិពលលើការដែលសហគមន៍ដោះស្រាយវិវាទរួមមាន៖ វប្បធម៌គោរពអាជ្ញាធរ វិសមភាពផ្នែកចំណេះដឹង វត្តមាននៃការតស៊ូមតិពីខាងក្រៅ (ជាទូទៅការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល) ខ្វះខាតការរៀបចំខ្លួនក្នុងការស្វែងរកយន្តការដោះស្រាយវិវាទ និងបទពិសោធន៍ជាមួយអាជ្ញាធរ និងតួអង្គឯកជន។ បច្ចុប្បន្ន ការអនុវត្តភាគច្រើនគឺសហគមន៍ដាក់ពាក្យបណ្តឹងទៅអាជ្ញាធរខេត្តជាច្រើនផ្សេងៗគ្នាដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។

វាទំនងជាបង្ហាញថាមានការមិនយល់គ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅលើ ការយល់ដឹង និងការប្រកាន់ខ្ជាប់ក្នុងនីតិវិធីនៃការដោះស្រាយវិវាទ ផ្លូវការ។ បទពិសោធន៍បានបង្ហាញថា ភាពមិនច្បាស់លាស់នូវនីតិវិធីកើតមាននៅថ្នាក់ខេត្ត។ នីតិវិធីមានរយៈពេលយូរ មិនមានតម្លាភាព និងអាស្រ័យទៅលើផលប្រយោជន៍របស់អាជ្ញាធរក្នុងសំណុំរឿង។[186] ជាលទ្ធផល សហគមន៍បង្កើនការស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ចៀសជាងតាមរយៈបណ្តាញផ្លូវការ។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយដល់សហគមន៍ជារឿយៗសំដៅលើយុទ្ធសាស្ត្រចំនួនពីរដែលមានអត្រាជោគជ័យខ្ពស់ក្នុងការការពារសិទ្ធិរបស់សហគមន៍នៅក្នុងការដោះស្រាយវិវាទ ៖ ទីមួយ គឺការស្វែងរកភាពជាដៃគូ និងការគាំទ្ររវាងអាជ្ញាធរជាតិ និងអន្តរជាតិ និងយុទ្ធសាស្ត្រទីពីរគឺការទាក់ទងភាគីក្រុមហ៊ុនឯងជនដែលស្ថិតនៅពីលើខ្សែចង្វាក់ផ្គត់ផ្គង់។[187]

**អនុសាសន៍ណែនាំ៖**

- **i.** រៀបចំគោលការណ៍ណែនាំច្បាស់លាស់ និងបទដ្ឋានអនុវត្តសម្រាប់ដោះស្រាយវិវាទ ដែលស្ថិតនៅក្នុងប្រព័ន្ធនៃសហគមន៍តំបន់ការពារធម្មជាតិដោយបន្តគោរព ការអនុវត្តបែបប្រពៃណី/ទំនៀមទម្លាប់។
- **ii.** ធានាថាយន្តការដោះស្រាយវិវាទដ៏ច្បាស់លាស់មួយត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយការទាមទារដែលកើតចេញពីការអនុវត្តសរាចរ០៦ (**មើលផ្នែក«កម្មសិទ្ធិដីធ្លី»**)។
- **iii.** ដាក់ចេញនូវការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិកាន់កាប់របស់សហគមន៍តំបន់ការពារធម្មជាតិដើម្បីធានាសុវត្ថិភាពផ្នែកច្បាប់ និងបង្កើនអំណាចចរចារបស់សហគមន៍ក្នុងករណីមានវិវាទ។
- **iv.** ចុះបញ្ជីតំបន់ការពារ/តំបន់ការពារធម្មជាតិក្នុងប្រព័ន្ធរួមមួយ ដូចជាការចុះបញ្ជីដីធ្លី ដើម្បីកាត់បន្ថយឬលុបបំបាត់ហានិភ័យនៃការទាមទារ។
- **v.** ប្រមូលផ្តុំនីតិវិធីក្នុងការផ្តល់ការអនុញ្ញាតលើសិទ្ធិស្តីពីធនធាន និងធ្វើឲ្យប្រសើរឡើងតម្លាភាពអន្តរក្រសួងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងក្នុងន័យធានាមិនឲ្យមានវិវាទកើតឡើង។



# ៩.ការអនុវត្តច្បាប់

## និយមន័យ៖

ក្នុងបរិបទនៃតំបន់ការពារសហគមន៍នៅកម្ពុជា ការអនុវត្តសំដៅដល់ការអនុវត្តដោយស្របច្បាប់នូវសកម្មភាពគ្រប់គ្រងនៃតំបន់ការពារសហគមន៍ដូចដែលបានយល់ព្រមក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ក៏ដូចជាជានាគោរពនូវច្បាប់ដែលពាក់ព័ន្ធ។ វារួមបញ្ចូលផងដែរ នូវសកម្មភាពផ្នែកច្បាប់ក្នុងការបង្ការ និងការដាក់ទោសបទល្មើស ដែលរួមមានសកម្មភាពដែលផ្ទុយទៅនឹងផែនការគ្រប់គ្រង។

## ច្បាប់គ្រប់គ្រង៖

ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្ដីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧)

## ភាគីពាក់ព័ន្ធ៖

ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត រដ្ឋបាលព្រៃឈើ សមាជិកសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល

## បរិបទ៖

ជាទូទៅរដ្ឋជាអ្នកពិនិត្យទៅលើការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ហើយអាជ្ញាធររដ្ឋាភិបាលមានទំនួលខុសត្រូវក្នុងការអនុវត្តច្បាប់ និងដាក់ទណ្ឌកម្ម។ ចំពោះការអនុវត្តផ្ទាល់ មន្ទីរបរិស្ថានខេត្តមានទំនួលខុសត្រូវឈានមុខគេចំពោះបញ្ហាដែលកើតឡើងប្រចាំថ្ងៃនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានរបស់ក្រសួង។ សមាជិកសហគមន៍តំបន់ការពារធម្មជាតិដើរតួនាទីយ៉ាងមានកម្រិតក្នុងការអនុវត្តច្បាប់ ជាបឋមរាយការណ៍ពីការបំពានច្បាប់ ឬលក្ខន្តិកៈរបស់សហគមន៍តំបន់ការពារធម្មជាតិទៅកាន់អាជ្ញាធររដ្ឋាភិបាល និងសហការជាមួយអាជ្ញាធរនៅពេលចាំបាច់ ហើយពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យដាក់ទណ្ឌកម្មឡើយ។

ជាទូទៅ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានតួនាទីក្នុងការពិនិត្យ និងអនុវត្តច្បាប់ស្ដីពីបទល្មើសបរិស្ថានដែលកើតមានក្នុងតំបន់ការពារធម្មជាតិ។[188] មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលកាពារ និងអភិរក្សធម្មជាតិ មានតួនាទីជានគរបាលយុត្តិធម៌ ដែលអាចដាក់ទណ្ឌកម្មក្នុងស្ថានការណ៍មួយចំនួន រីឯស្ថានការណ៍ផ្សេងទៀតមន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលកាពារ និងអភិរក្សធម្មជាតិអាចបញ្ជូនសំណុំរឿងទៅតុលាការ ដោយតុលាការជាអ្នកសម្រេចជាចុងក្រោយថាតើបទល្មើសលើធនធានធម្មជាតិកើតមានដែរឬទេ និងថាតើអ្វីទៅដែលជាទណ្ឌកម្មសមស្រប។[189]

លទ្ធភាពនៃការដាក់ទណ្ឌកម្មលើបទល្មើសស្ដីពីធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិរួមមាន: ការឃុំខ្លួន ការពិន័យជាប្រាក់ដោយតុលាការ ពិន័យអន្តរការណ៍ ការរឹបអូសភស្តុតាង ការបង់ប្រាក់ដើម្បីស្តារការខូចខាត ការព្រមាន និងការបញ្ចប់/ព្យួរកិច្ចព្រមព្រៀងឬអាជ្ញាប័ណ្ណ។[190]

អគ្គនាយកដ្ឋានរដ្ឋបាលកាពារ និងអភិរក្សធម្មជាតិ អាចធ្វើការពិន័យអន្តរការណ៍ បញ្ជាឲ្យបង់ប្រាក់សងសំណងខូចខាត និងចេញសេចក្តីព្រមាន ខណៈមានតែរដ្ឋមន្ត្រីក្រសួងបរិស្ថានប៉ុណ្ណោះដែលអាចបញ្ចប់ ឬព្យួរកិច្ចព្រមព្រៀង ឬអាជ្ញាប័ណ្ណ។[191] មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលកាពារ និងអភិរក្សធម្មជាតិ មានទំនួលខុសត្រូវក្នុងការគ្រប់គ្រងភស្តុតាងដែលត្រូវបានរឹបអូស/ឃាត់ទុក និងត្រូវបានអនុញ្ញាតឲ្យផ្អាកសកម្មភាពខុសច្បាប់រហូតដល់ពេលដែលសំណុំរឿងត្រូវបានដោះស្រាយ។[192]

> "ក្នុងករណីដែលជនល្មើសប្រកែកមិនព្រមបង់ប្រាក់ ឬស្តារការខូចខាត មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិអាចដាក់ពាក្យបណ្តឹងទៅតុលាការចំពោះបទល្មើសនេះ ហើយសំណុំរឿងនិងត្រូវដោះស្រាយដោយតុលាការ។"

ក្នុងករណីដែលជនល្មើសប្រកែកមិនព្រមបង់ប្រាក់ ឬស្តារការខូចខាត មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិអាចដាក់ពាក្យបណ្តឹងទៅតុលាការចំពោះបទល្មើសនេះ ហើយសំណុំរឿងនិងត្រូវដោះស្រាយដោយតុលាការ។[193] លើកលែងតែក្នុងស្ថានការណ៍ជាក់លាក់ណាមួយ បុគ្គលដែលបដិសេធទៅនឹងសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អាចប្តឹងតវ៉ាទៅប្រធាននាយកដ្ឋាននេះ ហើយក្នុងស្ថានការណ៍ណាក៏ដោយ ក៏អាចធ្វើការប្តឹងជំទាស់ទៅតុលាការផងដែរ។[194]

ប្រាក់ពិន័យដែលកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ និងប្រាក់ចំណូលដែលបានពីការលក់គស្តុតាងដែលបានរឹបអូសត្រូវដាក់បញ្ចូលក្នុងថវិកាជាតិ។[195] គេអាចឃើញថា ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ បានប្រមើលមើលឃើញថាប្រាក់សំណងខ្លះអាចត្រូវបានបង់ចូលសហគមន៍តំបន់ការពារធម្មជាតិសម្រាប់បទល្មើសមួយចំនួន ប៉ុន្តែពុំមានចែងច្បាស់លាស់ឡើយ។[196]

ប្រធានតំបន់ការពារធម្មជាតិនីមួយៗមានទំនួលខុសត្រូវក្នុងការចេញសកម្មភាពប្រឆាំងបទល្មើសធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិ។[197] ជាទូទៅ សហគមន៍តំបន់ការពារធម្មជាតិមានទំនួលខុសត្រូវក្នុងការអនុវត្តលក្ខន្តិកៈ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងរបស់ខ្លួន ក៏ដូចជាសហប្រតិបត្តិការជាមួយអាជ្ញាធរក្នុងការប្រយុទ្ធប្រឆាំងទៅនឹងបទល្មើសធនធានធម្មជាតិ។[198] គេមើលឃើញថា សហគមន៍តំបន់ការពារធម្មជាតិត្រូវបានកម្រិតឲ្យបានត្រឹមតែធ្វើការរាយការណ៍ពីបទល្មើស ដោយពុំអាចមានសមត្ថភាពក្នុងការអនុវត្តច្បាប់ដោយផ្ទាល់។ ការអនុញ្ញាតឲ្យសហគមន៍តំបន់ការពារធម្មជាតិអនុវត្តច្បាប់ដោយផ្ទាល់ និងបញ្ជាក់ពីសកម្មភាពអ្វីដែលសហគមន៍តំបន់ការពារធម្មជាតិអាចធ្វើបានដូចជាការឃាត់ខ្លួនជនល្មើសបណ្តោះអាសន្ន រឹបអូសឧបករណ៍ខុសច្បាប់ ការដើរល្បាតរួម អាចធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍តំបន់ការពារធម្មជាតិ/តំបន់ការពារធម្មជាតិ។

ការតាមដានលើការអនុវត្តដោយសហគមន៍តំបន់ការពារធម្មជាតិ ធ្វើឡើងដោយស្ថាប័នជាច្រើន។ ខណៈគណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ មានទំនួលខុសត្រូវក្នុងការគ្រប់គ្រង និងពិនិត្យសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន ដោយគណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិត្រូវតែធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំទៅប្រធានតំបន់ការពារធម្មជាតិដែលសហគមន៍តំបន់ការពារធម្មជាតិស្ថិតនៅក្នុង (ដោយផ្តល់ឯកសារចម្លងទៅអាជ្ញាធរឃុំ/សង្កាត់ និងអាជ្ញាធរស្រុក/ក្រុង)។[199] ប្រធានតំបន់ការពារធម្មជាតិនោះ ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសទៅមន្ទីរបរិស្ថានខេត្ត (ដោយផ្តល់ឯកសារចម្លងទៅអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន) ហើយមន្ទីរបរិស្ថានខេត្តត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំទៅក្រសួងបរិស្ថាន។[200]

ការតាមដាន និងការវាយតម្លៃទៅលើការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំដោយនាយកដ្ឋានតំបន់ការពារធម្មជាតិ មន្ទីរបរិស្ថានខេត្ត ក្រុមប្រឹក្សាឃុំ/សង្កាត់ និងដៃគូអភិវឌ្ឍ។[201] នាយកដ្ឋានជីវភាពសហគមន៍ពិនិត្យ និងវាយតម្លៃផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរយៈពេលបី (៣) ឆ្នាំ ឬឆាប់ជាងនេះបើចាំបាច់។[202]

**សហគមន៍តំបន់ការពារធម្មជាតិត្រូវរំពឹងថានឹងត្រូវបានតាមដាន និងវាយតម្លៃផ្អែកលើលក្ខខណ្ឌចំនួន៤ ដែលត្រូវបានចែងក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ។[203] លក្ខខណ្ឌទាំងនោះ ក៏ត្រូវបានភ្ជាប់មកជាមួយនូវលក្ខណៈវិនិច្ឆ័យ ហើយលក្ខខណ្ឌ និងលក្ខណៈមានដូចជា៖**

**លក្ខខណ្ឌទី១: ការការពារធនធានធម្មជាតិ** (លក្ខណៈវិនិច្ឆ័យ: ការគ្រប់គ្រង និងប្រើប្រាស់តំបន់ ការអភិរក្ស និងការពារជីវៈចម្រុះ ការធ្វើឲ្យប្រសើរឡើងនូវធនធានធម្មជាតិក្នុងសហគមន៍ និងការទាញយក និងប្រើប្រាស់ធនធានធម្មជាតិដោយសមហេតុផល)

**លក្ខខណ្ឌទី២: ធ្វើឲ្យប្រសើរឡើងនូវវិបុលភាពនៃសមាជិកសហគមន៍** (លក្ខណៈវិនិច្ឆ័យ: សមាជិកសហគមន៍តំបន់ការពារធម្មជាតិអាចចូលទៅរកធនធានធម្មជាតិ ធនធានធម្មជាតិក្នុងសហគមន៍រួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរបស់សមាជិក ធនធានធម្មជាតិរួមចំណែកក្នុងការអភិវឌ្ឍកសិកម្ម សមាជិកសហគមន៍តំបន់ការពារធម្មជាតិបានធ្វើឲ្យប្រសើរឡើងនូវឱកាសក្នុងការទទួលបានការងារបន្ថែម)

**លក្ខខណ្ឌទី៣: ការធានានូវវិបុលភាពរបស់សហគមន៍** (លក្ខណៈវិនិច្ឆ័យ: ប្រព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងដោយមានការចូលរួមពីសមាជិក យន្តការ និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងដោះស្រាយវិវាទ ភាពជាថ្នាក់ដឹកនាំនៃគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ តម្លាភាពក្នុងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ)

**លក្ខខណ្ឌទី៤: ការឧបត្ថម្ភពីខាងក្រៅ** (លក្ខណៈវិនិច្ឆ័យ: ការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការគាំទ្រការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ គោលនយោបាយរបស់រដ្ឋាភិបាលទៅលើការអភិវឌ្ឍសហគមន៍ ការអប់រំ និងចែករំលែកចំណេះដឹងក្នុងប្រព័ន្ធបែបផ្លូវការ និងក្រៅផ្លូវការដែលរួមចំណែកដល់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ការគាំទ្រលើតម្លៃផលិតផលក្នុងទីផ្សារ)

ផ្អែកលើលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យខាងលើ សូចនាការត្រូវបានបង្កើតឡើងដោយសហគមន៍តំបន់ការពារធម្មជាតិ និងត្រូវបានដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។

បច្ចុប្បន្ននេះ មានក្រុមឧទ្យានុរក្សចំនួន៣ប្រភេទដែលដើរល្បាតសហគមន៍តំបន់ការពារធម្មជាតិ:

(១) ការល្បាតសហគមន៍តំបន់ការពារធម្មជាតិដោយសមាជិកសហគមន៍

(២) ការល្បាតរួមរបស់សហគមន៍តំបន់ការពារធម្មជាតិធ្វើឡើងដោយសមាជិកសហគមន៍តំបន់ការពារ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាន និង

(៣) ការល្បាតរួមរវាងមន្ទីរបរិស្ថានខេត្ត និងក្រសួងបរិស្ថាន។[204]

ការល្បាតរបស់សហគមន៍តំបន់ការពារធម្មជាតិត្រូវបានកំណត់ត្រឹមព្រំដែនរបស់សហគមន៍ និងពុំមានដែនសមត្ថកិច្ចក្រៅពីព្រំដែនសហគមន៍តំបន់ការពារធម្មជាតិឡើយ ប៉ុន្តែបានបង្ហាញពីប្រសិទ្ធភាពក្នុងកាត់បន្ថយសកម្មភាពមិនស្របច្បាប់។[205] ការល្បាតរួមរបស់សហគមន៍តំបន់ការពារធម្មជាតិ ជាមធ្យោបាយដែលអាចកាត់បន្ថយចំណាយ និងមានប្រសិទ្ធភាពក្នុងការល្បាតតំបន់ការពារធម្មជាតិដែលមានផ្ទៃក្រឡាធំ ដោយសារតែកង្វះខាតនូវមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថានក្នុងការល្បាតម្តងមួយដុំ ហើយការល្បាតរួមរវាងមន្ទីរបរិស្ថាន និងក្រសួងបរិស្ថាន ជួយជានាទាំងថ្នាក់ខេត្ត និងភាគីពាក់ព័ន្ធថ្នាក់ជាតិថា ផលប្រយោជន៍របស់ពួកគេត្រូវបានការពារ។[206] ការល្បាតទាំងបីប្រភេទ រំពឹងយ៉ាងច្រើនទៅលើធនធាន និងការហ៊ឹកហ្វឺនពីខាងក្រៅ។[207] ប៉ុន្តែ ប្រឈមនឹងធនធានដែលមានកម្រិត ក្រុមទាំងនេះបានប្រើប្រាស់បច្ចេកវិទ្យាក្នុងការត្រួតពិនិត្យ និងប្រព័ន្ធព័ត៌មានដើម្បីបំពេញចន្លោះដែលខ្វះខាតបណ្តាលមកពីមានសមាជិកតិច។[208] សហគមន៍តំបន់ការពារធម្មជាតិភាគច្រើនទទួលបានជំនួយបច្ចេកទេស សម្ភារៈ និងហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាលក្នុងការដើរល្បាត។ ជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលដែលមានធនធានច្រើនបានផ្តល់ទៅសហគមន៍នូវសម្ភារៈបច្ចេកវិទ្យាថ្មីៗដូចជាដ្រូន និងឧបករណ៍ GPS ដែលអនុញ្ញាតឲ្យមន្ត្រីឧទ្យានុរក្សអាចធ្វើផែនការល្បាតដោយមានប្រសិទ្ធភាពជាងមុន និងប្រមូលបានប្រសើរជាងមុននូវភស្តុតាងស្តីពីសកម្មភាពខុសច្បាប់។[209]

## ចន្លោះប្រហោងផ្នែកច្បាប់៖

### ភាពមានកម្រិតនៃសមត្ថភាពក្នុងការចាត់វិធានការអនុវត្តច្បាប់

ដូចដែលបានរៀបរាប់ខាងលើ សមត្ថភាពនៅក្នុងការចាត់វិធានការអនុវត្តច្បាប់របស់សហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិនៅមានកម្រិត។ សហគមន៍មូលដ្ឋានដែលព្យាយាមការពារព្រៃឈើត្រូវបានទទួលការគំរាមកំហែង និងចោទប្រកាន់ថាជាជនកាប់ឈើខុសច្បាប់។ លើសពីនេះទៅទៀត សហគមន៍ នៃសហគមន៍តំបន់ការពារធម្មជាតិក៏ធ្លាប់ទទួលបានការព្រមានពីមន្ត្រីមូលដ្ឋានថាសហគមន៍ពុំមានសិទ្ធិក្នុងការចាប់ជនកាប់ឈើខុសច្បាប់ ឬឧបករណ៍របស់ជនល្មើស បើទោះបីជាជនដែលដ និងឧបករណ៍ទាំងនោះត្រូវបានដោះលែងដោយគ្មានទទួលទណ្ឌកម្មជាច្រើនលើកក៏ដោយ។[210]

### កង្វះខាតនូវការកំហែញ (ការកម្លា)

ជាទូទៅ ច្បាប់ពុំត្រូវបានភ្ជាប់មកជាមួយនូវការអនុវត្តបែបតឹងរឹង និងការដាក់ទណ្ឌកម្មបែបកម្លាចឡើយ។ សេចក្តីបារម្ភត្រូវបានលើកឡើងទាក់ទងទៅនឹងប្រសិទ្ធភាពក្នុងការដាក់ទណ្ឌកម្មដែលមានចែងដោយក្របខ័ណ្ឌច្បាប់ក្នុងការកំហែញសកម្មភាពខុសច្បាប់ ជាពិសេសគឺការទន្ទ្រាន និងទាញយកនូវធនធានធម្មជាតិដោយភាគីទីបី។ ការអនុវត្តមិនស្របច្បាប់ត្រូវបានគេកត់សម្គាល់នៅថ្នាក់ខេត្ត ដូចជាអ្នកកាប់ឈើខុសច្បាប់ដែលត្រូវបានចាប់ខ្លួនបានបង់ប្រាក់ក្រៅផ្លូវការដើម្បីមានសេរីភាពដោយរួចផុតពីការកាត់ទោស។[211] បន្ថែមពីនេះអាជ្ញាធរខេត្ត ក៏ដូចជាសមាជិកសហគមន៍ (ជនចំណាកស្រុកដែលពុំមានទំនាក់ទំនងបែបគ្រួសារទៅនឹងដី) ត្រូវបានសង្ស័យថារៀបចំយ៉ាងសកម្មនាពេលខ្លះ ឬចូលរួមដោយផ្ទាល់ក្នុងការកាប់ឈើដោយខុសច្បាប់ដើម្បីចំណូលផ្ទាល់ខ្លួន។[212] មានការយល់ដឹងជាទូទៅថាសកម្មភាពខុសច្បាប់មួយចំនួនមានតម្លៃច្រើនជាងការដាក់ទណ្ឌកម្មនៅពេលចាប់បាន។ បន្ថែមពីនេះ អាជ្ញាធរប្រឈមទៅនឹងបណ្តឹងដ៏ច្រើនលើសលុបដែលឈានដល់ការពឹងពាក់លើអង្គការមិនមែនរដ្ឋាភិបាលក្នុងការតាមដានសំណុំរឿង និងតស៊ូមតិទាមទារឲ្យមានការកាត់ទោសឲ្យបានសមស្រប។[213]

## បញ្ហាក្នុងការអនុវត្ត៖

### ការទទួលបានធនធាននៅមានកម្រិត

សមាសភាពនៃក្រុមឧទ្យានុរក្សដែលទទួលខុសត្រូវក្នុងការល្បាតរពឹងមួយភាគធំលើធនធានដែលមានជាស្រេច។[214] សហគមន៍តំបន់ការពារធម្មជាតិ តែងតែមានធនធានហិរញ្ញវត្ថុតិចតួច ក្នុងដំណាក់កាលអភិវឌ្ឍផែនការគ្រប់គ្រងរបស់ខ្លួន។[215] អំឡុងពេលខាងលើនេះសហគមន៍មូលដ្ឋាន តែងតែពឹងអាស្រ័យលើថវិកាពីខាងក្រៅដូចជាអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង់ប្រាក់ដល់សកម្មភាពល្បាតរបស់ពួកគេ។[216] ជារឿងគួរឲ្យសោកស្តាយ មិនមែនគ្រប់សហគមន៍តំបន់ការពារធម្មជាតិមានសមត្ថភាពក្នុងការទទួលបានធនធានឡើយ ដែលជាហេតុនាំឲ្យការល្បាតរបស់ឧទ្យានុរក្សតែងតែត្រូវបានកាត់ចេញពីថវិកា និងសកម្មភាពរបស់សហគមន៍។ [217] ដោយមានការល្បាតតិចតួច ឬគ្មានទាល់តែសោះ សកម្មភាពប្រមូលផលធនធានធម្មជាតិខុសច្បាប់បន្តកើតមានដោយមិនប្រទះនូវបញ្ហាអ្វីទាំងអស់។

ប៉ុន្តែបើទោះបីជាមានការដើរល្បាតក្តី ជនល្មើសតែងតែមានអាវុធយ៉ាងច្រើនឬមានការគាំទ្រពីស្ថាប័នមានអំណាច ជាហេតុនាំឲ្យឧទ្យានុរក្សមានជម្រើសតិចក្នុងការអនុវត្តច្បាប់ជាក់ស្តែង។ ការអនុវត្តបែងចែកធនធាន ដោយមានឧទ្យានុរក្សរួមល្បាតសហគមន៍តំបន់ការពារធម្មជាតិ ជាឧទាហរណ៍មួយដែលទំនងជាមានប្រសិទ្ធភាព។[218]

## ការមិនរួមបញ្ចូលនូវការអនុវត្តបែបប្រពៃណីនៃក្រុមជនជាតិដើមភាគតិច

សហគមន៍ជនជាតិដើមភាគតិច និងប្រពៃណីរបស់ពួកគាត់ពុំត្រូវបានយកមកពិចារណាឲ្យបានគ្រប់គ្រាន់ឡើយ ក្នុងការរួមបញ្ចូលសកម្មភាពជនជនដើមភាគតិចដែលត្រូវបានចាត់ទុកថាស្របច្បាប់។ នេះជាហេតុនាំឲ្យការអនុវត្តរបស់ពួកគាត់ត្រូវបានចាត់ទុកថាមិនស្របច្បាប់ និងធ្វើឲ្យសហគមន៍ជនជាតិដើមភាគតិចប្រឈមទៅនឹងហានិភ័យក្នុងការដាក់ទណ្ឌកម្ម។[219]

## ការធ្វើចំណាកស្រុកនៅក្នុងប្រទេស

ការកើនឡើងនៃការធ្វើចំណាកស្រុកនៅក្នុងប្រទេស ក៏បង្ករជាការលំបាកក្នុងការអនុវត្តច្បាប់ផងដែរ។ ជនចំណាកស្រុកថ្មី ដែលមានទំនាក់ទំនងតិចតួចជាមួយនឹងដីធ្លី ដែលពួកគេទើបនឹងមករស់នៅ ទំនងជាអាចចូលរួមប្រព្រឹត្តសកម្មភាពខុសច្បាប់ ដើម្បីទទួលបានប្រាក់កម្រៃឆាប់រហ័ស។[220] ការបែងចែកព្រំដែនឲ្យបានច្បាស់លាស់ត្រូវបានចាត់ទុកជាកត្តាយ៉ាងសំខាន់ដែលនាំឲ្យមានការអនុវត្តច្បាប់។[221] បច្ចុប្បន្ន ការបែងចែកព្រំដែមិនច្បាស់លាស់ ឬមិនមានព្រំដែន ឬពុំមានការយល់ដឹងពីសំណាក់ភាគីពាក់ព័ន្ធចំពោះទីតាំងព្រំដែន ឈានដល់ការចូលដោយខុសច្បាប់ជាញឹកញយ និងការទន្ទ្រានបែបអចិន្ត្រៃយ៍។

### អនុសាសន៍ណែនាំ៖

- **i.** ផ្តល់ឲ្យសហគមន៍តំបន់ការពារធម្មជាតិនូវអំណាចបន្ថែមក្នុងការអនុវត្តវិធានសហគមន៍តំបន់ការពារធម្មជាតិដោយផ្ទាល់ រួមមានការចេញសកម្មភាពប្រឆាំងភាគីទីបី ស្របពេលដែលពួកគាត់ពិនិត្យសហគមន៍តំបន់ការពារធម្មជាតិ (ដោយមានការគាំទ្រចាំបាច់ ដូចជាមធ្យោបាយ និងសម្ភារៈដើម្បីចេញត្រួតពិនិត្យ ការគាំទ្រដែលចាំបាច់ពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរបរិស្ថានខេត្ត ក៏ដូចជាការការពារផ្លូវច្បាប់ដើម្បីជានាពីតម្លាភាព និងទណ្ឌកម្មដោយយុត្តិធម៌)។
- **ii.** បញ្ជាក់ឲ្យច្បាស់ពីសំណងដែលសហគមន៍តំបន់ការពារធម្មជាតិអាចទទួលបានពីបទល្មើសធនធានធម្មជាតិ និងពីរបៀបដែលសំណងទាំងនោះត្រូវបានផ្តល់ និងបែងចែក ដែលរួមបញ្ចូលផងដែរពីការចាត់ចែងឡើងវិញទាំងស្រុង ឬផ្នែកណាមួយដែលប្រាក់ពិន័យទទួលបានពីបទល្មើសធនធានធម្មជាតិ និងចំណូលដែលទទួលបានពីការលក់តស្តុតាងរឹបអូស ដែលត្រូវផ្តល់ទៅសហគមន៍តំបន់ការពារធម្មជាតិដែលរងផលប៉ះពាល់។
- **iii.** ធ្វើការវិភាគពីទណ្ឌកម្មផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌដើម្បីកំណត់ថាតើភាពធ្ងន់ធ្ងរនៃទណ្ឌកម្មសមស្របក្នុងការកំញើញសកម្មភាពមិនស្របច្បាប់។
- **iv.** ធានាក្នុងការមានធនធាន និងសមត្ថភាពគ្រប់គ្រាន់ក្នុងការល្បាត និងអនុវត្តច្បាប់។
- **v.** ផ្តល់ភាពស្របច្បាប់ និងបញ្ជាក់ពីខ និងលក្ខខណ្ឌក្នុងការល្បាតរួម ដែលរួមមានទាំងសមាជិកសហគមន៍ និងឧទ្យានុរក្សនៃក្រសួងបរិស្ថានក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ។
- **vi.** ផ្តល់ភាពស្របច្បាប់ និងបញ្ជាក់ពីខ និងលក្ខខណ្ឌក្នុងការល្បាតរួម ដែលរួមមានទាំងសមាជិកសហគមន៍ និងឧទ្យានុរក្សនៃក្រសួងបរិស្ថានក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ។

# ១០.ការគាំទ្រពីខាងក្រៅ

## និយមន័យ៖

ការទទួលបានជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងកសាងសមត្ថភាពពីស្ថាប័នខាងក្រៅ ដោយផ្ទាល់ឬដោយប្រយោល ដែលគាំទ្រសហគមន៍ក្នុងការអនុវត្តសកម្មភាពសហគមន៍តំបន់ការពារធម្មជាតិ។ ក្នុងបរិបទនៃរបាយការណ៍នេះ ការគាំទ្រពីខាងក្រៅសំដៅដល់ការគាំទ្រទាំងខាងក្នុង និងក្រៅប្រព័ន្ធរដ្ឋបាលកម្ពុជា រួមមានភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គវិស័យឯកជន។

## ច្បាប់គ្រប់គ្រង៖

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) ប្រកាសស្តីពីគោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (២០១៧)

## ភាគីពាក់ព័ន្ធ៖

អគ្គនាយកដ្ឋានសហគមន៍នៃក្រសួងបរិស្ថាន ក្រសួងមហាផ្ទៃ មន្ទីរបរិស្ថានខេត្ត អភិបាលនៃគណៈអភិបាលខេត្ត អភិបាលរងខេត្ត ក្រុមប្រឹក្សាឃុំ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ភ្នាក់ងារម្ចាស់ជំនួយអន្តរជាតិ សមាជិកសហគមន៍

## បរិបទ៖

ក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិទទួលស្គាល់យ៉ាងច្បាស់ពីតួនាទីនៃជំនួយពីតួអង្គខាងក្រៅទៅកាន់សហគមន៍។ ការគាំទ្ររបស់រដ្ឋាភិបាល ជាផ្នែកមួយមិនអាចផ្តាច់បានក្នុងក្របខ័ណ្ឌច្បាប់ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ ដូចជាការបង្កើតតំបន់ការពារធម្មជាតិ ដែលពាក់ព័ន្ធការប្រឹក្សាយោបល់យ៉ាងច្រើន និងការការគាំទ្របច្ចេកទេសពីមន្ត្រីរដ្ឋាភិបាល។ ការអនុវត្តច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិទាមទារនូវការត្រួតពិនិត្យជាប្រចាំពីអាជ្ញាធររដ្ឋាភិបាល។ ដើម្បីអាចបំពេញនូវតួនាទីគាំទ្ររបស់ខ្លួន វាជាការចាំបាច់ដែលមាន ថវិកាគ្រប់គ្រាន់ ក៏ដូចជាធនធានមនុស្ស និងបច្ចេកទេស។[222]

ការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការបង្កើត និងដំណើរការសហគមន៍តំបន់ការពារធម្មជាតិអាចមានប្រភពជាច្រើន រួមមានមូលនិធិតំបន់ការពារធម្មជាតិ ថវិកាជាតិ ប្រាក់ដែលបានពីការចូល និងសេវាក្នុងតំបន់ការពារធម្មជាតិ ប្រាក់ធានារ៉ាប់រងបរិស្ថាន ប្រាក់អំណោយ ជំនួយពីអង្គការជាតិ និងអន្តរជាតិ និងប្រទេសជាមិត្ត ជំនួយពីមូលនិធិបរិស្ថានអន្តរជាតិ ប្រាក់បដិភាគសមាជិករបស់សមាជិកសហគមន៍ ការលក់ធនធានអនុផលព្រៃឈើ សេវាអេកូទេសចរណ៍ និងមូលនិធិឃុំ/សង្កាត់។[223]

ការគាំទ្រពីខាងក្រៅផ្សេងទៀតក៏ត្រូវបានប្រមើលមើល និងលើកកម្ពស់ផងដែរ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិចែងយ៉ាងច្បាស់ថា៖ «អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តក្នុងការផ្តល់ជំនួយ និងសម្របសម្រួលសម្រាប់ការបង្កើត និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ»។[224] បន្ថែមពីនេះ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងមន្ទីរបរិស្ថានខេត្តមានទំនួលខុសត្រូវក្នុងការបង្កើតការប្រាស្រ័យទាក់ទងជាមួយតួអង្គអភិវឌ្ឍ និងឯកជន ដើម្បីស្វែងរកការគាំទ្រក្នុងការបង្កើត គ្រប់គ្រង និងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ។[225]

ជាការពិត អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ធនធានគន្លឹះក្នុងការគាំទ្រសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការបង្កើត និងអនុវត្តទៅនៃសហគមន៍តំបន់ការពារធម្មជាតិ។[226] វិស័យឯកជន ក៏ជាប្រភពនៃការគាំទ្រមួយដែលអាចនឹងអភិវឌ្ឍបន្ថែមសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ បើទោះបីជាការប្រស្រ័យទាក់ទងគ្នានៅមានកម្រិត។

## ចន្លោះប្រហោងផ្នែកច្បាប់៖

### ភាពស្មុគស្មាញនៃនីតិវិធីក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

ក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ ផ្តល់ដំណាក់ក្នុងក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងកំណត់ឲ្យមានការពាក់ព័ន្ធពីសំណាក់សហគមន៍ និងអាជ្ញាធរក្នុងដំណាក់កាលនីមួយៗ។ ទោះជាយ៉ាងណា បទពិសោធន៍ក្នុងការអនុវត្តបង្ហាញយ៉ាងច្បាស់ថា បើទោះបីជាមានកិច្ចខំប្រឹងប្រែងក្នុងការប្រកាន់ខ្ជាប់នូវនីតិវិធីក្តី ការបង្អាក់ដែលបណ្តាលមកពីស្ថានការណ៍ធ្វើឲ្យនីតិវិធីមានរយៈពេលយូរដោយមិនសមហេតុផល។ អង្គការមិនមែនរដ្ឋាភិបាលដែលជួយសហគមន៍បានលើកឡើងពីតម្លៃនៃការធ្វើដំណើរ ការពិបាកក្នុងការចូលទៅសហគមន៍ កាលវិភាគជាន់គ្នារបស់អាជ្ញាធរ និងការប្រកួតប្រជែងផ្នែកអាទិភាពនៅតាមកម្រិតផ្សេងៗរបស់រដ្ឋាភិបាល រដូវកាលបោះឆ្នោតថ្នាក់ជាតិក៏ជាផ្នែកមួយនៃកត្តាដែលនាំឲ្យមានការពន្យារពេលក្នុងការពិគ្រោះយោបល់ និងយល់ព្រមស្តីពីសហគមន៍តំបន់ការពារធម្មជាតិ។ នេះនាំឲ្យមានការស្នើក្នុងការតាក់តែងឡើងវិញនូវនីតិវិធី ដើម្បីសម្រួលដល់ភស្តុភារផ្នែករដ្ឋបាល និងធ្វើឲ្យប្រសើរឡើងនូវពេលវេលា និងប្រសិទ្ធភាពនៃធនធានរបស់ភាគីពាក់ព័ន្ធដែលគាំទ្រដំណាក់កាលនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។

### កង្វះខាតនូវយន្តការជាក់លាក់សម្រាប់កិច្ចសហការជាមួយភាគីពាក់ព័ន្ធខាងក្រៅ ស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ

ក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ ពុំបានកំណត់ពីចំណែកណាមួយនៅកម្រិតឃុំ ដែលត្រូវបែងចែកក្នុងការគ្រប់គ្រងធនធានធម្មជាតិឡើយ។ ក៏មានផងដែរកង្វះខាត នូវការកំណត់ថ្នាក់ជាតិស្តីពីការណែនាំអប្បរមាក្នុងផ្តល់មូលនិធិចាំបាច់ក្នុងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលអាស្រ័យតាមទំហំសហគមន៍នីមួយៗ និងគ្មានការធានាលើការផ្តល់មូលនិធិពីរដ្ឋាភិបាលបែបណាមួយឡើយ។ ជាលទ្ធផល សហគមន៍តំបន់ការពារធម្មជាតិ ពឹងផ្អែកយ៉ាងច្រើនលើហិរញ្ញវត្ថុរបស់អង្គការមិនមែន រដ្ឋាភិបាលដើម្បីគាំទ្រដល់ការគ្រប់គ្រងសកម្មភាពរបស់ខ្លួន។[227] មានពេលខ្លះ អង្គការមិនមែនរដ្ឋាភិបាល រួមចំណែកក្នុងការចែករំលែកការចំណាយ ដោយផ្តល់ថវិកាបែបសមមាត្រ ( ការផ្តល់ធនធាន ដែលសមមាត្រទៅនឹងការផ្តល់ពីប្រភពឯទៀត ) ដើម្បីលើកទឹកចិត្តឲ្យរដ្ឋាភិបាលបង្កើនការផ្តល់ថវិកាទៅសហគមន៍តំបន់ការពារ។ ដំណាក់កាលនេះពុំត្រូវបានចាត់ទុកជាផ្លូវការនៅឡើយក្នុងក្របខ័ណ្ឌច្បាប់នៃសហគមន៍តំបន់ការពារធម្មជាតិ ហើយអង្គការមិនមែនរដ្ឋាភិបាលពុំអាចទាមទារឲ្យអាជ្ញាធរទទួលខុសត្រូវក្នុងករណីដែលអាជ្ញាធរពុំផ្តល់មូលនិធិឲ្យសមមាត្រទៅនឹងទំហំដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ឡើយ។

## បញ្ហាក្នុងការអនុវត្ត៖

### ការពឹងអាស្រ័យហួសហេតុលើការគាំទ្រពីសំណាក់ខាងក្រៅ

ជាលទ្ធផលនៃឧបសគ្គក្នុងការផ្តល់មូលនិធិដូចបានរៀបរាបខាងលើ( **មើលផ្នែក «អភិបាលកិច្ចផ្ទៃក្នុងសហគមន៍»** ) សហគមន៍តំបន់ការពារធម្មជាតិអាស្រ័យជ្រុលលើការគាំទ្រហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល វាជាការបារម្ភមួយផងដែររបស់អង្គការមិនមែនរដ្ឋាភិបាល។ ការបារម្ភមានពីរផ្នែកដែលពាក់ព័ន្ធគ្នា: ផ្នែកទីមួយ គឺសហគមន៍អាចនឹងមានទម្លាប់ឲ្យតួអង្គខាងក្រៅគ្រប់គ្រងធនធានរបស់ខ្លួន និងនាំឲ្យពួកគេមិន«គ្រប់គ្រង»ផែនការគ្រប់គ្រងរបស់ខ្លួន ឯផ្នែកទីពីរគឺសហគមន៍ត្រូវស្របតាមកម្មវត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអាចនឹងមិនតំណាងឲ្យផលប្រយោជន៍ដ៏ល្អបំផុតរបស់សហគមន៍។[228] អង្គការមិនមែនរដ្ឋាភិបាល ខ្លាចក្រែងបើលែងមានការគាំទ្រទៅកាន់សហគមន៍តំបន់ការពារធម្មជាតិនៅចំណុចណាមួយនាពេលអនាគត នោះកិច្ចខំប្រឹងប្រែងទាំងឡាយកន្លងមកនឹងត្រូវអាសាបង់។[229]

អង្គការមិនមែនរដ្ឋាភិបាល គាំទ្រសហគមន៍ចំពោះសកម្មភាពជាច្រើនយ៉ាង ដោយផ្តោតជាញឹកញយដល់ការសម្របសម្រួលក្នុងការសហការជាមួយភាគីពាក់ព័ន្ធ និងការកសាងសមត្ថភាពរបស់សហគមន៍។ បញ្ហាចម្បងមួយស្ថិតនៅលើទំនាក់ទំនង។ ឧបសគ្គផ្នែកភាសាតែងតែបង្កជាបញ្ហាប្រឈមដល់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយក្រុមជនជាតិដើមភាគតិច ដែលពេលខ្លះនិយាយខ្មែរតិចតួច ឬមិនចេះតែម្តង។[230] បន្ថែមពីនេះ គំនិតក្នុងការគ្រប់គ្រងដែលប្រើដោយអង្គការមិនមែនរដ្ឋាភិបាល មានលក្ខណៈប្លែកទៅកាន់សហគមន៍មូលដ្ឋាន និងអាចមិនសមស្របក្នុងបរិបទមូលដ្ឋាន កំពុងបង្ករជាបញ្ហាលំបាកក្នុងការបង្កើតភាពជោគជ័យក្នុងសហគមន៍។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនចាប់ផ្តើមធ្វើការជាមួយសហគមន៍ មុនដំណាក់កាលនៃ( ការបង្កើត )សហគមន៍តំបន់ការពារធម្មជាតិចាប់ផ្តើម ដើម្បីផ្តល់សហគមន៍នូវពេលវេលាបន្ថែមក្នុងការកសាងសមត្ថភាពក្នុងការរៀបចំ ដើម្បីដាក់ស្នើពាក្យ( បង្កើត )សហគមន៍តំបន់ការពារធម្មជាតិ។[231] បញ្ហាចម្បងមួយទៀត គឺការស្វែងរកសម្លេងឯកច្ឆន្ទក្នុងចំណោមភាគីពាក់ព័ន្ធក្នុងការចូលរួមពិគ្រោះយោបល់។ បទពិសោធន៍បានបង្ហាញថា ដោយសារតែផលប្រយោជន៍ និងការយល់ដឹងផ្សេងៗគ្នាពីក្របខ័ណ្ឌច្បាប់សហគមន៍តំបន់ការពារធម្មជាតិក្នុងចំណោមសមាជិកសហគមន៍ និងអ្នកដទៃ គេអាចត្រូវការរយៈពេលជាច្រើនឆ្នាំទម្រាំតែសម្រេចបានកិច្ចព្រមព្រៀងស្តីពីវិធានក្នុងការគ្រប់គ្រង។[232]

បទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាល ជាមួយអាជ្ញាធរមានលក្ខណៈខុសៗគ្នា។ ជាទូទៅមានភាពខកចិត្តចំពោះវិមជ្ឈការអំណាចនាពេលថ្មីៗ ជារឿយៗមានភាពមិនច្បាស់លាស់ពីទំនួលខុសត្រូវរបស់អាជ្ញាធររដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ការយល់ដឹងពីក្របខ័ណ្ឌច្បាប់សហគមន៍តំបន់ការពារធម្មជាតិ ក៏មានភាពដោយឡែកយ៉ាងខ្លាំងផងដែរក្នុងចំណោមស្ថាប័នរបស់រដ្ឋាភិបាល ដែលនាំឲ្យមានការលំបាកក្នុងការសម្របសម្រួល។ បន្ថែមពីនេះ លទ្ធភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការប្រើប្រាស់ឥទ្ធិពលវិជ្ជមានរបស់ខ្លួនទៅលើការអភិវឌ្ឍរបស់សហគមន៍តំបន់ការពារធម្មជាតិក៏ខុសគ្នាយ៉ាងខ្លាំងផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលធំៗ ដែលមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ និងមានហិរញ្ញវត្ថុល្អ ត្រូវបានមើលឃើញថាមានលទ្ធភាព និងឥទ្ធិពលក្នុងការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរ។ នៅមិនទាន់មានការយល់ស្របជារួមនៅឡើយទេ ពីប្រសិទ្ធភាពក្នុងការការពារសិទ្ធិរបស់សហគមន៍តំបន់ការពារធម្មជាតិ តាមរយៈការពង្រឹងភាពជាដៃគូជាមួយអាជ្ញាធរជាតិ ធៀបទៅនឹងភាពជាដៃគូជាមួយអាជ្ញាធរខេត្ត។ បទពិសោធន៍ដែលទទួលបានផ្លាស់ប្តូរទៅតាមករណីនីមួយៗ។

## ការប្រាស្រ័យទាក់ទងនៅមានកម្រិតពីវិស័យឯកជន

តួអង្គវិស័យឯកជន ធ្វើការងារមួយផ្នែកធំជាមួយសហគមន៍តាមរយៈការសម្របសម្រួលដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងករណីសាកល្បងខ្លះ សហគមន៍រៀបចំការប្រជុំ និងចចារដោយផ្ទាល់ជាមួយតួអង្គវិស័យឯកជនដើម្បីការរៀបចំពាណិជ្ជកម្មផ្សេងៗ ហើយពេលខ្លះតួអង្គវិស័យឯកជនក៏ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកសហគមន៍ផងដែរ។[233] យ៉ាងណាក្តី ក្របខ័ណ្ឌអន្តរកម្មបែបនេះអាចកើតឡើងជាទៀងទាត់នៅបន្តខ្វះខាត។

### អនុសាសន៍ណែនាំ៖

**i.** ធានានូវភាពទៀងទាត់ និងគ្រប់គ្រាន់ផ្នែកលទ្ធភាព និងការផ្តល់ធនធានសម្រាប់ការគាំទ្រដោយចីរភាពចំពោះការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ ដោយរួមបញ្ចូលនូវលទ្ធភាពនៃសហគមន៍តំបន់ការពារធម្មជាតិក្នុងការប្រាស្រ័យទាក់ទងដោយសមស្របជាមួយភាគីពាក់ព័ន្ធខាងក្រៅ។

**ii.** បង្កើតគោលការណ៍ណែនាំប្រតិបត្តិដោយបញ្ជាក់ពីតួនាទី និងទំនួលខុសត្រូវក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរក្នុងករណីមានកិច្ចសហការក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍកម្រិតមូលដ្ឋាន។

**iii.** ធ្វើឲ្យផ្លូវការនូវនីតិវិធីក្នុងការបែងចែកចំណាយរវាងឃុំ និងអង្គការមិនមែនរដ្ឋាភិបាលទៅលើការគ្រប់គ្រងសកម្មភាព និងការកសាងតម្លាភាពក្នុងការគ្រប់គ្រងមូលនិធិសហគមន៍តំបន់ការពារធម្មជាតិ។

**iv.** លើកទឹកចិត្ត និងសម្របសម្រួលកិច្ចសហការយ៉ាងទូលំទូលាយរវាងសហគមន៍តំបន់ការពារធម្មជាតិ និងវិស័យឯកជន តាមរយៈការផ្តល់សិទ្ធិយ៉ាងជាក់ច្បាស់ដល់សហគមន៍ ក្នុងការក្លាយជាភាគីនៃកិច្ចសន្យា និងយន្តការសកម្មភាពពាណិជ្ជកម្មផ្សេងៗ រួមមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងការការពារ ដើម្បីកាត់បន្ថយវិសមភាពអំណាច ឬការកាន់កាប់ដោយមនុស្សមួយក្តាប់តូចទៅលើសហគមន៍តំបន់ការពារធម្មជាតិដោយក្រុមហ៊ុនឯកជន៕



# កំណត់ចំណាំចុងក្រោយ

1 This report was made possible by the Gilmour-Samson gift.

2 *See* ClientEarth, *Communities at the heart of forest management: How can the law make a difference?* (February 2019); ClientEarth, *Toolkit for enabling laws on community forestry* (September 2019). Note that ClientEarth's methodology uses the term "community forestry" to describe community-based natural resources management in a broader sense. The term used in the Toolkit should not be understood to mean "community forestry" as a specific model of community-based natural resources management in Cambodia.

3 ClientEarth created a first-of-its-kind legal *Toolkit for enabling laws on community forestry* (September 2019) to support the development of laws on community-based natural resources management worldwide. The toolkit draws on lessons from community-based natural resources management models of Nepal, the Philippines and Tanzania, summarized in ClientEarth, *Communities at the heart of forest management: How can the law make a difference?* (February 2019). This report provides governments and communities with legal guidance to reform and implement community forestry laws.

4 Paley, R., "Managing Protected Areas in Cambodia," *Conservation and Development in Cambodia: Exploring Frontiers of Change in Nature, State and Society*, 141-59 (2015).

